ធនាគារកម្ពុជាសាធារណៈ

# លើកកម្ពស់និរន្តរភាពបរិស្ថាន សង្គម និងអភិបាលកិច្ច

របាយការណ៍ប្រចាំឆ្នាំ២០២៤



# បេសកកម្ម និងចក្ខុវិស័យរួម

*រក្សាឱ្យបាននូវស្ថានភាពជាគ្រឹះស្ថានហិរញ្ញវត្ថុលេខមួយ ដែលពោរពេញទៅដោយប្រសិទ្ធភាព ចំណេញ និងទទួលបាននូវការគោរពស្ញប់ស្ញែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។*




## ប្រសិទ្ធភាព . ចំណេញ . ការគោរពស្ញប់ស្ញែង

# មាតិកា


3 ព័ត៌មានរួម

4 បណ្ដាញសាខា

11 ប្រវត្តិធនាគារ

12 ការគូសបញ្ជាក់អំពីស្ថានភាពហិរញ្ញវត្ថុ

13 តារាងតុល្យការបំព្រួញ

14 ការសង្ខេបទៅលើកំណើនប្រាំឆ្នាំ

15 ក្រុមប្រឹក្សាភិបាល

16 ប្រវត្តិរូបរបស់ក្រុមប្រឹក្សាភិបាល

19 របាយការណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល

23 ទិដ្ឋភាពទូទៅនៃអភិបាលកិច្ចក្រុមហ៊ុន

34 ប្រតិបត្តិការអាជីវកម្ម

41 ការវិភាគរបាយការណ៍ហិរញ្ញវត្ថុ

43 របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

49 របាយការណ៍របស់សវនករឯករាជ្យ

52 របាយការណ៍ស្ដីពីស្ថានភាពហិរញ្ញវត្ថុរួម

54 របាយការណ៍លទ្ធផលពេញលេញរួម

55 របាយការណ៍ស្ដីពីបម្រែបម្រួលមូលធនរួម

57 របាយការណ៍លំហូរសាច់ប្រាក់រួម

58 របាយការណ៍ស្ថានភាពហិរញ្ញវត្ថុដាច់ដោយឡែក

60 របាយការណ៍លទ្ធផលពេញលេញដាច់ដោយឡែក

61 របាយការណ៍បម្រែបម្រួលមូលធនដាច់ដោយឡែក

63 របាយការណ៍លំហូរសាច់ប្រាក់ដាច់ដោយឡែក

64 កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក

188 ប្រតិទិននៃព្រឹត្តិការណ៍សំខាន់ៗ

# ព័ត៌មានរួម

## ក្រុមប្រឹក្សាភិបាល

Dato' Mohammed Najeeb bin Abdullah
ប្រធានក្រុមប្រឹក្សាភិបាលមិនប្រតិបត្តិឯករាជ្យ

Dato' Chang Kat Kiam
អភិបាលមិនប្រតិបត្តិមិនឯករាជ្យ

Mr. Quah Poh Keat
អភិបាលមិនប្រតិបត្តិមិនឯករាជ្យ

**បណ្ឌិត ផៃ ទូច**
អភិបាលមិនប្រតិបត្តិឯករាជ្យ

Mr. Ong Ming Teck

អភិបាលប្រតិបត្តិ

## លេខាធិការរួមរបស់ក្រុមហ៊ុន

Cik Wan Marhanim Binti Wan Muhammad

**លោក ង៉ោ លីកូ**

## សវនករ

អឺនស្ទ៍ អេន យ៉ាំង (ខេមបូឌា)
ជាន់ទី 3 មជ្ឈមណ្ឌល SSN អគារលេខ 66 មហាវិថីព្រះនរោត្តម
សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ 12206 រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

## ទីស្នាក់ការកណ្តាល

អគារលេខ 23 ផ្លូវលេខ 114
សង្កាត់ផ្សារថ្មីទី 2 ខណ្ឌដូនពេញ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ ៖ (855) 23 222 880 / 222 881 / 222 882
ទូរសារលេខ ៖ (855) 23 222 887
SWIFT ៖ CPBLKHPP
អ៊ីមែល ៖ hoe@campubank.com.kh

## គេហទំព័រ

គេហទំព័រ ៖ www.campubank.com.kh

# បណ្តាញសាខា

## សាខានៅរាជធានីភ្នំពេញ

**ខណ្ឌបឹងកេងកង - សង្កាត់បឹងកេងកងទី១** (អតីតសាខាមហាវិថីព្រះសីហនុ)
ផ្ទះលេខ១០២បេ មហាវិថីព្រះសីហនុ ភូមិ៥
សង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ ៖ (855) 23 998 091 / 998 092 / 998 093
ទូរសារលេខ ៖ (855) 23 998 094
អ៊ីម៉ែល ៖ campupsb@campubank.com.kh

**ខណ្ឌបឹងកេងកង - សង្កាត់បឹងកេងកងទី២** (អតីតសាខាព្រះមុនីវង្ស)
ផ្ទះលេខ៥៤១អឺ០ & ៥៤៣អឺ០ មហាវិថីព្រះមុនីវង្ស ភូមិ១
សង្កាត់បឹងកេងកងទី២ ខណ្ឌបឹងកេងកង
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ ៖ (855) 23 992 630 / 992 631 / 992 632
អ៊ីម៉ែល ៖ campumng@campubank.com.kh

**ខណ្ឌបឹងកេងកង-សង្កាត់អូឡាំពិក** (អតីតសាខាផ្សារអូឡាំពិក)
ផ្ទះលេខ៣៧០អឺ០ ផ្លូវលេខ១៩៣ ភូមិ៣
សង្កាត់អូឡាំពិក ខណ្ឌបឹងកេងកង
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ ៖ (855) 23 988 560 / 988 561 / 988 563
អ៊ីម៉ែល ៖ campuomt@campubank.com.kh

**ខណ្ឌបឹងកេងកង - សង្កាត់ទួលស្វាយព្រៃទី១** (អតីតសាខាផ្សារម៉ៅសេទុង)
ផ្ទះលេខ២១៧អាបេសេដេ មហាវិថីម៉ៅសេទុង ភូមិ៦
សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌបឹងកេងកង
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ ៖ (855) 23 987 293 / 987 294 / 987 295
ទូរសារលេខ ៖ (855) 23 987 296
អ៊ីម៉ែល ៖ campumtt@campubank.com.kh

# បណ្តាញសាខា

**ខណ្ឌចំការមន-សង្កាត់ទន្លេបាសាក់** (អតីតសាខាបឹងត្របែក)
ផ្ទះលេខ៤៣២ មហាវិថីព្រះមុនីវង្ស ភូមិ១៣
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ ៖ (855) 23 989 310 / 989 311 / 989 312
អ៊ីម៉ែល ៖ campubtk@campubank.com.kh

**ខណ្ឌចំការមន - សង្កាត់ទួលទំពូងទី១** (អតីតសាខាទួលទំពូង)
ផ្ទះលេខ១៧០អា & បេ ផ្លូវលេខ១៥៥ ភូមិ៤
សង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ ៖ (855) 23 996 940 / 996 941 / 996 942
អ៊ីម៉ែល ៖ camputtp@campubank.com.kh

**ខណ្ឌច្បារអំពៅ - សង្កាត់ច្បារអំពៅទី១** (អតីតសាខាច្បារអំពៅ)
ផ្ទះលេខ១៦ ផ្លូវជាតិលេខ១ ភូមិដើមអំពិល
សង្កាត់ច្បារអំពៅទី១ ខណ្ឌច្បារអំពៅ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ ៖ (855) 23 997 976 / 997 977 / 997 978
ទូរសារលេខ ៖ (855) 23 997 975
អ៊ីម៉ែល ៖ campucba@campubank.com.kh

**ខណ្ឌជ្រោយចង្វារ-សង្កាត់ជ្រោយចង្វារ** (អតីតសាខាជ្រោយចង្វារ)
ផ្ទះលេខអែហ្វ០១ & អែហ្វ០២ ផ្លូវជាតិលេខ៦អា ភូមិ៣
សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ ៖ (855) 23 432 301 / 432 302 / 432 303
អ៊ីម៉ែល ៖ campuccv@campubank.com.kh

# បណ្តាញសាខា

**ខណ្ឌដង្កោ-សង្កាត់ដង្កោ** (អតីតសាខាបឹងទំពុន)
ក្បាលដីលេខគ៣១៥៩ ផ្លូវលេខ៣៧១ ភូមិម៉ល
សង្កាត់ដង្កោ ខណ្ឌដង្កោ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ ៖ (855) 23 901 140 / 901 141 / 901 142
អ៊ីម៉ែល ៖ campubtn@campubank.com.kh

**ខណ្ឌដូនពេញ-សង្កាត់ផ្សារកណ្តាលទី២** (អតីតសាខាកណ្តាល)
ផ្ទះលេខ១២៩ ១៣១ & ១៣៣ ផ្លូវលេខ១៤៤ ភូមិ៤
សង្កាត់ផ្សារកណ្តាលទី២ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ ៖(855) 23 988 300 / 988 301 / 988 302
អ៊ីម៉ែល ៖ campupkd@campubank.com.kh

**ខណ្ឌដូនពេញ - សង្កាត់ផ្សារថ្មីទី២** (អតីតសាខាភ្នំពេញ)
អគារលេខ២៣ ជាន់ផ្ទាល់ដី & ជាន់ទី១ ផ្លូវក្រមួនសរ
សង្កាត់ផ្សារថ្មីទី២ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ ៖ (855) 23 214 111 / 217 686 / 223 182
ទូរសារលេខ ៖ (855) 23 217 655
អ៊ីម៉ែល ៖ campupnh@campubank.com.kh

**ខណ្ឌកំបូល - សង្កាត់កន្ទោក** (អតីតសាខាភីអ៊ីហ្សេត)
ផ្ទះលេខអា២ ផ្លូវជាតិលេខ៤ ភូមិត្រពាំងគល់
សង្កាត់កន្ទោក ខណ្ឌកំបូល
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ ៖ (855) 23 729 311 / 729 312 / 729 313
អ៊ីម៉ែល ៖ campupez@campubank.com.kh

**ខណ្ឌមានជ័យ - សង្កាត់ស្ទឹងមានជ័យទី១** (អតីតសាខាស្ទឹងមានជ័យ)
ផ្ទះលេខ៦១អា ៦២អា ៦៣អា ៦៤អា & ៦៥អា មហាវិថីវេងស្រេង ភូមិទ្រា៣
សង្កាត់ស្ទឹងមានជ័យទី១ ខណ្ឌមានជ័យ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ ៖ (855) 23 969 601 / 969 602 / 969 603
ទូរសារលេខ ៖ (855) 23 969 606
អ៊ីម៉ែល ៖ campusmy@campubank.com.kh

## បណ្ដាញសាខា

**ខណ្ឌ៧មករា - សង្កាត់វាលវង់** (អតីតសាខាអូឡាំពិក)
ផ្ទះលេខ ២៦៧ ២៦៩ & ២៧១ មហាវិថីព្រះសីហនុ ភូមិ៧
សង្កាត់វាលវង់ ខណ្ឌ៧មករា
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ ៖ (855) 23 222 860 / 222 861 / 222 862
អ៊ីម៉ែល ៖ campuolympic@campubank.com.kh

**ខណ្ឌឫស្សីកែវ - សង្កាត់គីឡូម៉ែត្រលេខ៦** (អតីតសាខាឫស្សីកែវ)
ផ្ទះលេខ៤៩០ ផ្លូវជាតិលេខ៥ ភូមិក្រោលគោ
សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ ៖ (855) 23 902 520 / 902 521 / 902 522
អ៊ីម៉ែល ៖ campurko@campubank.com.kh

**ខណ្ឌសែនសុខ - សង្កាត់អូរបែកក្អម** (អតីតសាខាទឹកថ្លា)
ផ្ទះលេខ៧ ៩ & ១១ អឺ០-អឺ៤ ផ្លូវលេខ១១០អា ភូមិទ្រុងមាន់
សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ ៖ (855) 23 995 202 / 995 203 / 995 204
ទូរសារលេខ ៖ (855) 23 995 205
អ៊ីម៉ែល ៖ camputta@campubank.com.kh

**ខណ្ឌសែនសុខ - សង្កាត់ភ្នំពេញថ្មី** (អតីតសាខាសែនសុខ)
ផ្ទះលេខ២៤១ ២៤៣ ២៤៥ & ២៤៧ ផ្លូវលេខ១០០៣ ភូមិបាយ៉ាប
សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ ៖ (855) 23 901 380 / 901 381 / 901 382
អ៊ីម៉ែល ៖ campussh@campubank.com.kh

**ខណ្ឌសែនសុខ-សង្កាត់ទឹកថ្លា** (អតីតសាខាផ្លូវ ២៧១)
ផ្ទះលេខ២៦ ផ្លូវលេខ២៧១ ភូមិបុរីកម្មករ
សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ ៖ (855) 23 969 610 / 969 611 / 969 612
អ៊ីម៉ែល ៖ campust271@campubank.com.kh

# បណ្ដាញសាខា

**ខណ្ឌទួលគោក - សង្កាត់បឹងកក់ទី១** (អតីតសាខាទួលគោក)
ផ្ទះលេខ១៥០អេហ្វ២អា ១៥០អេហ្វ២បេ & ១៥០អេហ្វ២សេ
ផ្លូវលេខ២៨៩ ភូមិ១៣
សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ ៖ (855) 23 992 480 / 992 481/ 992 482
ទូរសារលេខ ៖ (855) 23 992 484
អ៊ីម៉ែល ៖ camputkk@campubank.com.kh

**ខណ្ឌទួលគោក - សង្កាត់ផ្សារដើមគរ** (អតីតសាខាផ្សារដើមគរ)
ផ្ទះលេខ ២៨១ មហាវិថីម៉ៅសេទុង ភូមិ១
សង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ ៖ (855) 23 996 118 / 996 119 / 996 120
អ៊ីម៉ែល ៖ campupdr@campubank.com.kh

## សាខានៅតាមបណ្ដាខេត្ត

**ក្រុងបាត់ដំបង - សង្កាត់ស្វាយប៉ោ** (អតីតសាខាខេត្តបាត់ដំបង)
ផ្ទះលេខ១០២ ផ្លូវព្រះវិហារ ភូមិ២០ ឧសភា
សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ ៖ (855) 53 953 801 / 953 802 / 953 803
អ៊ីម៉ែល ៖ campubtb@campubank.com.kh

**ក្រុងបាវិត - សង្កាត់បាវិត** (អតីតសាខាបាវិត)
ក្បាលដីលេខអឺIII១៧០៣ ផ្លូវជាតិលេខ១ ភូមិបាវិតកណ្ដាល
សង្កាត់បាវិត ក្រុងបាវិត
ខេត្តស្វាយរៀង ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ ៖ (855) 44 946 100 / 946 101 / 946 102
អ៊ីម៉ែល ៖ campubvt@campubank.com.kh

**ក្រុងច្បារមន - សង្កាត់រការធំ** (អតីតសាខាខេត្តកំពង់ស្ពឺ)
ក្បាលដីលេខ៥៨០ ផ្លូវជាតិលេខ៤ ភូមិក្រាំងពលទេព
សង្កាត់រការធំ ក្រុងច្បារមន
ខេត្តកំពង់ស្ពឺ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ ៖ (855) 25 987 500 / 987 501 / 987 502
អ៊ីម៉ែល ៖ campuksu@campubank.com.kh

# បណ្តាញសាខា

**ក្រុងកំពង់ចាម - សង្កាត់កំពង់ចាម** (អតីតសាខាខេត្តកំពង់ចាម)
ក្បាលដីលេខប៉េ១០៥០០ ផ្លូវកុសមៈនារីរ័ត្ន ភូមិទី១១
សង្កាត់កំពង់ចាម ក្រុងកំពង់ចាម
ខេត្តកំពង់ចាម ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ ៖ (855) 42 942 180 / 942 181 / 942 182
អ៊ីម៉ែល ៖ campukgcham@campubank.com.kh

**ក្រុងកំពត-សង្កាត់កំពង់បាយ** (អតីតសាខាខេត្តកំពត)
ផ្ទះលេខ៤៥ ផ្លូវជាតិលេខ៣ ភូមិកំពង់បាយខាងត្បូង
សង្កាត់កំពង់បាយ ក្រុងកំពត
ខេត្តកំពត ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ ៖ (855) 33 932 760 / 932 761 / 932 762
អ៊ីម៉ែល ៖ campukpt@campubank.com.kh

**ក្រុងខេមរភូមិន្ទ-សង្កាត់ដងទង់** (អតីតសាខាខេត្តកោះកុង)
ក្បាលដីលេខ៣២១ ផ្លូវលេខ២ ភូមិទី១
សង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ
ខេត្តកោះកុង ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ ៖ (855) 35 936 600 / 936 601 / 936 602
អ៊ីម៉ែល ៖ campukkg@campubank.com.kh

**ក្រុងប៉ោយប៉ែត - សង្កាត់អូរជ្រៅ** (អតីតសាខាប៉ោយប៉ែត)
ក្បាលដីលេខសេVIII៣២៦៧ ផ្លូវជាតិលេខ៥ ភូមិអូរជ្រៅ
សង្កាត់អូរជ្រៅ ក្រុងប៉ោយប៉ែត
ខេត្តបន្ទាយមានជ័យ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ ៖ (855) 54 967 356 / 967 357 / 967 358
អ៊ីម៉ែល ៖ campuppt@campubank.com.kh

**ក្រុងព្រះសីហនុ - សង្កាត់២** (អតីតសាខាខេត្តព្រះសីហនុ)
ក្បាលដីលេខអាII០១៨៦ ផ្លូវសុភមង្គល ភូមិ៣
សង្កាត់២ ក្រុងព្រះសីហនុ
ខេត្តព្រះសីហនុ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ ៖ (855) 34 934 130 / 934 131 / 934 132
អ៊ីម៉ែល ៖ campupsk@campubank.com.kh

# បណ្ដាញសាខា

**ក្រុងសៀមរាប-សង្កាត់ស្លក្រាម** (អតីតសាខាផ្សារលើ)
ក្បាលដីលេខ២៣៧៧ & ២៨០២ ផ្លូវជាតិលេខ៦ ភូមិចុងកៅស៊ូ
សង្កាត់ស្លក្រាម ក្រុងសៀមរាប
ខេត្តសៀមរាប ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ ៖ (855) 63 962 100 / 962 101 / 962 102
អ៊ីម៉ែល ៖ campuplu@campubank.com.kh

**ក្រុងសៀមរាប - សង្កាត់ស្វាយដង្គំ** (អតីតសាខាខេត្តសៀមរាប)
ផ្ទះលេខ៣៩ ៤០ & ៤១ ផ្លូវស៊ីវុត្ថា ភូមិមណ្ឌល២
សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប
ខេត្តសៀមរាប ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ ៖ (855) 63 964 777 / 964 889/ 964 890
ទូរសារលេខ ៖ (855) 63 963 899
អ៊ីម៉ែល ៖ campusrp@campubank.com.kh

**ក្រុងសួង-សង្កាត់សួង** (អតីតសាខាខេត្តសួង)
ផ្ទះលេខ 263 ផ្លូវជាតិលេខ 7 ភូមិជើងឡូង
សង្កាត់សួង ក្រុងសួង
ខេត្តត្បូងឃ្មុំ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ ៖ (855) 42 218 380 / 218 381 / 218 382
អ៊ីម៉ែល ៖ campusug@campubank.com.kh

**ក្រុងតាខ្មៅ-សង្កាត់តាខ្មៅ** (អតីតសាខាតាខ្មៅ)
ក្បាលដីលេខ១៣៤ ផ្លូវលេខ២០៣ កែង ១០៦ ភូមិតាខ្មៅ
សង្កាត់តាខ្មៅ ក្រុងតាខ្មៅ
ខេត្តកណ្ដាល ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ ៖ (855) 24 985 001 / 985 002 / 985 003
ទូរសារលេខ ៖ (855) 24 985 011
អ៊ីម៉ែល ៖ camputakhmao@campubank.com.kh

# ប្រវត្តិធនាគារ

## ជីវប្រវត្តិរបស់ធនាគារកម្ពុជាសាធារណៈ

ធនាគារកម្ពុជាសាធារណៈ (ហៅកាត់ថា "ធនាគារ" ឬ "ធនាគារកម្ពុ") ត្រូវបានបង្កើតឡើងនាថ្ងៃទី20 ខែកុម្ភៈ ឆ្នាំ1992 និងចាប់ផ្តើមប្រតិបត្តិការអាជីវកម្មដំបូងនៅក្នុងព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី25 ខែឧសភា ឆ្នាំ1992។ ធនាគារមេរបស់ធនាគារកម្ពុ គឺធនាគារសាធារណៈ (Public Bank Berhad) ដែលត្រូវបានបង្កើត និងមានអាជ្ញាប័ណ្ណធនាគារនៅក្នុងប្រទេសម៉ាឡេស៊ី។ ធនាគារសាធារណៈ ជាធនាគារកំពូលមួយ និងមានកិត្តិស័ព្ទល្បីល្បាញលើការគ្រប់គ្រងដ៏ប្រុងប្រយ័ត្ន សេវាកម្មអតិថិជនលំដាប់ខ្ពស់ ជាមួយការផ្តល់ជូនដ៏ល្អឥតខ្ចោះ អភិបាលកិច្ច និងវប្បធម៌អាជីវកម្មដ៏រឹងមាំ។

សកម្មភាពចម្បងរបស់ធនាគារ គឺធ្វើប្រតិបត្តិការលើរាល់សកម្មភាពអាជីវកម្មធនាគារ និងផ្តល់សេវាទាំងឡាយដែលពាក់ព័ន្ធនឹងសេវាកម្មហិរញ្ញវត្ថុ។ ធនាគារកម្ពុបានរីកចម្រើនធំធាត់ពីមួយឆ្នាំទៅមួយឆ្នាំ។ បណ្តាញសាខារបស់ធនាគារបានកើនឡើងដល់ 32 សាខា។

## ទស្សនវិស័យរួម

ធនាគារកម្ពុយកចិត្តទុកដាក់ចំពោះអតិថិជនរបស់ខ្លួន

- ដោយផ្តល់ជូននូវសេវាប្រកបដោយប្រសិទ្ធភាព និងភាពរួសរាយរាក់ទាក់គ្រប់ប្រភេទអាជីវកម្ម។
- ដោយបង្កើតផលិតផល និងសេវាកម្មធនាគារថ្មីៗ។

ធនាគារកម្ពុយកចិត្តទុកដាក់ចំពោះបុគ្គលិករបស់ខ្លួន

- ដោយលើកកម្ពស់សុខុមាលភាពរបស់បុគ្គលិកធនាគារតាមរយៈការផ្តល់ជូនប្រាក់បៀវត្ស និងអត្ថប្រយោជន៍បន្ថែមផ្សេងៗទៀតគួរឱ្យទាក់ទាញ។
- ដោយពង្រឹងផ្នែកស្មារតីតាមរយៈការបណ្តុះបណ្តាល និងការអភិវឌ្ឍន៍បុគ្គលិក និងផ្តល់ជូននូវឱកាសសម្រាប់ការតំឡើងឋានៈ និងតួនាទី ។

ធនាគារកម្ពុយកចិត្តទុកដាក់ចំពោះសហគមន៍ដែលខ្លួនផ្តល់សេវាជូន

- ដោយកំណត់តួនាទីរបស់ខ្លួនជាអ្នកទទួលខុសត្រូវក្នុងសង្គមជាលក្ខណៈរូបិយមួយ ។
- ដោយផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងគោលនយោបាយ និងទិសដៅរបស់ប្រទេសជាតិដើម្បីរួមចំណែកក្នុងដំណើរការអភិវឌ្ឍន៍ប្រទេសជាតិទាំងមូល ។

**.... ជាមួយនឹងបូរណភាព ។**

# ការគូសបញ្ជាក់អំពីស្ថានភាពហិរញ្ញវត្ថុ

| | ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែធ្នូ | |
|---|---|---|
| | 2024 | 2023 |
| **លទ្ធផលប្រតិបត្តិការ (ពាន់ដុល្លារអាមេរិក)** | | |
| ប្រាក់ចំណេញមុនដកពន្ធ | 80,627 | 74,002 |
| ប្រាក់ចំណេញក្រោយដកពន្ធ | 64,570 | 59,315 |
| **ទិន្នន័យតារាងតុល្យការសំខាន់ៗ (ពាន់ដុល្លារអាមេរិក)** | | |
| ទ្រព្យសកម្មសរុប | 2,410,477 | 2,186,461 |
| ឥណទាន និងបុរេប្រទានសុទ្ធ | 1,480,461 | 1,389,551 |
| ទ្រព្យអកម្មសរុប | 1,555,374 | 1,395,928 |
| ប្រាក់បញ្ញើរបស់អតិថិជន | 1,476,461 | 1,337,409 |
| ដើមទុនបានបង់ | 90,000 | 90,000 |
| មូលធនភាគទុនិក | 855,103 | 790,533 |
| ការសន្យា និងភាពជាយថាភាព | 309,262 | 402,697 |
| **អនុបាតហិរញ្ញវត្ថុ (%)** | | |
| ឥណទានមិនដំណើរការ ធៀបនឹងឥណទាន និងបុរេប្រទានសរុប | 1.94 | 1.40 |
| ផលចំណូលសុទ្ធពីទ្រព្យសកម្ម | 2.68 | 2.71 |
| ផលចំណូលសុទ្ធពីមូលធនសុទ្ធ | 7.55 | 7.50 |
| ចំណូលការប្រាក់សុទ្ធធៀបនឹងចំណូលដុល | 71.87 | 74.84 |
| ចំណាយក្រៅពីការប្រាក់ធៀបនឹងចំណូលដុល | 23.05 | 23.43 |
| អនុបាតក្រមខណ្ឌសន្ទនីយភាព | 159.47 | 151.55 |
| អនុបាតសោធនភាព | 26.75 | 28.06 |
| អនុបាតឥណទានដុលធៀបនឹងប្រាក់បញ្ញើ | 99.10 | 103.71 |
| **អនុបាតលើផលសម្រេច (ពាន់ដុល្លារអាមេរិក)** | | |
| ឥណទានដុលធៀបនឹងចំនួនបុគ្គលិក | 1,613 | 1,500 |
| ប្រាក់បញ្ញើរបស់អតិថិជនធៀបនឹងចំនួនបុគ្គលិក | 1,594 | 1,429 |
| ប្រាក់ចំណេញមុនកាត់ពន្ធធៀបនឹងចំនួនបុគ្គលិក | 87.07 | 79.06 |
| ចំនួនបុគ្គលិក | 926 | 936 |

## តារាងតុល្យការបំព្រួញរបស់ធនាគារ

# តារាងតុល្យការបំព្រួញ

### ទ្រព្យសកម្ម




**សរុប 2024**
**2,410.5 លានដុល្លារអាមេរិក**
2023: 2,186.5 លានដុល្លារអាមេរិក




- ទ្រព្យ និងបរិក្ខារ
- ប្រាក់បញ្ញើ កំណត់ដោយច្បាប់
- ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា
- ឥណទាន និងបុរេប្រទានសុទ្ធ
- សាច់ប្រាក់ និងសមតុល្យធនាគារ
- ទ្រព្យសកម្មផ្សេងៗ

### បំណុល និងមូលធនរបស់ភាគទុនិក




**សរុប 2024**
**2,410.5 លានដុល្លារអាមេរិក**
2023: 2,186.5 លានដុល្លារអាមេរិក




- ប្រាក់បញ្ញើរបស់អតិថិជន
- ប្រាក់ចំណេញរក្សាទុក
- ទុនបម្រុងមិនអាចបែងចែកបាន
- ដើមទុនបានបង់
- ប្រាក់បញ្ញើធនាគារនានា
- បំណុលផ្សេងៗ
- ទុនបម្រុងតាមច្បាប់

# ការសង្ខេបទៅលើកំណើនប្រាំឆ្នាំរបស់ធនាគារ



# ក្រុមប្រឹក្សាភិបាល



**Dato' Mohammed Najeeb bin Abdullah**
ប្រធានក្រុមប្រឹក្សាភិបាលមិនប្រតិបត្តិឯករាជ្យ



**Dato' Chang Kat Kiam**
អភិបាលមិនប្រតិបត្តិមិនឯករាជ្យ



**Mr. Quah Poh Keat**
អភិបាលមិនប្រតិបត្តិមិនឯករាជ្យ



បណ្ឌិត ផៃ ទូច
អភិបាលមិនប្រតិបត្តិឯករាជ្យ



**Mr. Ong Ming Teck**
អភិបាលប្រតិបត្តិ

# ប្រវត្តិរូបរបស់ក្រុមប្រឹក្សាភិបាល

Dato' Mohammed Najeeb bin Abdullah

## ប្រធានក្រុមប្រឹក្សាភិបាលមិនប្រតិបត្តិឯករាជ្យ

Dato' Mohammed Najeeb bin Abdullah អាយុ 71 ឆ្នាំ ត្រូវបានតែងតាំងជាអភិបាលមិនប្រតិបត្តិឯករាជ្យនៃធនាគារកម្ពុជាសាធារណៈ ភីអិលស៊ី នៅថ្ងៃទី9 ខែមិថុនា ឆ្នាំ2015 ហើយត្រូវបានតែងតាំងជាអនុប្រធានក្រុមប្រឹក្សាភិបាលមិនប្រតិបត្តិឯករាជ្យរបស់ធនាគារកម្ពុនាថ្ងៃទី5 ខែមិថុនា ឆ្នាំ2018 និងក្រោយមកត្រូវបានតែងតាំងជាប្រធានក្រុមប្រឹក្សាភិបាលមិនប្រតិបត្តិឯករាជ្យនៅថ្ងៃទី25 ខែមេសា ឆ្នាំ2023។

Dato' Mohammed Najeeb បានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែករដ្ឋបាលអាជីវកម្ម (គណនេយ្យ និងហិរញ្ញវត្ថុ) ពីសាកលវិទ្យាល័យ Charles Darwin ប្រទេសអូស្ត្រាលី។ លោកក៏បានបញ្ចប់សញ្ញាប័ត្រផ្នែកទីផ្សារពី Chartered Institute of Marketing នៃចក្រភពអង់គ្លេសផងដែរ។

Dato' Mohammed Najeeb មានបទពិសោធន៍ខាងវិស័យធនាគារនៅក្នុងប្រទេសម៉ាឡេស៊ីសរុបចំនួន 46 ឆ្នាំ។ មុនពេលលោកចូលបម្រើការងារនៅធនាគារសាធារណៈក្នុងឆ្នាំ1983 លោកបានបម្រើការងារនៅតាមធនាគារធំៗនៅក្នុងប្រទេសម៉ាឡេស៊ីអស់រយៈពេល 9 ឆ្នាំ។ ក្នុងអំឡុងពេលបម្រើការងារនៅធនាគារសាធារណៈ លោកបានកាន់មុខតំណែងជាគណៈគ្រប់គ្រងជាន់ខ្ពស់ជាច្រើន រួមមានប្រធានផ្នែកប្រតិបត្តិការធនាគារ Islamic របស់ធនាគារសាធារណៈចាប់ពីឆ្នាំ1998 ដល់ឆ្នាំ2008 និងជាអគ្គនាយកនៃ Public Islamic Bank ចាប់ពីឆ្នាំ2008 ដល់ ឆ្នាំ2010។

Dato' Mohammed Najeeb បានលាឈប់ពី Public Islamic Bank នៅពេលលោកត្រូវបានតែងតាំងជាសមាជិកព្រឹទ្ធសភាម៉ាឡេស៊ីនៅក្នុងខែមេសា ឆ្នាំ2010 ជាមុខតំណែងដែលលោកបានកាន់រហូតដល់ចប់អាណត្តិនៅឆ្នាំ2013។

ភាពជាអភិបាលរបស់លោកនៅក្នុងក្រុមហ៊ុនផ្សេងៗនៃសម្ព័ន្ធធនាគារសាធារណៈ រួមមាន PB Trustee Services Berhad, Public Mutual Berhad ក្រុមហ៊ុនធានារ៉ាប់រង កម្ពុ ឡុនប៉ាក ភីអិលស៊ី Public Bank Vietnam Limited, Public Bank Securities Vietnam Company Limited និង Public Bank Lao Limited។

Dato' Chang Kat Kiam

## អភិបាលមិនប្រតិបត្តិមិនឯករាជ្យ

Dato' Chang Kat Kiam អាយុ 70 ឆ្នាំ ទទួលបានសញ្ញាបត្រជាន់ខ្ពស់ផ្នែករដ្ឋបាលអាជីវកម្ម និងត្រូវបានតែងតាំងជាអភិបាលមិនប្រតិបត្តិមិនឯករាជ្យនៃធនាគារកម្ពុជាសាធារណៈ ភីអិលស៊ី នៅថ្ងៃទី11 ខែសីហា ឆ្នាំ2009។

លោកបានបម្រើការងារនៅធនាគារសាធារណៈចាប់តាំងពីឆ្នាំ1975 ហើយលោកមានបទពិសោធន៍គ្រប់ផ្នែកនៃប្រតិបត្តិការធនាគារ រួមមានការគ្រប់គ្រងសាខា និងមុខងារអាជីវកម្មធនាគារនៅទីស្នាក់ការកណ្តាល។ Dato' Chang ត្រូវបានតែងតាំងជានាយកប្រតិបត្តិប្រតិបត្តិការនៃធនាគារសាធារណៈនៅក្នុងឆ្នាំ2006 ហើយបានផ្លាស់ប្តូរមុខតំណែងជានាយកប្រតិបត្តិប្រតិបត្តិការជាន់ខ្ពស់នៅខែតុលា ឆ្នាំ2013។ លោកត្រូវបានតែងតាំងជាមួយមុខតំណែងបច្ចុប្បន្នជានាយករងប្រតិបត្តិនៃធនាគារសាធារណៈក្នុងខែមករា ឆ្នាំ2016។

ភាពជាអភិបាលរបស់លោកនៅក្នុងក្រុមហ៊ុនផ្សេងៗក្នុងសម្ព័ន្ធធនាគារសាធារណៈ រួមមាន Public Financial Holdings Ltd, Public Finance Ltd, Public Bank (Hong Kong) Ltd ក្រុមហ៊ុនធានារ៉ាប់រង កម្ពុ ឡុនប៉ាក ភីអិលស៊ី ក្រុមហ៊ុន មូលបត្រ កម្ពុ ម.ភ Public Bank Vietnam Limited, Public Bank Securities Vietnam Company Limited, Public Bank Lao Limited ក្រុមហ៊ុន ស៊ីភីប៊ី ប្រូភ័រធី ខូ អិលធីឌី និង AIA Public Takaful Bhd។

# ប្រវត្តិរូបរបស់ក្រុមប្រឹក្សាភិបាល

លោក Quah Poh Keat
### អភិបាលមិនប្រតិបត្តិមិនឯករាជ្យ

លោក Quah Poh Keat អាយុ 72 ឆ្នាំ ត្រូវបានតែងតាំងជាអភិបាលមិនប្រតិបត្តិឯករាជ្យរបស់ធនាគារកម្ពុជាសាធារណៈ ភីអិលស៊ី នៅថ្ងៃទី11 ខែសីហា ឆ្នាំ2009។

លោក Quah ត្រូវបានផ្លាស់ប្តូរមុខតំណែងជាអភិបាលមិនប្រតិបត្តិមិនឯករាជ្យរបស់ធនាគារ បន្ទាប់ពីការតែងតាំងជានាយករងប្រតិបត្តិទី 2 នៃធនាគារសាធារណៈ ដែលជាក្រុមហ៊ុនមេនៅថ្ងៃទី31 ខែតុលា ឆ្នាំ2013។ លោកបានចូលនិវត្តន៍ក្នុងមុខតំណែងជានាយករងប្រតិបត្តិនៃធនាគារសាធារណៈចាប់ពីថ្ងៃទី1 ខែមករា ឆ្នាំ2016។

លោកជាសមាជិកមួយរូបនៃវិទ្យាស្ថានពន្ធដារម៉ាឡេស៊ី និងសមាគមគណនេយ្យករ ជំនាញជាន់ខ្ពស់ (ACCA) ហើយក៏ជាសមាជិកមួយរូបនៃវិទ្យាស្ថានគណនេយ្យករម៉ាឡេស៊ី វិទ្យាស្ថានគណនេយ្យករជំនាញសាធារណៈម៉ាឡេស៊ី និងវិទ្យាស្ថានគ្រប់គ្រងគណនេយ្យករជាន់ខ្ពស់ផងដែរ។

លោកធ្លាប់ជាដៃគូសវនកម្មរបស់ក្រុមហ៊ុន KPMG ក្នុងប្រទេសម៉ាឡេស៊ីចាប់តាំងពីខែតុលា ឆ្នាំ1982 និងត្រូវបានតែងតាំងជាដៃគូសវនកម្មជាន់ខ្ពស់ (ឬក៏អាចហៅម្យ៉ាងទៀតថាដៃគូសវនកម្មប្រតិបត្តិ) នៅក្នុងខែតុលា ឆ្នាំ2000 រហូតដល់ថ្ងៃទី30 ខែកញ្ញា ឆ្នាំ2007។

លោកបានចូលនិវត្តពីក្រុមហ៊ុននៅថ្ងៃទី31 ខែធ្នូ ឆ្នាំ2007។ លោកមានបទពិសោធន៍ផ្នែកសនវកម្ម ពន្ធដារ និងការអនុវត្តសោធនភាព និងធ្លាប់បម្រើការងារនៅក្នុងប្រទេសម៉ាឡេស៊ី និងចក្រភពអង់គ្លេស បទពិសោធន៍របស់លោក រួមមានការផ្លាស់ប្តូររចនាសម្ព័ន្ធក្រុមហ៊ុន បំបែកក្រុមហ៊ុន និងឯកជនភាវូបនីយកម្មក្រុមហ៊ុន។

ភាពជាអភិបាលរបស់លោកនៅក្នុងក្រុមហ៊ុនផ្សេងៗក្នុងសម្ព័ន្ធធនាគាសាធារណៈ មានដូចជា ក្រុមហ៊ុន មូលបត្រ កម្ពុ ម.ក Public Mutual Bhd, Public Consolidated Holdings Sdn Bhd, Public Financial Holdings Ltd, Public Finance Ltd, ក្រុមហ៊ុនធានារ៉ាប់រងកម្ពុ ឡុនប៉ាក ភីអិលស៊ី, Public Bank Lao Limited និងក្រុមហ៊ុនបុត្រសម្ព័ន្ធផ្សេងទៀតរបស់ធនាគារសាធារណៈ។ ភាពជាអភិបាលរបស់លោកនៅក្នុងក្រុមហ៊ុនមហាជនផ្សេងៗ ដែលបានចុះបញ្ជីនៅលើទីផ្សារមូលបត្រម៉ាឡេស៊ីធំៗដែលក្នុងនោះរួមមានក្រុមហ៊ុន Kuala Lumpur Kepong Berhad, Paramount Corporation Berhad, Malayan Flour Mills Berhad និង On-Going Holdings Sdn Bhd។

### បណ្ឌិត ផៃ ទូច
### អភិបាលមិនប្រតិបត្តិឯករាជ្យ

បណ្ឌិត ផៃ ទូច អាយុ 56 ឆ្នាំ ត្រូវបានតែងតាំងជាអភិបាលមិនប្រតិបត្តិឯករាជ្យរបស់ធនាគារកម្ពុជាសាធារណៈ ភីអិលស៊ី នៅថ្ងៃទី25 ខែមេសា ឆ្នាំ2023។

បណ្ឌិត ផៃ ទូច បានបញ្ចប់បរិញ្ញាបត្រថ្នាក់បណ្ឌិតរដ្ឋបាលអាជីវកម្មពីសាកលវិទ្យាល័យ North Borneo University College Malaysia និង European University (European Business School) Switzerland។ លោកក៏បានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគណនេយ្យពីសាកលវិទ្យាល័យ Maharishi University of Managment សហរដ្ឋអាមេរិក និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកហិរញ្ញវត្ថុពីសាកលវិទ្យាល័យ Charles Sturt University ប្រទេសអូស្ត្រាលី។

# ប្រវត្តិរូបរបស់ក្រុមប្រឹក្សាភិបាល

បណ្ឌិត ផៃ ទូច គឺជាសមាជិកភាពនៃ Institute of Public Accountants ប្រទេសអូស្ត្រាលី Institute of Financial Accountants ចក្រភពអង់គ្លេស និងជាសមាជិកនៃ Chartered Institute for Securities and Investment ចក្រភពអង់គ្លេស។ លោកក៏ជាសមាជិកជំនាញនៃ Institute of Internal Auditors ប្រទេសម៉ាឡេស៊ី និងជាអភិបាលនៃគណៈកម្មាធិការជំនាញសវនកម្មនៃ Institute of Internal Auditors ប្រទេសម៉ាឡេស៊ី។

បណ្ឌិត ផៃ ទូច មានបទពិសោធន៍ជាង 30 ឆ្នាំ ផ្នែកឧស្សាហកម្ម/ធុរកិច្ចនៅជាង 20 ស្ថាប័នផ្សេងគ្នា ទាំងវិស័យឯកជន និងមិនមែនឯកជន និងមានបទពិសោធន៍ជាអភិបាលរយៈពេល 16 ឆ្នាំ នៅតាមបណ្តាក្រុមហ៊ុន/គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួននៅក្នុងប្រទេសកម្ពុជា មុនពេលលោកត្រូវបានតែងតាំងជាអភិបាលមិនប្រតិបត្តិឯករាជ្យនៅធនាគារកម្ពុជាសាធារណៈ ភីអិលស៊ី។ លោកមានបទពិសោធន៍ផ្នែកធនាគារ និងហិរញ្ញវត្ថុ ក្នុងនោះរួមមានសវនកម្ម។

ភាពជាអភិបាលរបស់លោកនៅក្នុងក្រុមហ៊ុនផ្សេងៗក្នុងសម្ព័ន្ធធនាគារសាធារណៈ មានដូចជាក្រុមហ៊ុន ធានារ៉ាប់រង កម្ពុ ឡូនប៉ាក ភីអិលស៊ី។

លោក Ong Ming Teck

**អភិបាលប្រតិបត្តិ**

លោក Ong Ming Teck អាយុ 62 ឆ្នាំ ត្រូវបានតែងតាំងជាអភិបាលប្រតិបត្តិនៃធនាគារកម្ពុជាសាធារណៈ ភីអិលស៊ី នៅថ្ងៃទី26 ខែមេសា ឆ្នាំ2021។

លោក Ong Ming Teck បានបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកអាជីវកម្ម (រដ្ឋបាលអាជីវកម្ម), AMIM, DBFS និង CCP។ លោកបានចូលបម្រើការងារនៅសម្ព័ន្ធធនាគារសាធារណៈរយៈពេល 41 ឆ្នាំ។ លោកកាន់មុខតំណែង សំខាន់ៗជាច្រើននៅធនាគារសាធារណៈ មុនពេលលោកត្រូវបានតែងតាំងជាអគ្គនាយករងនៃធនាគារកម្ពុនៅថ្ងៃទី10 ខែកក្កដា ឆ្នាំ2008។ លោកត្រូវបានតែងតាំងជានាយកប្រតិបត្តិនៃធនាគារកម្ពុចាប់ពីថ្ងៃទី11 ខែមករា ឆ្នាំ2021។

ភាពជាអភិបាលរបស់លោកនៅក្នុងក្រុមហ៊ុនផ្សេងៗក្នុងសម្ព័ន្ធធនាគារសាធារណៈ រួមមានក្រុមហ៊ុន មូលបត្រ កម្ពុ ម.ក ក្រុមហ៊ុនធានារ៉ាប់រង កម្ពុ ឡូនប៉ាក ភីអិលស៊ី និងក្រុមហ៊ុន ស៊ីភីប៊ី ប្រូភ័រធី ខូ អិលធីឌី។ បច្ចុប្បន្ន លោកគឺជាសមាជិកក្រុមប្រឹក្សាសមាគមធនាគារនៅកម្ពុជាក្នុងរយៈពេលពីរអាណត្តិជាប់ៗគ្នាចាប់ពីឆ្នាំ2022-2025។



DATO' MOHAMMED NAJEEB BIN ABDULLAH | ប្រធានក្រុមប្រឹក្សាភិបាល

# របាយការណ៍របស់ ប្រធានក្រុមប្រឹក្សាភិបាល

# របាយការណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល

ឆ្នាំ2024 អាចពិពណ៌នាបានថាជាឆ្នាំមួយនៃការអភិវឌ្ឍន៍ប្រកបដោយភាពប្រុងប្រយ័ត្ន និងការធ្វើបរិវត្តកម្មប្រកបដោយអត្ថន័យសម្រាប់ព្រះរាជាណាចក្រកម្ពុជា។ ខណៈដែលសេដ្ឋកិច្ចនៅទូទាំងសកលលោកនៅមិនទាន់មានស្ថិរភាព ដោយសារភាពមិនប្រាកដប្រជាបានបន្តអូសបន្លាយ បើទោះបីជាមានការបន្ធូរបន្ថយគោលនយោបាយរូបិយវត្ថុនៅតាមបណ្តាប្រទេសមួយចំនួនដោយសារអតិផរណាមានកម្រិតមធ្យម។

ស្ថិតក្នុងបរិយាសកាសដែលមានបញ្ហាប្រឈមនេះ សេដ្ឋកិច្ចកម្ពុជាបានបង្ហាញភាពធន់ កំណើនថេរ ដែលត្រូវបានទ្រទ្រង់ដោយការប្រើប្រាស់ក្នុងស្រុក ការងើបឡើងវិញនៃវិស័យទេសចរណ៍ និងពង្រឹងសមិទ្ធិផលនាំចេញ។ វិស័យកាត់ដេរផលិតផលស្បែកជើង និងផលិតផលធ្វើដំណើរ រួមជាមួយវិស័យកសិកម្ម និងសេវាកម្មបានដើរតួនាទីយ៉ាងសំខាន់ក្នុងការទ្រទ្រង់កម្លាំងចលករសេដ្ឋកិច្ចក្នុងប្រទេស។

ព្រះរាណាចក្រកម្ពុជាក៏បានចាប់ផ្តើមទាក់ទាញចំណាប់អារម្មណ៍យ៉ាងខ្លាំងពីវិនិយោគិនបរទេស ជាពិសេសទៅលើផ្នែកមួយចំនួនដូចជា វិស័យថាមពលកកើតឡើងវិញ ការកែច្នៃកសិកម្ម និងឧស្សាហកម្មស្រាល។ កិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់របស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈយុទ្ធសាស្រ្តបញ្ចកោណ ដំណាក់កាលទី 1 និងគំនិតផ្តួចផ្តើមលើកកម្ពស់បរិវត្តកម្មឌីជីថល និងការធ្វើពិពិធកម្មឧស្សាហកម្មកំពុងពង្រឹងការប្រកួតប្រជែង និងការអភិវឌ្ឍន៍ប្រកបដោយចីរភាពរយៈពេលវែងរបស់ប្រទេសជាតិ។

ដោយមានវិស័យហិរញ្ញវត្ថុដ៏មានស្ថិរភាពជាមូលដ្ឋានគ្រឹះ ប្រព័ន្ធធនាគារកម្ពុជានៅតែជាចលករជំរុញកំណើនសេដ្ឋកិច្ចដ៏សំខាន់ដោយធានាបាននូវធនធាន និងការគាំទ្រគោលដៅអភិវឌ្ឍប្រទេសជាតិដ៏មានប្រសិទ្ធភាព។

### ការលើកកម្ពស់និរន្តរភាពបរិស្ថាន សង្គម និងអភិបាលកិច្ច

បញ្ហាប្រឈមជាបន្តបន្ទាប់នៅទូទាំងសាកលលោក និងការវិវត្តបរិយាកាសធុរកិច្ចយ៉ាងឆាប់រហ័សបានស្តែងឱ្យឃើញភាពធន់នៃអាជីវកម្ម។ ក្នុងទិដ្ឋភាពនៃការប្រែប្រួលយ៉ាងឆាប់រហ័សនេះ និរន្តរភាពបរិស្ថាន សង្គម និងអភិបាលកិច្ចបានក្លាយជាចលករជំរុញកំណើន និងស្ថិរភាពរយៈពេលវែង។

ប្រធានបទនៃរបាយការណ៍ប្រចាំឆ្នាំ2024 "ការលើកកម្ពស់និរន្តរភាពបរិស្ថាន សង្គម និងអភិបាលកិច្ច" គឺទាន់ពេលវេលាដែលឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តដ៏មោះមុតដើម្បីកំណើន និងការអភិវឌ្ឍន៍ប្រកបដោយការទទួលខុសត្រូវ។

ធនាគារកម្ពុនៅតែបន្តការប្តេជ្ញាចិត្តបង្កើតផលប៉ះពាល់ជាវិជ្ជមានលើបរិស្ថាន និងសហគមន៍ដែលធនាគារកំពុងធ្វើប្រតិបត្តិការ។ ការណ៍នេះសម្រេចទៅបាន តាមរយៈការបញ្ជ្រាបទៅក្នុងការអនុវត្តន៍ប្រកបដោយចីរភាពទៅក្នុងម៉ូឌែលធុរកិច្ចក្នុងការផ្តល់ជូននូវគុណតម្លៃរយៈពេលវែងដល់អ្នកពាក់ព័ន្ធ តាមរយៈការផ្តល់ត្រឡប់ជាប្រចាំដល់ម្ចាស់ភាគទុនិក សេវាអតិថិជនល្អឥតខ្ចោះ សុខុមាលភាពបុគ្គលិក និងការចូលរួមចំណែកទៅលើការអភិវឌ្ឍន៍សហគមន៍។

តាមរយៈការផ្តល់អាទិភាពលើនិរន្តរភាពបរិស្ថាន សង្គម និងអភិបាលកិច្ច ធនាគារកម្ពុកំពុងរួមបញ្ចូលប្រតិបត្តិការរបស់ខ្លួនដោយធានាផ្តល់នូវគុណតម្លៃ ស្របតាមគោលដៅធុរកិច្ចរបស់ខ្លួន និងអាទិភាពអភិវឌ្ឍប្រកបដោយចីរភាពរបស់កម្ពុជា។

### ចលករទ្រទ្រង់កំណើន

ក្នុងឆ្នាំ2024 ធនាគារកម្ពុសម្រេចបាននូវលទ្ធផលហិរញ្ញវត្ថុដ៏រឹងមាំមួយផ្សេងទៀត ជាមួយប្រាក់ចំណូលមុនចំណាយពន្ធកើនឡើងចំនួន 8.95% ស្មើនឹង 80.63 លានដុល្លារអាមេរិក។

# របាយការណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល

## ចលករទ្រទ្រង់កំណើន (តពីទំព័រមុន)

លទ្ធផលដ៏ល្អឥតខ្ចោះនេះត្រូវទ្រទ្រង់ដោយប្រសិទ្ធភាពថ្លៃដើម និងការគ្រប់គ្រងទ្រព្យសកម្មប្រកបដោយភាពប្រុងប្រយ័ត្ន របស់ធនាគារកម្ពុ ដែលឆ្លុះបញ្ចាំងឱ្យឃើញពីការប្តេជ្ញាចិត្តដើម្បីស្ថេរភាពហិរញ្ញវត្ថុ និងកំណើនប្រកបដោយចីរភាព។

ធនាគារកម្ពុបន្តសហការជាមួយក្រុមហ៊ុនអភិវឌ្ឍលំនៅដ្ឋាន ដែលមានតម្លៃសមរម្យ ដើម្បីគាំទ្រគម្រោងកម្មសិទ្ធិលំនៅដ្ឋាន ក្នុងចំណោមអតិថិជនដែលមានប្រាក់ចំណូលទាបទៅមធ្យម ដោយចំនួនហិរញ្ញប្បទានដែលបានអនុម័តសម្រាប់លំនៅដ្ឋាន មានតម្លៃសមរម្យមានចំនួន 10.9 លានដុល្លារអាមេរិក គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2024។

ដោយមានកំណើនប្រាក់ចំណូលថេរ ធនាគារកម្ពុបានបន្តអនុវត្តប្រពៃណីផ្តល់គុណតម្លៃសេវាកម្មរបស់ខ្លួនដល់អតិថិជន តាមរយៈការច្នៃនវានុវត្តន៍ផលិតផល និងសេវាកម្មថ្មីៗ ដើម្បីឆ្លើយតបតាមតម្រូវការរបស់អតិថិជន។

## យុទ្ធសាស្ត្រអាជីវកម្ម

ដើម្បីអតិថិជនរបស់ខ្លួន ធនាគារកម្ពុកំពុងបន្តអភិវឌ្ឍឆ្ពោះទៅរកបរិវត្តកម្មឌីជីថល និងផ្តល់ជូនសេវាកម្មល្អបំផុត ហើយខិតខំប្រឹងប្រែងផ្តល់តម្លៃសេវាកាន់តែប្រសើរ យកចិត្តទុកដាក់លើមតិយោបល់របស់អតិថិជន និងព្យាយាមឆ្លើយតបទៅនឹងតម្រូវការរបស់អតិថិជនភ្លាមៗ។ ធនាគារកម្ពុបន្តកែលម្អលក្ខណៈពិសេសនៃផលិតផល និងសេវាកម្មរបស់ខ្លួន ដើម្បីស្របទៅតាមតម្រូវការគ្រប់ប្រភេទរបស់អតិថិជន និងជំរុញនវានុវត្តន៍ដើម្បផ្តល់ភាពងាយស្រួល និងប្រសិទ្ធភាពកាន់តែប្រសើរសម្រាប់តម្រូវការប្រតិបត្តិការធនាគាររបស់អតិថិជន។ សមត្ថភាពក្នុងការព្យាករណ៍តម្រូវការអតិថិជន និងការឆ្លើយតបតាមតម្រូវការលើសពីការរំពឹងទុករបស់អតិថិជនបាននឹងបន្តសម្រួចទម្រង់ស្តង់ដាសេវាកម្មរបស់ធនាគារកម្ពុ ឈានដល់កម្រិតខ្ពស់នាពេលបច្ចុប្បន្ន។

លើសពីនេះទៅទៀត ដើម្បីពង្រឹងសមត្ថភាពរបស់ខ្លួនក្នុងការជំរុញកំណើនអាជីវកម្ម ធនាគារកម្ពុបានបន្តពង្រឹងយុទ្ធសាស្ត្រផ្តោតលើការអភិវឌ្ឍន៍ធនធានមនុស្ស និងបរិវត្តកម្មឌីជីថល។

## ទស្សនៈវិស័យវិជ្ជមានសម្រាប់ឆ្នាំ2025

គាំទ្រដោយកិច្ចខិតខំប្រឹងប្រែងដ៏មោះមុតរបស់រាជរដ្ឋាភិបាលកម្ពុជា និងធនាគារជាតិនៃកម្ពុជាក្នុងការស្តារសេដ្ឋកិច្ច ស្របតាមមូលដ្ឋានគ្រឹះសេដ្ឋកិច្ចដ៏រឹងមាំរបស់ប្រទេស កំណើនសេដ្ឋកិច្ចជាវិជ្ជមានត្រូវបានរំពឹងទុកថានឹងបន្តកើនឡើងក្នុងឆ្នាំ2025 និងឆ្នាំខាងមុខ។

ធនាគារកម្ពុនឹងបន្តធ្វើមូលធនកម្មលើវត្តមានទីផ្សារដ៏រឹងមាំ និងបណ្តាញផ្តល់សេវាកម្មដ៏ទូលំទូលាយរបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងកំណើនតម្រូវការសេវាធនាគារដែលមានគុណភាពនៅទូទាំងប្រទេស។

នៅក្នុងពេលដំណាលគ្នានេះដែរ ធនាគារកម្ពុនៅតែប្តេជ្ញាចិត្តពង្រីកកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការបន្តដើរតួនាទីយ៉ាងសកម្មក្នុងនាមជាក្រុមហ៊ុនសាជីវកម្ម ដែលមានការទទួលខុសត្រូវក្នុងដំណើររបស់ព្រះរាជាណាចក្រកម្ពុជាឆ្ពោះទៅរកការអភិវឌ្ឍន៍ប្រកបដោយបរិយាបន្ន និងចីរភាព។

# របាយការណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល

## សេចក្តីថ្លែងអំណរគុណ

ធនាគារកម្ពុសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការបន្តគាំទ្រ ទំនុកចិត្ត និងភាពជឿជាក់របស់អតិថិជន ព្រមទាំងគណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់ដែលខិតខំប្រឹងប្រែង និងលះបង់ដើម្បីសម្រេចបាននូវសមិទ្ធផលដ៏ល្អរបស់ធនាគារកម្ពុ។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ធនាគារជាតិនៃកម្ពុជា និងគ្រប់អាជ្ញាធរពាក់ព័ន្ធទាំងអស់ចំពោះការណែនាំ និងគាំទ្រមិនអាចកាត់ថ្លៃបាន។

ដំណើររបស់ធនាគារកម្ពុនៅក្នុងព្រះរាជាណាចក្រកម្ពុជា គឺជាដំណើរមួយដែលមានកំណើនថេរ និងចីរភាព បើទោះបីជាបរិយាកាសធុរកិច្ចពោរពេញទៅដោយបញ្ហាប្រឈម។ ភាពជោគជ័យនេះត្រូវបានកសាងលើមូលដ្ឋានគ្រឹះនៃការអនុវត្តប្រតិបត្តិការធនាគារប្រកបដោយភាពប្រុងប្រយ័ត្ន សេវាអតិថិជនមានប្រសិទ្ធភាព អភិបាលកិច្ចក្រុមហ៊ុនរឹងមាំ និងកំណត់ត្រាដ៏ល្អឥតខ្ចោះដែលត្រូវបានចម្រាញ់ និងពង្រឹងគ្រប់ពេល។

ធនាគារកម្ពុនៅតែរក្សាការប្តេជ្ញាចិត្តគ្រប់គ្រងទំនុកចិត្ត និងសុចរិតភាពជាមួយភាគីពាក់ព័ន្ធ ខណៈពេលកំពុងបន្តអនុវត្ត និងធ្វើនវានុវត្តន៍ ដើម្បីរក្សាការផ្សារភ្ជាប់ និងការឆ្លើយតបទៅនឹងតម្រូវការប្រជាជនខ្មែរ។

ខណៈពេលសំឡឹងមើលទៅអនាគត យើងខ្ញុំសូមបញ្ជាក់ការប្តេជ្ញាចិត្តយ៉ាងពេញទំហឹងដើម្បីនិរន្តរភាព ដោយរក្សាការប្តជ្ញាចិត្តនេះជាផ្នែកសំខាន់មួយនៃមាគ៌ាឆ្ពោះទៅមុខរបស់ធនាគារកម្ពុក្នុងព្រះរាជាណាចក្រកម្ពុជា។

Dato' Mohammed Najeeb bin Abdullah

**ប្រធានក្រុមប្រឹក្សាភិបាល**

# ទិដ្ឋភាពទូទៅនៃអភិបាលកិច្ចក្រុមហ៊ុន

## ការទទួលខុសត្រូវសំខាន់ៗរបស់ក្រុមប្រឹក្សាភិបាល

ការទទួលខុសត្រូវសំខាន់ៗរបស់ក្រុមប្រឹក្សាភិបាលមានដូចខាងក្រោម៖

- បង្កើតផែនការអាជីវកម្ម និងផែនការសកម្មភាពរបស់ធនាគារកម្ពុ ជាប្រចាំឆ្នាំដើម្បីកំណត់ចំណុចសំខាន់ៗនៃអាជីវកម្មរបស់ធនាគារកម្ពុស្របតាមបរិយាកាសសេដ្ឋកិច្ច និងទីផ្សារ។
- អនុម័តថវិកាប្រចាំឆ្នាំ និងពិនិត្យផែនការសកម្មភាពដែលអនុវត្តដោយគណៈគ្រប់គ្រងដើម្បីសម្រេចគោលដៅអាជីវកម្ម។
- បង្កើតយុទ្ធសាស្ត្រ និងគោលនយោបាយសំខាន់ៗពាក់ព័ន្ធនឹងប្រតិបត្តិការអាជីវកម្មរបស់ធនាគារកម្ពុ។
- ពិនិត្យ និងតាមដានលទ្ធផលរបស់គណៈគ្រប់គ្រងក្នុងការអនុវត្តយុទ្ធសាស្ត្រ ផែនការ គោលដៅ និងគោលនយោបាយអាជីវកម្មដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល។
- ពិនិត្យប្រតិបត្តិការ និងលទ្ធផលអាជីវកម្មរបស់ធនាគារជាប្រចាំតាមរយៈការពិនិត្យរបាយការណ៍របស់គណៈគ្រប់គ្រងស្តីពីវឌ្ឍនភាពប្រតិបត្តិការអាជីវកម្ម។
- ពិនិត្យ និងអនុម័តរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារកម្ពុ។
- បង្កើតស្តង់ដារអប្បរមា និងគោលនយោបាយលើការគ្រប់គ្រងហានិភ័យឥណទាន និងផ្នែកសំខាន់ផ្សេងៗនៃប្រតិបត្តិការរបស់ធនាគារកម្ពុ។
- ធានាថាហេដ្ឋារចនាសម្ព័ន្ធ ដំណើរការត្រួតពិនិត្យផ្ទៃក្នុង និងការគ្រប់គ្រងហានិភ័យមានប្រសិទ្ធភាពក្នុងការវាយតម្លៃ និងគ្រប់គ្រងហានិភ័យអាជីវកម្ម ហានិភ័យប្រតិបត្តិការ ហានិភ័យឥណទាន ហានិភ័យទីផ្សារ និងហានិភ័យសន្ទនីយភាព និងធានាថាដំណើរការត្រួតពិនិត្យ និងគ្រប់គ្រងត្រូវបានអនុវត្តប្រកបដោយសង្គតិភាព។
- អនុវត្តមុខងារ និងការទទួលខុសត្រូវផ្សេងៗ ដូចមានចែងក្នុងសេចក្តីណែនាំ និងសារាចរណែនាំរបស់ធនាគារជាតិនៃកម្ពុជាពីពេលមួយទៅពេលមួយ។

## គណៈកម្មការឯកទេស

ក្រុមប្រឹក្សាភិបាលបង្កើតគណៈកម្មការកម្រិតក្រុមប្រឹក្សាភិបាលដែលមានដូចខាងក្រោម ស្របតាមប្រកាសស្តីពីអភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ៖

- គណៈកម្មការសវនកម្ម
- គណៈកម្មការគ្រប់គ្រងហានិភ័យ
- គណៈកម្មការតែងតាំង និងផ្តល់តម្លៃការ

សមាសភាពរបស់គណៈកម្មការសវនកម្ម គណៈកម្មការគ្រប់គ្រងហានិភ័យ និងគណៈកម្មការតែងតាំង និងផ្តល់តម្លៃការរួមមាន Dato' Mohammed Najeeb bin Abdullah បណ្ឌិត ផៃ ទូច និងលោក Quah Poh Keat។

# និដ្ឋភាពទូទៅនៃអភិបាលកិច្ចក្រុមហ៊ុន

## កិច្ចប្រជុំក្រុមប្រឹក្សាភិបាល និងការទទួលបានព័ត៌មាន

កិច្ចប្រជុំក្រុមប្រឹក្សាភិបាលត្រូវបានរៀបចំយ៉ាងតិច 4 ដងក្នុងមួយឆ្នាំ។ របាយការណ៍លើដំណើរការរីកចម្រើននៃប្រតិបត្តិការអាជីវកម្មត្រូវបានរៀបចំឡើងដោយគណៈគ្រប់គ្រងរបស់ធនាគារ ហើយដាក់ជូនសមាជិកក្រុមប្រឹក្សាភិបាលដើម្បីធ្វើការពិនិត្យ។ ក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល សមាជិកនៃក្រុមប្រឹក្សាភិបាលក៏ធ្វើការវាយតម្លៃលើសំណើអាជីវកម្មដែលតម្រូវឱ្យមានការយល់ព្រមពីក្រុមប្រឹក្សាភិបាល ដោយយោងទៅតាមលក្ខខណ្ឌតម្រូវនៃច្បាប់ ឬឥទ្ធិពលផ្នែកហិរញ្ញវត្ថុលើធនាគារ។

របៀបវារៈសម្រាប់រាល់កិច្ចប្រជុំក្រុមប្រឹក្សាភិបាល ព្រមទាំងរបាយការណ៍គណៈគ្រប់គ្រងលម្អិត លិខិតស្នើសុំ និងឯកសារពាក់ព័ន្ធផ្សេងៗទៀតត្រូវបានផ្តល់ជូនដល់អភិបាលទាំងអស់ពិនិត្យមុនពេលប្រជុំក្រុមប្រឹក្សាភិបាល ដើម្បីឱ្យអភិបាលមានពេលគ្រប់គ្រាន់ក្នុងការត្រួតពិនិត្យនូវរាល់គម្រោងទាំងអស់ដែលនឹងពិភាក្សានៅក្នុងកិច្ចប្រជុំ និងជាជំនួយដល់ការសម្រេចចិត្តរបស់អភិបាលទាំងអស់ផងដែរ។

រាល់កំណត់ហេតុនៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាលត្រូវបានចែកជូនដល់គ្រប់អភិបាលទាំងអស់ ដើម្បីធ្វើការត្រួតពិនិត្យមុននឹងបញ្ជាក់ភាពត្រឹមត្រូវនៃកំណត់ហេតុក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកក្រោយ។

អភិបាលទាំងអស់ត្រូវបានជូនដំណឹងជាទៀងទាត់តាមរយៈលេខាធិការក្រុមប្រឹក្សាភិបាលស្តីពីច្បាប់ថ្មីៗ ព្រមទាំងលិខិតបទដ្ឋាននានាដែលទាក់ទងទៅនឹងតួនាទី និងការទទួលខុសត្រូវរបស់អភិបាល រួមបញ្ចូលទាំងគោលការណ៍ណែនាំដែលចេញដោយធនាគារជាតិនៃកម្ពុជាពាក់ព័ន្ធនឹងធនាគារកម្ពុជាសាធារណៈ។ សមាជិកក្រុមប្រឹក្សាភិបាលទាំងអស់អាចទទួលបាននូវសេចក្តីជូនដំណឹង និងសេវាកម្មផ្សេងៗដែលបានត្រៀមជាស្រេចពីលេខាធិការដោយពុំមានការកំណត់។ អភិបាលទាំងអស់មានសេរីភាពក្នុងការស្វែងរកការប្រឹក្សាពីខាងក្រៅប្រសិនបើអភិបាលមានតម្រូវការ។

## ការត្រួតពិនិត្យផ្ទៃក្នុង

### ការទទួលខុសត្រូវ

ក្រុមប្រឹក្សាភិបាលនៃធនាគារកម្ពុទទួលខុសត្រូវចំពោះភាពគ្រប់គ្រាន់ និងប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ។ ក្រុមប្រឹក្សាភិបាលធានាឱ្យបានប្រាកដថា ប្រព័ន្ធនេះនឹងគ្រប់គ្រងផ្នែកសំខាន់ៗនៃហានិភ័យរបស់ធនាគារក្នុងកម្រិតមួយដើម្បីបង្កើនឱកាសដែលអាចសម្រេចបាននូវគោលនយោបាយ និងគោលដៅអាជីវកម្មរបស់ធនាគារ។ ក្រុមប្រឹក្សាភិបាលនៅបន្តត្រួតពិនិត្យលើប្រព័ន្ធនេះដើម្បីធានាឱ្យប្រាកដថា ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនេះផ្តល់នូវការធានាដ៏សមរម្យមួយ ប៉ុន្តែ ពុំបានធានាទាំងស្រុងចំពោះកំហុសខុសឆ្គងជាសារវ័ន្តរបស់គណៈគ្រប់គ្រង និងព័ត៌មានហិរញ្ញវត្ថុ និងការកត់ត្រា ឬចំពោះការខូចខាត ឬកេងបន្លំផ្នែកហិរញ្ញវត្ថុនោះទេ។

ក្រុមប្រឹក្សាភិបាលបានបង្កើតឡើងនូវដំណើរការបន្តបន្ទាប់ដើម្បីកំណត់អត្តសញ្ញាណវាយតម្លៃនិងគ្រប់គ្រងហានិភ័យសំខាន់ៗដែលធនាគារបានជួបប្រទះ ហើយដំណើរការនេះរួមមានការពង្រឹងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនៅពេលដែលមានការផ្លាស់ប្តូរបរិយាកាសអាជីវកម្ម ឬការផ្លាស់ប្តូរបទប្បញ្ញត្តិ។ ដំណើរការនេះត្រូវបានត្រួតពិនិត្យយ៉ាងទៀងទាត់ដោយក្រុមប្រឹក្សាភិបាល។

គណៈគ្រប់គ្រងជួយដល់ក្រុមប្រឹក្សាភិបាលក្នុងការអនុវត្តនូវគោលនយោបាយ និងនីតិវិធីរបស់ក្រុមប្រឹក្សាភិបាលទៅលើហានិភ័យ និងការត្រួតពិនិត្យដោយការកំណត់ និងវាយតម្លៃលើហានិភ័យដែលបានជួបប្រទះ និងជួយក្នុងការរៀបចំ ការធ្វើប្រតិបត្តិការ និងការតាមដាននូវការត្រួតពិនិត្យផ្ទៃក្នុងដ៏សមស្របដើម្បីសម្រាល និងគ្រប់គ្រងហានិភ័យទាំងនេះ។

# និន្នាការទូទៅនៃអភិបាលកិច្ចក្រុមហ៊ុន

ក្រុមប្រឹក្សាភិបាលពិនិត្យឃើញថា ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលបានដាក់ឱ្យអនុវត្តសម្រាប់ឆ្នាំនេះ គិតត្រឹមកាលបរិច្ឆេទនៃការចេញផ្សាយរបាយការណ៍ហិរញ្ញវត្ថុគឺមានលក្ខណៈគ្រប់គ្រាន់ និងមានប្រសិទ្ធភាពក្នុងការការពារការវិនិយោគរបស់ម្ចាស់ភាគហ៊ុន ផលប្រយោជន៍របស់អតិថិជន និយ័តករ និងនិយោជិត និងទ្រព្យសកម្មរបស់ធនាគារ ។

## ដំណើការត្រួតពិនិត្យផ្ទៃក្នុងសំខាន់ៗ

ដំណើរការសំខាន់ៗដែលត្រូវបានបង្កើតឡើងដើម្បីពិនិត្យមើលភាពគ្រប់គ្រាន់ និងប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងមានដូចខាងក្រោម៖

(i) គណៈកម្មការក្រុមប្រឹក្សាភិបាលប្រតិបត្តិរបស់ធនាគារ ត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាភិបាល ដើម្បីគ្រប់គ្រងអាជីវកម្មរបស់ធនាគារ និងដើម្បីធានាឱ្យប្រាកដថា ប្រតិបត្តិការរបស់ធនាគារគឺអនុលោមតាមគោលដៅយុទ្ធសាស្រ្ត និងថវិកាប្រចាំឆ្នាំរបស់សាជីវកម្ម ក៏ដូចជាគោលនយោបាយ និងទិសដៅអាជីវកម្មដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល។ គណៈកម្មការក្រុមប្រឹក្សាភិបាលប្រតិបត្តិអនុវត្តយុទ្ធសាស្រ្តដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល និងដោះស្រាយបញ្ហាដែលកើតឡើងដោយសារការផ្លាស់ប្តូរបរិយាកាសអាជីវកម្មខាងក្រៅ និងលក្ខខណ្ឌប្រតិបត្តិការផ្ទៃក្នុង។ គណៈកម្មការថ្នាក់គ្រប់គ្រងត្រូវបានបង្កើតដើម្បីបំពេញមុខងារដែលបានចែងខាងលើ។

(ii) គណៈកម្មការសវនកម្មរបស់ធនាគារត្រួតពិនិត្យនូវបញ្ហាការគ្រប់គ្រងផ្ទៃក្នុង ដែលបានកំណត់ដោយនាយកដ្ឋានសវនកម្មផ្ទៃក្នុង សវនករឯករាជ្យ និយ័តកម្មសិទ្ធិអំណាច និងគណៈគ្រប់គ្រង និងវាយតម្លៃលើភាពគ្រប់គ្រាន់ និងប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ការគ្រប់គ្រងហានិភ័យ និងដំណើរការអភិបាលកិច្ច។ កំណត់ហេតុនៃកិច្ចប្រជុំគណៈកម្មការសវនកម្មត្រូវបានកំណត់ជារបៀបវារៈ សម្រាប់ដាក់ជូនក្រុមប្រឹក្សាភិបាលនៃធនាគារជារៀងរាល់ត្រីមាស។

(iii) គណៈកម្មការគ្រប់គ្រងហានិភ័យរបស់ធនាគារត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាភិបាល ដើម្បីជួយពិនិត្យការគ្រប់គ្រងទាំងស្រុងនៃផ្នែកសំខាន់ៗនៃហានិភ័យរបស់ធនាគារ និងត្រួតពិនិត្យការគ្រប់គ្រងផ្ទៃក្នុងដែលបានកំណត់ដោយនាយកដ្ឋានគ្រប់គ្រងហានិភ័យ និងនាយកដ្ឋានមុខងារប្រតិបត្តិតាម និងប្រឆាំងការសម្អាតប្រាក់។

(iv) នាយកដ្ឋានសវនកម្មផ្ទៃក្នុងធ្វើសវនកម្មប្រចាំគ្រាដើម្បីវាយតម្លៃភាពគ្រប់គ្រាន់ ប្រសិទ្ធភាព និងភាពត្រឹមត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងលើកឡើងនូវរបកគំហើញជាសារវ័ន្តពាក់ព័ន្ធនឹងភាពខ្វះចន្លោះ ឬភាពមិនត្រឹមត្រូវ ។ សវនកម្មត្រូវបានអនុវត្តតាមសាខា និងនាយកដ្ឋាននៅទីស្នាក់ការកណ្តាល ព្រមទាំងបុត្រសម្ព័ន្ធរបស់ធនាគារដែលមិនមានមុខងារសវនកម្មផ្ទៃក្នុងផ្ទាល់ខ្លួន ដែលចំនួនដងនៃការធ្វើសវនកម្មត្រូវបានកំណត់ដោយកម្រិតនៃហានិភ័យដែលបានវាយតម្លៃ ដើម្បីផ្តល់របាយការណ៍ដែលមានភាពឯករាជ្យ និងអព្យាក្រឹត្យភាពស្តីពីប្រតិបត្តិការ និងសកម្មភាពគ្រប់គ្រងនៅគ្រប់ទីតាំងដែលបានធ្វើសវនកម្ម។ ផែនការសវនកម្មប្រចាំឆ្នាំត្រូវបានត្រួតពិនិត្យ និងអនុម័តដោយគណៈកម្មការសវនកម្មរបស់ធនាគារហើយលទ្ធផលនៃការធ្វើសវនកម្មត្រូវដាក់ជូនគណៈកម្មការសវនកម្មរបស់ធនាគារដើម្បីពិនិត្យនៅក្នុងកិច្ចប្រជុំប្រចាំគ្រា។

(v) នាយកដ្ឋានមុខងារប្រតិបត្តិតាម និងប្រឆាំងការសម្អាតប្រាក់របស់ធនាគារធ្វើការពិនិត្យលើការអនុវត្តស្របតាមច្បាប់ បទប្បញ្ញត្តិ និងគោលការណ៍ និងនីតិវិធីផ្ទៃក្នុង ហើយលើកឡើងពីរបកគំហើញពាក់ព័ន្ធនឹងការមិនអនុវត្តតាមដាក់ជូនគណៈកម្មការគ្រប់គ្រងហានិភ័យលើមុខងារប្រតិបត្តិតាមរបស់ធនាគារសម្រាប់ពិនិត្យក្នុងកិច្ចប្រជុំប្រចាំគ្រា។

(vi) គណៈកម្មការប្រតិបត្តិការរបស់ធនាគារក៏ត្រូវបានបង្កើតឡើងជាមួយនឹងការផ្តល់សិទ្ធិសមស្រប ដើម្បីធានាប្រសិទ្ធភាពគ្រប់គ្រង និងត្រួតពិនិត្យប្រតិបត្តិការអាជីវកម្មស្នូលរបស់ធនាគារ។ គណៈកម្មការទាំងនេះរួមមាន គណៈកម្មការឥណទាន និងគណៈកម្មការដឹកនាំព័ត៌មានវិទ្យារបស់ធនាគារកម្ពុ និងគណៈកម្មការធនធានមនុស្សនៃសម្ព័ន្ធធនាគារសាធារណៈ។

# ទិដ្ឋភាពទូទៅនៃអភិបាលកិច្ចក្រុមហ៊ុន

(vii) ផែនការអាជីវកម្មប្រចាំឆ្នាំ និងថវិកាប្រចាំឆ្នាំរបស់ធនាគារត្រូវបានត្រួតពិនិត្យ និងអនុម័តដោយក្រុមប្រឹក្សាភិបាល។ លទ្ធផលប្រតិបត្តិការរបស់ធនាគារត្រូវបានវាយតម្លៃ ផ្ទៀងផ្ទាត់ជាមួយនឹងថវិកាដែលបានអនុម័ត និងសេចក្តីពន្យល់ចំពោះភាពខុសគ្នាជាសារវ័ន្តត្រូវបានផ្តល់ជូនក្រុមប្រឹក្សាភិបាលរៀងរាល់ត្រីមាស។

(viii) សេចក្តីណែនាំរបស់ធនាគារសម្រាប់ការជ្រើសរើស និងបញ្ឈប់បុគ្គលិក កម្មវិធីបណ្តុះបណ្តាលជាផ្លូវការសម្រាប់បុគ្គលិក និងការវាយតម្លៃប្រចាំឆមាស ឬប្រចាំឆ្នាំ ដើម្បីលើកកម្ពស់កម្រិតសមត្ថភាពរបស់បុគ្គលិកក្នុងការអនុវត្តកាតព្វកិច្ច និងការទទួលខុសត្រូវ។

(ix) ក្រុមប្រឹក្សាភិបាលទទួល និងត្រួតពិនិត្យរបាយការណ៍ពីគណៈគ្រប់គ្រងយ៉ាងទៀងទាត់ ។ របាយការណ៍ព័ត៌មានទាំងនេះរួមមាន របាយការណ៍គណនេយ្យនិងហិរញ្ញវត្ថុ របាយការណ៍ស្តីពីការត្រួតពិនិត្យលើការអនុវត្តស្របតាមច្បាប់ធនាគារ និងសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា ស្តីពីការផ្តល់កម្ចី ភាពគ្រប់គ្រាន់នៃដើមទុន និងលក្ខខណ្ឌតម្រូវនៃបទប្បញ្ញត្តិផ្សេងៗទៀត របាយការណ៍ប្រចាំគ្រាស្តីពីប្រតិបត្តិការអាជីវកម្មដែលត្រូវបានកំណត់ជារបៀបវារៈនៅកិច្ចប្រជុំក្រុមប្រឹក្សាភិបាលប្រចាំត្រីមាស។

(x) គោលនយោបាយ និងការកម្រិតសិទ្ធិអំណាចត្រូវបានតម្រូវឱ្យអនុវត្តដោយគណៈគ្រប់គ្រងនៅក្នុងធនាគារលើសកម្មភាពទាក់ទងនឹងប្រតិបត្តិការហិរញ្ញវត្ថុ និងសេវាកម្មធនាគារប្រចាំថ្ងៃ ការបន្ថែមកម្រិតឥណទាន ការវិនិយោគ ការទិញ និងការលក់ទ្រព្យសកម្ម។

(xi) គោលនយោបាយ និងនីតិវិធីដើម្បីធានាការអនុវត្តស្របតាមការត្រួតពិនិត្យផ្ទៃក្នុងនិងច្បាប់ និងបទបញ្ញត្តិដែលពាក់ព័ន្ធត្រូវបានចែងនៅក្នុងសៀវភៅណែនាំអំពីប្រតិបត្តិការ សេចក្តីណែនាំ និងបង្គាប់ការចេញផ្សាយដោយធនាគារដែលត្រូវបានធ្វើបច្ចុប្បន្នភាពពីពេលមួយទៅពេលមួយ។

## ការគ្រប់គ្រងហានិភ័យ

### សេចក្តីផ្តើម

ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវរួមចំពោះការគ្រប់គ្រងហានិភ័យរបស់ធនាគារ។ ធនាគារនឹងបន្តយកចិត្តទុកដាក់លើការពង្រឹងការគ្រប់គ្រងហានិភ័យ ហេដ្ឋារចនាសម្ព័ន្ធ និងសមត្ថភាពគ្រប់គ្រងរបស់ខ្លួន ក្នុងក្របខណ្ឌគ្រប់គ្រងហានិភ័យសហគ្រាសពេញលេញ ដោយមិនត្រឹមតែអនុលោមទៅតាមច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងកែលម្អសកម្មភាពប្រតិបត្តិការ និងសកម្មភាពហិរញ្ញវត្ថុ ព្រមទាំងធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពដើមទុនផងដែរ។

### គណៈកម្មការគ្រប់គ្រងហានិភ័យ

ធនាគារកម្ពុបានបង្កើតគណៈកម្មការគ្រប់គ្រងហានិភ័យ ដើម្បីជួយសម្រួលក្រុមប្រឹក្សាភិបាលក្នុងការគ្រប់គ្រងហានិភ័យសំខាន់ៗ ដោយក្នុងនោះរួមមានការត្រួតពិនិត្យក្របខណ្ឌ និងគោលនយោបាយគ្រប់គ្រងហានិភ័យ កម្រិតគ្រប់គ្រងហានិភ័យផលប៉ះពាល់និងធាតុផ្សំនៃប្រភេទហានិភ័យព្រមទាំងធានាឱ្យបានហេដ្ឋារចនាសម្ព័ន្ធធនធាននិងប្រព័ន្ធត្រូវបានរៀបចំសម្រាប់ការគ្រប់គ្រងលើការត្រួតពិនិត្យហានិភ័យប្រកបដោយប្រសិទ្ធភាព។

### គណៈកម្មការគ្រប់គ្រងទ្រព្យសកម្ម និងបំណុល

ធនាគារកម្ពុបានបង្កើតគណៈកម្មការគ្រប់គ្រងទ្រព្យសកម្ម និងបំណុលដើម្បីបង្កើតក្របខណ្ឌ និងកំណត់គោលដៅសម្រាប់មុខងារគ្រប់គ្រងទ្រព្យសកម្ម និងបំណុល។

គណៈកម្មការនេះក៏បង្កើតផងដែរនូវដំណើរការ នីតិវិធី និងវិធានការគ្រប់គ្រងផ្ទៃក្នុងដើម្បីគ្រប់គ្រងហានិភ័យទីផ្សារ ហានិភ័យសន្ទនីយភាព និងហានិភ័យមូលនិធិ។

# និដ្ឋភាពទូទៅនៃអភិបាលកិច្ចក្រុមហ៊ុន

### ក្រុមការងារគ្រប់គ្រងហានិភ័យប្រតិបត្តិការ

ធនាគារកម្ពុបានបង្កើតក្រុមការងារគ្រប់គ្រងហានិភ័យប្រតិបត្តិការ ដើម្បីជួយគណៈកម្មការគ្រប់គ្រងហានិភ័យក្នុងការគ្រប់គ្រងហានិភ័យប្រតិបត្តិការរបស់ខ្លួន។ ក្រុមការងារនេះត្រូវបានបង្កើតដើម្បីផ្តល់ជាវេទិការមួយសម្រាប់ការពិភាក្សាលម្អិតអំពីការប្រឈមទៅនឹងហានិភ័យប្រតិបត្តិការ និងបញ្ហាជាក់លាក់សម្រាប់ផ្នែកអាជីវកម្ម និងផ្នែកទ្រទ្រង់របស់ធនាគារកម្ពុ និងបញ្ជូនបញ្ហាហានិភ័យប្រតិបត្តិការសំខាន់ៗ និងយុទ្ធសាស្ត្រគ្រប់គ្រងជូនគណៈកម្មការគ្រប់គ្រងហានិភ័យ ដើម្បីសម្របសម្រួលដល់ការវាយតម្លៃការប្រឈមទៅនឹងហានិភ័យប្រតិបត្តិការទូទៅរបស់ធនាគារ ដោយក្នុងនោះរួមមានការវាយតម្លៃពីប្រសិទ្ធភាពនៃការត្រួតពិនិត្យ ដើម្បីគ្រប់គ្រងហានិភ័យប្រតិបត្តិការដែលបានកំណត់។ ក្រុមការងារនេះក៏ត្រូវពិនិត្យទៅលើការអនុវត្តក្របខណ្ឌគ្រប់គ្រងហានិភ័យប្រតិបត្តិការ និងគោលនយោបាយដែលពាក់ព័ន្ធនឹងហានិភ័យប្រតិបត្តិការផ្សេងៗរបស់ធនាគារ ព្រមទាំងការគ្រប់គ្រងការប្រឈមទៅនឹងហានិភ័យប្រតិបត្តិការ និងបញ្ហាជាក់លាក់ត្រឹមកម្រិតផ្នែកអាជីវកម្ម/ផ្នែកទ្រទ្រង់។

### ក្រុមការងារពិនិត្យហានិភ័យដែលអាចកើតមានឡើង

ធនាគារកម្ពុបានបង្កើតក្រុមការងារពិនិត្យហានិភ័យដែលអាចកើតមានឡើង ដើម្បីអនុវត្តវិធាននៃការកំណត់ហានិភ័យដែលអាចកើតមានឡើងជាបន្តបន្ទាប់ ដែលអាចកើតចេញពីការវិវឌ្ឍន៍នៃស្ថានភាពសេដ្ឋកិច្ចក្នុងស្រុក និងសាកលលោក ព្រមទាំងចំណុចខ្សោយក្នុងដំណើរការ និង/ឬការអនុវត្តផ្ទៃក្នុងដែលបណ្តាលមកពីការផ្លាស់ប្តូរដំណើរការ/ការអនុវត្ត។ ក្រុមការងារនេះត្រូវធានាការឆ្លើយតបសមស្របនានាទៅនឹងហានិភ័យ ហើយរាល់ផែនការសកម្មភាពត្រូវបានអនុវត្តដើម្បីកាត់បន្ថយហានិភ័យដែលអាចកើតមានឡើង។ ហានិភ័យដែលអាចកើតមានឡើងដែលបានកំណត់ និងផែនការសកម្មភាពដែលបានអនុវត្ត/នឹងត្រូវអនុវត្តត្រូវបានដាក់ជូនទៅគណៈគ្រប់គ្រង គណៈកម្មការ/ក្រុមការងារដែលពាក់ព័ន្ធ គណៈកម្មការគ្រប់គ្រងហានិភ័យ និងក្រុមប្រឹក្សាភិបាល។

## ក្រមសីលធម៌ កិត្យានុភាព និងទំនុកចិត្ត

### ភាពជាអ្នកដឹកនាំប្រកបដោយក្រមសីលធម៌

ក្នុងនាមជាធនាគារសម្រាប់សាធារណជន និងរក្សាមូលនិធិសាធារណជន ធនាគារកម្ពុប្តេជ្ញាចិត្តរក្សាកម្រិតវិជ្ជាជីវៈនិយម និងសចុរិតភាពខ្ពស់ក្នុងទំនាក់ទំនងទាំងអស់ ដើម្បីគាំពារផលប្រយោជន៍ និងទំនុកចិត្តដល់ភាគីពាក់ព័ន្ធ ដូចជាអតិថិជន ភាគទុនិក និយោជិត និងសង្គមទាំងមូល។

ភាពល្អតតខ្ចោះ សុចរិតភាព និងក្រមសីលធម៌ការងាររឹងមាំត្រូវបានបញ្ជ្រាបទៅក្នុងផ្នត់គំនិតរួមរបស់ធនាគារកម្ពុ។ វប្បធម៌នៃក្រមសីលធម៌ និងសុចរិតភាពរបស់ធនាគារត្រូវបានកំណត់ចាប់ពីកម្រិតក្រុមប្រឹក្សាភិបាលដែលកំណត់ការតម្រង់ទិសនៃដំណើរការសាជីវកម្ម និងយុទ្ធសាស្ត្រ។

សុចរិតភាពរឹងមាំផ្តោតលើគោលនយោបាយត្រូវបានបង្កើតឡើង ដើម្បីពង្រឹងក្រមសីលធម៌រឹងមាំ និងវប្បធម៌អនុលោមភាព។

### ក្រមសីលធម៌

ក្រមសីលធម៌របស់ធនាគារកម្ពុ គឺស្របទៅតាម "ក្រមវិជ្ជាជីវៈសម្រាប់ឧស្សាហកម្មសេវាហិរញ្ញវត្ថុ" ដែលចេញដោយក្រុមប្រឹក្សាភិបាលវិជ្ជាជីវៈសេវាហិរញ្ញវត្ថុ (Financial Services Professional Board)។ ក្រមសីលធម៌នេះមានចែងស្តង់ដាអាកប្បកិរិយាល្អ និងប្រកបដោយក្រមសីលធម៌ និងការអនុវត្តការងារដែលគ្រប់និយោជិតទាំងអស់ត្រូវប្រកាន់ខ្ជាប់។

# និរន្តរភាពទូទៅនៃអភិបាលកិច្ចក្រុមហ៊ុន

### ក្រមសីលធម៌ (តពីទំព័រមុន)

ក្រមសីលធម៌របស់ធនាគារកម្ពុកំណត់យ៉ាងច្បាស់នៅក្នុងគោលការណ៍មូលដ្ឋានគ្រឹះទាំងប្រាំដូចខាងក្រោម៖

| គោលការណ៍នៃមូលដ្ឋានគ្រឹះក្រមសីលធម៌ | និយមន័យសង្ខេប |
|---|---|
| 1. សមត្ថភាព | បង្កើត និងរក្សាចំណេះដឹង ជំនាញ និងអាកប្បកិរិយាពាក់ព័ន្ធដើម្បីធានាថាសកម្មភាពនានាត្រូវធ្វើឡើងប្រកបដោយវិជ្ជាជីវៈ និងប្រសិទ្ធភាព។ |
| 2. សុចរិតភាព | ស្មោះត្រង់ និងបើកចំហចំពោះការជួញដូរ និងទំនាក់ទំនងអាជីវកម្មប្រកបដោយឥរិយាបទទទួលខុសត្រូវ និងមានទំនុកចិត្ត។ |
| 3. ស្មើភាព | មានការទទួលខុសត្រូវ និងចាត់វិធានការស្មើភាពគ្នា និងតម្លាភាពចំពោះអ្នកពាក់ព័ន្ធ។ |
| 4. ការរក្សាការសម្ងាត់ | រក្សាការសម្ងាត់ និងព័ត៌មានសំខាន់ ក្នុងនោះរួមមានទំនាក់ទំនងរបស់អតិថិជនជាមួយធនាគារ។ |
| 5. អព្យាក្រឹត្យភាព | មិនអនុញ្ញាតឱ្យមានភាពលម្អៀង ទំនាស់ផលប្រយោជន៍ ឬទទួលឥទ្ធិពលពីអ្នកដទៃដែលអាចប៉ះពាល់ដល់ការអនុម័តប្រតិបត្តិការអាជីវកម្ម និងការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈរបស់ខ្លួន។ |

### គោលនយោបាយពិពិធកម្ម សមធម៌ និងបរិយាបន្ន

ធនាគារកម្ពុមានជំនឿយ៉ាងមុតមាំថា បុគ្គលិករបស់ខ្លួនជាអ្នកកំណត់អត្តន័យធនាគារ ជំរុញកំណើនធុរកិច្ច និងពង្រឹងកេរ្តិ៍ឈ្មោះធនាគារក្លាយជាគ្រឹះស្ថានហិរញ្ញវត្ថុដែលទទួលបានការគោរពមួយក្នុងចំណោមគ្រឹះស្ថានហិរញ្ញវត្ថុទាំងនៅកម្ពុជា។

គោលនយោបាយពិពិធកម្ម សមធម៌ និងបរិយាបន្នបានបង្ហាញពីការប្តេជ្ញាចិត្តរបស់ធនាគារក្នុងការជំរុញការផ្លាស់ប្តូរប្រកបដោយវិជ្ជមាន និងពង្រឹងកន្លែងការងារមួយដែលបុគ្គលិកមានសាវតាខុសគ្នាអាចមានអារម្មណ៍ថាទទួលបានការស្វាគមន៍ ការគាំទ្រដើម្បីភាពរីកចម្រើន ការអភិវឌ្ឍន៍ និងការចូលរួមចំណែក។

ធនាគារកម្ពុមិនមានការលើកលែងចំពោះការរើសអើង និងការបៀតបៀនណាមួយឡើយ ដោយសារទង្វើនេះផ្ទុយទៅនឹងវប្បធម៌ និងតម្លៃស្នូលរបស់ធនាគារ។ ជាផ្នែកមួយនឹងការប្តេជ្ញាចិត្តរបស់ធនាគារក្នុងការរក្សាកន្លែងការដែលពោពេញដោយការគោរព បុគ្គលិកទាំងអស់ ត្រូវបានលើកទឹកចិត្តឱ្យរាយការណ៍រាល់ទង្វើផ្ទុយទៅនឹងច្បាប់/ការប្រព្រឹត្តផ្តាំឆ្គង/អាកប្បកិរិយាមិនសមរម្យ តាមរយៈបណ្តាញវិស្សលប្ល័រវីង និងបណ្តឹងវិវាទការងារ។ បុគ្គលិកដែលរំលោភបំពានគោលនយោបាយពិពិធកម្ម សមធម៌ និងបរិយាបន្នត្រូវទទួលរងវិធានការខាងវិន័យកំណត់ស្របតាមក្របខណ្ឌគ្រប់គ្រងវិធានការវិន័យរបស់ធនាគារកម្ពុ។

### គោលនយោបាយប្រតិបត្តិតាម

ធនាគារកម្ពុទទួលស្គាល់ថា ការយល់ដឹងអំពីការប្រតិបត្តិតាមដែលផ្តោតលើគោលជំហរបុរេសកម្មសំដៅដល់ការកំណត់អត្តសញ្ញាណ វាយតម្លៃ និងគ្រប់គ្រងហានិភ័យប្រកបដោយការយកចិត្តទុកដាក់ខ្ពស់។ គោលនយោបាយប្រតិបត្តិតាមរបស់ធនាគារកម្ពុមានចែងលក្ខខណ្ឌតម្រូវនៃការប្រតិបត្តិតាម អភិបាលកិច្ច ព្រមទាំងតួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រងជាន់ខ្ពស់ មុខងារធុរកិច្ច និងគាំទ្រ និងបុគ្គលិកក្នុងការគ្រប់គ្រងហានិភ័យប្រតិបត្តិតាម។

គោលនយោបាយប្រតិបត្តិតាមរបស់ធនាគារកម្ពុត្រូវបានអនុម័ត ដើម្បីធានាសុចរិតភាពនៃប្រតិបត្តិការរបស់ធនាគារជាមួយគោលបំណងដូចខាងក្រោម៖

(i) កំណត់តួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រងជាន់ខ្ពស់ និងបុគ្គលិករបស់ធនាគារកម្ពុក្នុងការគ្រប់គ្រងហានិភ័យប្រតិបត្តិតាម

# ទិដ្ឋភាពទូទៅនៃអភិបាលកិច្ចក្រុមហ៊ុន

## គោលនយោបាយប្រតិបត្តិតាម (តពីទំព័រមុន)

(ii) កំណត់ភាពចាំបាច់នៃមុខងារប្រតិបត្តិតាមសម្រាប់ធនាគារ

(iii) កំណត់លក្ខខណ្ឌតម្រូវ និងបទដ្ឋាននៃការប្រតិបត្តិតាមសម្រាប់ធនាគារ

(iv) កំណត់ម៉ូឌែលប្រតិបត្តិការសម្រាប់មុខងារប្រតិបត្តិតាមពាក់ព័ន្ធទៅនឹងការកំណត់ គ្រប់គ្រង និងរាយការណ៍អំពីហានិភ័យប្រតិបត្តិតាម និង

(v) ផ្សព្វផ្សាយវប្បធម៌សាជីវកម្មដែលលើកកម្ពស់បទដ្ឋាននៃការមិនអនុគ្រោះចំពោះការមិនប្រតិបត្តិតាមច្បាប់ និងបទប្បញ្ញត្តិ សុចរិតភាព និងក្រមសីលធម៌ក្នុងការធ្វើអាជីវកម្មរបស់ធនាគារកម្ពុ។

គោលនយោបាយប្រតិបត្តិតាមរបស់ធនាគារកម្ពុត្រូវបានបង្កើតផ្អែកលើគោលការណ៍ពេញលេញទាំង 3 ដូចខាងក្រោម៖

(i) "វិធីសាស្ត្រមិនអនុគ្រោះចំពោះការមិនប្រតិបត្តិតាមច្បាប់ និងបទប្បញ្ញត្តិ"

បុគ្គលិកទាំងអស់ត្រូវបានរំពឹងទុកថា បានអនុលោមតាមតាមច្បាប់ និងបទប្បញ្ញត្តិដែលគ្រប់គ្រងអាជីវកម្ម និងប្រតិបត្តិការរបស់ធនាគារកម្ពុ។

(ii) "ការប្រតិបត្តិតាមគឺជាការទទួលខុសត្រូវរបស់បុគ្គលិកទាំងអស់"

បុគ្គលិកទាំងអស់ ដោយមិនគិតពីមុខតំណែងមានទំនួលខុសត្រូវចំពោះការគ្រប់គ្រងហានិភ័យប្រតិបត្តិតាមក្នុងវិសាលភាពការងាររបស់ពួកគេប្រកបដោយប្រសិទ្ធភាព។

(iii) "វិធីសាស្ត្រផ្អែកលើហានិភ័យ" ក្នុងការគ្រប់គ្រងហានិភ័យប្រតិបត្តិតាម

មុខងារប្រតិបត្តិតាមអនុវត្តការវាយតម្លៃហានិភ័យប្រតិបត្តិតាមជាប្រចាំ ដើម្បីកំណត់អត្តសញ្ញាណ និងផ្តល់អាទិភាពលើលក្ខខណ្ឌតម្រូវនៃច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងធនាគារដែលកំណត់ដោយនិយ័តករ។

## គោលនយោបាយប្រឆាំងការក្លែងបន្លំ

ធនាគារកម្ពុបន្តបំផុសវប្បធម៌ប្រុងប្រយ័ត្នដល់បុគ្គលិកទាំងអស់ក្នុងការកំណត់អត្តសញ្ញាណ ដោះស្រាយ និងប្រយុទ្ធប្រឆាំងការក្លែងបន្លំ។

ការអនុលោមតាមយ៉ាងហ្មតចត់ និងតឹងរឹងចំពោះគោលជំហរមិនមានការអនុគ្រោះរបស់ធនាគារកម្ពុទៅលើការក្លែងបន្លំ និងការប្រព្រឹត្តិប្រកបដោយក្រមសីលធម៌ត្រូវបានបញ្ជ្រាបទៅក្នុងដំណើរការធុរកិច្ច និងកំណត់ជាចក្ខុវិស័យសាជីវកម្ម។

គោលនយោបាយប្រឆាំងការក្លែងបន្លំរបស់ធនាគារកម្ពុបានគូសបញ្ជាក់ការប្តេជ្ញាចិត្តរបស់ធនាគារកម្ពុក្នុងការលុបបំបាត់ការក្លែងបន្លំពីគ្រប់សកម្មភាពធុរកិច្ចទាំងអស់របស់ខ្លួន។

គោលបំណងសំខាន់ៗនៃគោលនយោបាយប្រឆាំងការក្លែងបន្លំរបស់ធនាគារកម្ពុមានដូចខាងក្រោម៖

- ធានាប្រតិបត្តិការអាជីវកម្មរបស់ធនាគារកម្ពុស្របតាមច្បាប់។
- បង្កើតបរិយាកាសមួយដែលពោរពេញដោយភាពស្មោះត្រង់ និងសុចរិតភាព។
- លើកកម្ពស់ការយល់ដឹងអំពីគោលជំហររបស់ធនាគារលើរាល់ទង្វើដែលមិនសមរម្យ ផ្ទុយទៅនឹងច្បាប់ និងភាពមិនស្មោះត្រង់ និងផលវិបាកដែលកើតចេញពីទង្វើទាំងនោះ និង
- បង្កើតការយល់ដឹងរបស់បុគ្គលិកអំពីតួនាទី សិទ្ធិ និងការទទួលខុសត្រូវពាក់ព័ន្ធទៅនឹងទង្វើដែលមិនសមរម្យ ផ្ទុយទៅនឹងច្បាប់ និងភាពមិនស្មោះត្រង់។

# និរន្តរភាពទូទៅនៃអភិបាលកិច្ចក្រុមហ៊ុន

## គោលនយោបាយប្រឆាំងការស៊ីសំណូក និងអំពើពុករលួយ

ធនាគារកម្ពុប្តេជ្ញាចិត្តធ្វើអាជីវកម្ម និងប្រតិបត្តិការស្របតាមបទដ្ឋានក្រមសីលធម៌ និងសុចរិតភាពខ្ពស់។ ធនាគារកម្ពុអនុវត្តគោលនយោបាយមិនមានការអនុគ្រោះលើគ្រប់ទម្រង់នៃការស៊ីសំណូក និងពុករលួយ។ វប្បធម៌នៃការប្រតិបត្តិតាមត្រូវបានបញ្ចូលទៅក្នុងមូលដ្ឋានគ្រឹះនៃវប្បធម៌ និងគុណតម្លៃរបស់ធនាគារ។

គោលនយោបាយប្រឆាំងការស៊ីសំណូក និងអំពើពុករលួយរបស់ធនាគារកម្ពុអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ក្នុងនោះរួមមានច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ 2010។ គោលនយោបាយប្រឆាំងការស៊ីសំណូក និងអំពើពុករលួយរបស់ធនាគារកម្ពុត្រូវបានដាក់ឱ្យអនុវត្តជាមួយគោលបំណងដូចខាងក្រោម៖

- បង្កើត និងពង្រឹងបរិយាកាសអាជីវកម្មមួយដែលមិនមានការស៊ីសំណូក និងអំពើពុករលួយ លើកកម្ពស់សុចរិតភាព តម្លាភាព និងភាពទទួលខុសត្រូវ
- បណ្តុះផ្នត់គំនិតដល់សមាជិកក្រុមប្រឹក្សាភិបាល និងបុគ្គលិកទាំងអស់អំពីការប្តេជ្ញាចិត្តរបស់ធនាគារកម្ពុប្រឆាំងទៅនឹងអំពើពុករលួយគ្រប់ទម្រង់រូបភាព ក្នុងនោះរួមមានការស៊ីសំណូក និង
- កំណត់កត្តាដែលធ្វើឱ្យមានការស៊ីសំណូក និងអំពើពុករលួយ និងការប្រព្រឹត្តដែលត្រូវបានហាមឃាត់។

## គោលនយោបាយប្រឆាំងការសម្អាតប្រាក់ ប្រឆាំងហិរញ្ញប្បទានភេរវកម្ម ប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយអាវុធ និងទណ្ឌកម្មផ្នែកហិរញ្ញវត្ថុ ( AML/CFT/CPF និង TFS )

ការប្តេជ្ញាចិត្តរបស់ធនាគារកម្ពុក្នុងការប្រយុទ្ធប្រឆាំងហានិភ័យនៃ AML/CFT/CPF និង TFS ត្រូវបានបង្ហាញតាមរយៈក្របខណ្ឌ AML/CFT/CPF និង TFS រឹងមាំ និងទូលំទូលាយ និងគោលនយោបាយដែលកំណត់ហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរឹងមាំ ដើម្បីទប់ស្កាត់សកម្មភាពផ្ទុយទៅនឹងច្បាប់ និងគាំពារប្រព័ន្ធហិរញ្ញវត្ថុ។

គោលបំណងសំខាន់របស់គោលនយោបាយ AML/CFT/CPF និង TFS របស់ធនាគារកម្ពុមានដូចខាងក្រោម៖

- កំណត់ការរំពឹងទុកនៃការអនុវត្តតាមលក្ខខណ្ឌតម្រូវ AML/CFT/CPF និង TFS សម្រាប់គ្រប់ផ្នែកទាំងអស់ក្នុងធនាគារកម្ពុ និង
- បង្កើតក្របខណ្ឌដើម្បីធានាថា រាល់បុគ្គលិកទាំងអស់បានយល់ និងអនុលោមតាមលក្ខខណ្ឌតម្រូវ AML/CFT/CPF និង TFS ដើម្បីប្រឆាំងនឹងហានិភ័យលាងសម្អាតប្រាក់ ឬហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយអាវុធ។

## គោលនយោបាយ និងនីតិវិធីវិស្សលប្លូវឹង

គោលនយោបាយវិស្សលប្លូវឹងរឹងមាំគឺជាមូលដ្ឋានគ្រឹះសម្រាប់វប្បធម៌បើកចំហ និងសេរីភាពបញ្ចេញមតិ ដែលឈានដល់តម្លាភាព អនុលោមភាព និងបរិយាកាសការងារប្រកបដោយក្រមសីលធម៌។

គោលនយោបាយ និងនីតិវិធីវិស្សលប្លូវឹងរបស់ធនាគារកម្ពុ ត្រូវបានបង្កើតឡើងស្របតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជាស្តីពីការត្រួតពិនិត្យផ្ទៃក្នុងរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងមានគោលបំណងបង្កើតបរិយាកាសការងារមួយដែលបុគ្គលិក អាជីវករ អ្នកផ្តល់សេវាកម្ម អតិថិជន និងអ្នកពាក់ព័ន្ធផ្សេងទៀតអាចសម្តែងការព្រួយបារម្ភអំពីការប្រព្រឹត្តកំហុសឆ្គង ភាពមិនប្រក្រតី ឬការប្រព្រឹត្តផ្ទុយទៅនឹងច្បាប់ ដោយមិនមានការភ័យខ្លាច ឬធ្វើទុក្ខបុកម្នេញ និង/ឬការក្លាយទៅជាជនរងគ្រោះ និងការទទួលនូវការធានាថា ការព្រួយបារម្ភរបស់ពួកគេត្រូវបានពិនិត្យយ៉ាងហ្មត់ចត់។

គោលបំណងរបស់គោលនយោបាយ និងនីតិវិធីវិស្សលប្លូវឹងមានដូចខាងក្រោម៖

- ផ្តល់ទីកន្លែង ឬបណ្តាញសម្រាប់បុគ្គលិក និងភាគីទីបី ( មានដូចជាបុគ្គលិកហាត់ការ អ្នកប្រឹក្សាយោបល់ អ្នកម៉ៅការ អ្នកលក់ អ្នកផ្គត់ផ្គង់ អតិថិជន ) ដើម្បីរាយការណ៍អំពីការប្រព្រឹត្ត ឬការអនុវត្តផ្ទុយទៅនឹងច្បាប់ ក្រមសីលធម៌ ការអនុវត្តគួរឱ្យសង្ស័យ ឬមិនសមរម្យក្នុងធនាគារកម្ពុ និង
- ដាក់ចេញនូវការការពារអ្នកដាក់ពាក្យបណ្តឹង ដែលបានបង្ហាញអំពីការប្រព្រឹត្តខុសប្រកបដោយសុចរិតទៀងត្រង់។

# និន្នាការទូទៅនៃអភិបាលកិច្ចក្រុមហ៊ុន

### គោលនយោបាយ និងនីតិវិធីវិស្សលប្លឺវីង (តពីទំព័រមុន)

អភិបាលមិនប្រតិបត្តិម្នាក់ ដែលជាប្រធានគណៈកម្មការគ្រប់គ្រងហានិភ័យទទួលបន្ទុកមុខងារប្រតិបត្តិតាម ទទួលខុសត្រូវចំពោះការអនុវត្តគោលនយោបាយ និងនីតិវិធីវិស្សលប្លឺវីងប្រកបដោយប្រសិទ្ធភាព។

### គោលនយោបាយប្រឆាំងការបៀតបៀនផ្លូវភេទ

ធនាគារកម្ពុខិតខំប្រឹងប្រែងរក្សាឱ្យបាននូវបរិកាសការងារ ដែលបុគ្គលិកទាំងអស់ត្រូវទទួលបានការគោរព និងសេចក្តីថ្លៃថ្នូរ។ បរិយាកាសបែបនេះស្តែងឱ្យឃើញតាមរយៈទំនុកចិត្តទៅវិញទៅមក និងមិនមានការគម្រាមកំហែង ការគាបសង្កត់ ការកែងប្រវ័ញ្ច ការបៀតបៀន ភាពអាម៉ាស់ ឬអាកប្បកិរិយារំលោភបំពានណាមួយ។ ធនាគារកម្ពុមិនមានការអនុគ្រោះចំពោះទម្រង់នៃការបៀតបៀនផ្លូវភេទណាមួយឡើយ។

បណ្តាញរាយការណ៍ផ្សេងៗអាចប្រើប្រាស់គ្រប់បុគ្គលិកទាំងអស់ ដែលបានដឹងអំពីការបៀតបៀនផ្លូវភេទ និង/ឬជនរងគ្រោះដោយសារការដាក់ពាក្យបណ្តឹង។ រាល់របាយការណ៍អំពីការបៀតបៀនផ្លូវភេទត្រូវបានរក្សាជាការសម្ងាត់បំផុត។ បុគ្គលិកដែលត្រូវបានរកឃើញថារំលោភបំពានគោលនយោបាយនេះនឹងត្រូវទទួលរងវិធានការខាងវិន័យ ស្របតាមក្របខណ្ឌគ្រប់គ្រងវិធានការវិន័យរបស់ធនាគារកម្ពុ។

គោលបំណងសំខាន់ៗមានដូចខាងក្រោម៖

- ដើម្បីបង្ការ និងលុបបំបាត់ការបៀតបៀនផ្លូវភេទនៅកន្លែងធ្វើការ
- ផ្តល់បរិយាកាសការងារដែលមានសុវត្ថិភាព និងជាសុភភាពនៅគ្រប់កន្លែងបំពេញការងាររបស់បុគ្គលិកម្នាក់ៗ ដោយមិនគិតពីឋានៈ និងមុខតំណែងត្រូវទទួលបានការគោរព និងមិនទទួលរងការបៀតបៀនផ្លូវភេទ ភាពអាម៉ាស និងការគម្រាមកំហែងផ្លូវភេទ។
- អប់រំ និងលើកកម្ពស់ការយល់ដឹងដល់បុគ្គលិកទាំងអស់អំពីមូលហេតុដែលនាំឱ្យមានការបៀតបៀនផ្លូវភេទនៅកន្លែងធ្វើការ
- អប់រំ និងលើកកម្ពស់ការយល់ដឹងដល់បុគ្គលិកទាំងអស់អំពីបណ្តាញ ដែលអាចប្រើប្រាស់សម្រាប់រាយការណ៍អំពីការបៀតបៀនផ្លូវភេទនៅកន្លែងការងារ និង
- ដាក់ចេញនូវវិធានការវិន័យនៃការរំលោភបំពានគោលនយោបាយដោយបុគ្គលិក។

### គោលនយោបាយបណ្តាញសង្គម

បណ្តាញសង្គមត្រូវបានចាត់ជាទុកកម្លាំងជំរុញដ៏មានឥទ្ធិពល ដែលបានធ្វើបដិវត្តមធ្យោបាយទំនាក់ទំនង ចែករំលែកព័ត៌មាន និងប្រាស្រ័យទាក់ទងជាមួយពិភពលោកនៅជុំវិញខ្លួនយើង។ ប៉ុន្តែ ការផ្លាស់ប្តូរនេះក្នុងបណ្តាញសង្គមក៏នាំមកនូវបញ្ហាប្រឈមដូចជាការផ្តល់ព័ត៌មានមិនត្រឹមត្រូវ ការព្រួយបារម្ភលើឯកជនភាព និងហានិភ័យសន្តិសុខដែលត្រូវគ្រប់គ្រងប្រកបដោយភាពប្រុងប្រយ័ត្ន ដើម្បីកាត់បន្ថយហានិភ័យដែលពាក់ព័ន្ធ។

គោលនយោបាយបណ្តាញសង្គមរបស់ធនាគារកម្ពុ ត្រូវបានប្រើប្រាស់ជាសៀវភៅណែនាំសម្រាប់បុគ្គលិកក្នុងការប្រើប្រាស់បណ្តាញសង្គមដ៏ឆ្លាតវៃ តាមរយៈការកំណត់ការរំពឹងទុកច្បាស់លាស់សម្រាប់ការប្រព្រឹត្តប្រកបដោយក្រមសីលធម៌នៅលើបណ្តាញសង្គម ទាំងសមត្ថភាពវិជ្ជាជីវៈ និងផ្ទាល់ខ្លួន។ ការណ៍នេះឆ្លុះបញ្ចាំងឱ្យឃើញពីការទទួលខុសត្រូវរួមរបស់ធនាគារ និងបុគ្គលិកក្នុងការការពារកេរ្តិ៍ឈ្មោះធនាគារនៅលើថ្នាលអនឡាញ។

គោលនយោបាយបណ្តាញសង្គមរបស់ធនាគារកម្ពុមានគោលបំណងដូចខាងក្រោម៖

- ដាក់ចេញនូវសេចក្តីណែនាំ និងបទដ្ឋានដែលរំពឹងទុកស្តីពីការប្រើប្រាស់បណ្តាញសង្គមប្រកបដោយការទទួលខុសត្រូវ និងក្រមសីលធម៌របស់បុគ្គលិករបស់ធនាគារកម្ពុទាំងអស់ និង
- ដាក់ចេញនូវវិធានការវិន័យនៃការរំលោភបំពានគោលនយោបាយដោយបុគ្គលិក។

# និន្នាការទូទៅនៃអភិបាលកិច្ចក្រុមហ៊ុន

## គោលនយោបាយសុវត្ថិភាពព័ត៌មាន

គោលនយោបាយសុវត្ថិភាពព័ត៌មានរបស់ធនាគារកម្ពុជាសបញ្ជាក់ពីការប្តេជ្ញាចិត្តដ៏មោះមុត ដើម្បីបន្តលើកកម្ពស់ការសម្ងាត់ សុចរិតភាព និងការប្រើប្រាស់ទិន្នន័យ។ គោលនយោបាយនេះត្រូវបានប្រើប្រាស់ជាមូលដ្ឋានដើម្បីបង្កើតបរិយាកាសដែលមានសុវត្ថិភាព និងកាត់បន្ថយហានិភ័យដែលអាចកើតមានពាក់ព័ន្ធទៅនឹងទិន្នន័យដែលមាននៅក្នុងហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យារបស់ធនាគារ។

ធនាគារកម្ពុប្រើប្រាស់វិធីសាស្រ្តដែលមានរចនាសម្ព័ន្ធច្បាស់លាស់ ដើម្បីគ្រប់គ្រងសុវត្ថិភាពព័ត៌មានដែលគោលការណ៍ ដំណើរការ និងវិធានការត្រូវបានអនុវត្តដើម្បីការពារទិន្នន័យ និងកម្មសិទ្ធិបញ្ញាពីការគម្រាមកំហែងសុវត្ថិភាពណាមួយ ហើយនីតិវិធីកាត់បន្ថយហានិភ័យសុវត្ថិភាពព័ត៌មានវិទ្យា មានចែងយ៉ាងច្បាស់លាស់នៅក្នុងគោលនយោបាយសុវត្ថិភាពព័ត៌មានរបស់ធនាគារ។

គោលបំណងនៃគោលនយោបាយនេះរួមមាន៖

- ការពារព័ត៌មានធនាគារកម្ពុពីការគម្រាមកំហែងជាយថាហេតុ មិនថាមានប្រភពពីខាងក្រៅ ឬផ្ទៃក្នុង ដោយចេតនា និងអចេតនា
- ធានាសុវត្ថិភាពចែករំលែកព័ត៌មាន
- ធានាថាបុគ្គលិកទាំងអស់យល់ដឹងអំពីតួនាទី និងការទទួលខុសត្រូវរបស់ពួកគេក្នុងការគ្រប់គ្រង និងការពារការសម្ងាត់ និងសុចរិតភាពព័ត៌មានដែលពួកគេគ្រប់គ្រង
- ការពារធនាគារកម្ពុពីការទទួលខុសត្រូវតាមផ្លូវច្បាប់ដោយសារតែការប្រើប្រាស់ព័ត៌មានមិនសមស្រប និង
- អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

## គោលនយោបាយវិវាទការងារ

ធនាគារកម្ពុយកចិត្តទុកដាក់យ៉ាងខ្លាំងលើសុខុមាលភាពរបស់បុគ្គលិក ហើយជឿជាក់យ៉ាងមុតមាំថា ការប្រាស្រ័យទាក់ទងជាប្រចាំ និងប្រកបដោយប្រសិទ្ធភាពគឺជាផ្នែកដ៏សំខាន់ក្នុងការកាត់បន្ថយជម្លោះ និងការភ័ន្តច្រឡំ។ គោលនយោបាយវិវាទការងារត្រូវបានអនុវត្តដើម្បីដឹកនាំកន្លែងធ្វើការមានភាពវិជ្ជមាន ស្មើភាព និងការគាំទ្រ។ បុគ្គលិកទាំងអស់អាចសម្តែងការព្រួយបារម្ភរបស់ខ្លួនតាមរយៈបណ្តាញដាក់ពាក្យបណ្តឹងរបស់ធនាគារ ដែលរាល់ពាក្យបណ្តឹងទាំងអស់ត្រូវបានគ្រប់គ្រងដោយស្មើភាព និងសមធម៌ សំដៅដោះស្រាយជម្លោះដោយសន្តិវិធី។

គោលបំណងនៃគោលនយោបាយនេះរួមមាន៖

- ដាក់ចេញនូវបណ្តាញ និងនីតិវិធីសម្រាប់បុគ្គលិកដាក់ពាក្យបណ្តឹងពីលក្ខខណ្ឌការងាររបស់ខ្លួន (ឧ.ការរំលោភបំពាន ឬការអនុវត្តការងារមិនស្មើភាព ការរំលោភបំពានសិទ្ធិមនុស្ស ភាពមិនពេញចិត្តលើលក្ខខណ្ឌការងារ ។ល។) និង
- ធានាថាបណ្តឹង ដែលបានទទួលត្រូវពិនិត្យទាន់ពេលដោយគណៈគ្រប់គ្រង ដើម្បីទទួលបានដំណោះស្រាយ/ការដោះស្រាយយ៉ាងឆាប់រហ័ស និងដោយសន្តិវិធីក្នុងកម្រិតទាបបំផុតតាមដែលអាចធ្វើទៅបានដើម្បីរក្សាឱ្យបាននូវសុខដុមនីកម្មឧស្សាហកម្ម ព្រមទាំងបរិយាកាសការងារវិជ្ជមាន និងស្មើភាព។

## ការបញ្ជ្រាបក្រមសីលធម៌ សុចរិតភាព និងទំនុកចិត្តក្នុងវប្បធម៌សាជីវកម្មរបស់ធនាគារកម្ពុ

ផ្អែកលើសារសំខាន់នៃវប្បធម៌ក្រមសីលធម៌ដែលជាកិច្ចការដ៏ស្មុគស្មាញមួយ តម្រូវឱ្យមានការបន្តផ្សារភ្ជាប់ ការពង្រឹងគុណតម្លៃស្នូល និងភាពជាអ្នកដឹកនាំតាមរយៈការធ្វើជាគំរូ។ ការប្តេជ្ញាចិត្តរបស់ធនាគារកម្ពុដើម្បីបណ្តុះវប្បធម៌ក្រមសីលធម៌ និងការប្រតិបត្តិតាម ដើម្បីជាសញ្ញានៃសុចរិតភាព និងទំនុកចិត្ត ហើយបានបញ្ជ្រាបទៅក្នុងគំនិតផ្តួចផ្តើម និងវិធានការដូចខាងក្រោមទៅក្នុងការគ្រប់គ្រងធនធានមនុស្សរបស់ធនាគារ៖

# និន្នាភាពទូទៅនៃអភិបាលកិច្ចក្រុមហ៊ុន

## ការបញ្ជ្រាបក្រមសីលធម៌ សុចរិតភាព និងទំនុកចិត្តក្នុងវប្បធម៌សាជីវកម្មរបស់ធនាគារកម្ពុ (តពីទំព័រមុន)

- ការពិនិត្យយ៉ាងតឹងរឹង និងហ្មត់ចត់មុនពេលចូលបំពេញការងារលើមុខតំណែងណាមួយ ដើម្បីបង្ការ ឬកាត់បន្ថយការជ្រៀតចូលសមាសធាតុណាមួយដែលមិនមានភាពសមស្របទៅលើបុគ្គលិក។
- ការបញ្ចូលសេចក្តីណែនាំ និងគោលនយោបាយក្នុងលិខិតផ្តល់ការងារ និងកិច្ចសន្យាការងារដែលត្រូវបានអាន ស្វែងយល់ និងបញ្ជាក់ពីការទទួលស្គាល់ដោយបុគ្គលិកទាំងអស់ បន្ទាប់ពីបានឱ្យបម្រើការងារ។
- សេចក្តីណែនាំ និងគោលនយោបាយនានានឹងត្រូវបញ្ជាក់បន្ថែមក្នុងកម្មវិធីធ្វើបទបង្ហាញណែនាំសម្រាប់បុគ្គលិកថ្មីៗ។
- ការក្រើនរំលឹកទៀតទាត់តាមរយៈសារាចរណែនាំបុគ្គលិក។
- ការបណ្តុះបណ្តាលគ្រប់ជ្រុងជ្រោយស្តីពីបទដ្ឋាននៃការប្រព្រឹត្តប្រកបដោយក្រមសីលធម៌ ដែលរំពឹងទុកពីបុគ្គលិកធនាគារកម្ពុ ដោយផ្តោតលើ៖
  - ការពង្រឹងចំណេះដឹងបុគ្គលិកអំពីលិខិតបទដ្ឋានគតិយុត្តិ
  - ការជួយបុគ្គលិកក្នុងការស្វែងយល់ និងការបញ្ជ្រាបបទដ្ឋាននៃក្រមសីលធម៌ដែលកំណត់ដោយធនាគារកម្ពុ
  - ការពង្រឹងចំណេះដឹង និងជំនាញបន្ថែមដល់បុគ្គលិកក្នុងការដោះស្រាយបញ្ហាក្រមសីលធម៌ និងសុចរិតភាព
  - ការពង្រឹងចំណេះដឹង និងជំនាញបន្ថែមដល់បុគ្គលិកក្នុងការស្វែងយល់សញ្ញាផ្តល់ដំណឹងជាមុនអំពីការក្លែងបន្លំ និងការប្រព្រឹត្តផ្ទុយទៅនឹងច្បាប់ និង
  - ជួយបុគ្គលិកអនុលោមតាមក្រមសីលធម៌ និងក្រមលើការប្រព្រឹត្តិរបស់ធនាគារកម្ពុ គោលនយោបាយប្រតិបត្តិតាម និងគោលនយោបាយប្រឆាំងការស៊ីសំណូក និងអំពើពុករលួយរបស់ធនាគារកម្ពុ។
- ការគ្រប់គ្រង និងនីតិវិធីត្រួតពិនិត្យយ៉ាងទូលំទូលាយក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ធនាគារកម្ពុ គឺដើម្បីធានាទទួលបានកិច្ចព្រមព្រៀងដែលមានភាពប្រុងប្រយ័ត្ន។
- ពិនិត្យ និងតាមដានលើអនុលោមភាពរបស់បុគ្គលិកតាមសេចក្តីណែនាំ ឬគោលនយោបាយដែលពាក់ព័ន្ធចេញដោយសវនកម្មផ្ទៃក្នុង និងក្រុមការងារនៃនាយកដ្ឋានប្រតិបត្តិតាមជាប្រចាំ។
- អនុវត្តប្រព័ន្ធគ្រប់គ្រងការងារដែលបញ្ចូលសមិទ្ធផលរំពឹងទុកលើបទដ្ឋានក្រមសីលធម៌ អភិបាលកិច្ច និងអនុលោមភាពទៅតាមលក្ខណវិនិយច្ឆ័យនៃការវាយតម្លៃលទ្ធផល និង
- អនុវត្តយុទ្ធសាស្រ្តអភិបាលកិច្ចគ្រប់គ្រងហានិភ័យលើលាភការបុគ្គលិក តាមរយៈការបង្វិលត្រឡប់លាភការ ឬទម្លាក់ពិន្ទុលើការវាយតម្លៃផ្តល់ប្រាក់រង្វាន់ ក្នុងករណីមានការក្លែងបន្លំ និង/ឬការប្រព្រឹត្តមិនសមរម្យ។

## ក្របខណ្ឌប្រុងប្រយ័ត្នទៅលើការប្រព្រឹត្តដោយមិនមានក្រមសីលធម៌

ធនាគារកម្ពុអនុវត្តវប្បធម៌សាជីវកម្មមួយដែល "សុចរិតភាព" គឺជាកត្តាដ៏សំខាន់នៅក្នុងប្រតិបត្តិការអាជីវកម្ម។ ភាពដ៏ល្អឥតខ្ចោះប្រកបដោយក្រមសីលធម៌នេះគឺជាកោសិកាធនាគារ។

ក្រុមប្រឹក្សាភិបាលចូលរួមយ៉ាងសកម្មក្នុងការដឹកនាំតម្រង់ទិស និងកំណត់ឱ្យអនុវត្តទៅគ្រប់ផ្នែកបុគ្គលិកទាំងអស់។ គណៈគ្រប់គ្រងជាន់ខ្ពស់ និងបុគ្គលិកត្រូវទទួលខុសត្រូវជារួមក្នុងការកសាង ពង្រឹង និងរក្សាទំនុកចិត្ត និងវប្បធម៌ប្រកបដោយក្រមសីលធម៌របស់ធនាគារកម្ពុ។

ហេតុដូច្នេះ ធនាគារកម្ពុមិនមានភាពស្ទាក់ស្ទើរក្នុងការចាត់វិធានការខាងវិន័យតឹងរឹង ស្របតាមក្របខណ្ឌគ្រប់គ្រងវិធានការវិន័យរបស់ខ្លួនលើការមិនអនុលោមតាមច្បាប់ គោលនយោបាយរបស់ធនាគារ វិធាន ឬបទប្បញ្ញត្តិ ដើម្បីការពារផលប្រយោជន៍របស់ធនាគារ និងអ្នកពាក់ព័ន្ធរបស់ខ្លួន។ ការបំពានលើសុចរិតភាព និងក្រមសីលធម៌ត្រូវបានរាយការណ៍ទៅក្រុមប្រឹក្សាភិបាលដើម្បីពិនិត្យបរិយាកាសក្រមសីលធម៌ក្នុងធនាគារ។

# ប្រតិបត្តិការអាជីវកម្ម

## ទស្សនទានហិរញ្ញវត្ថុ

បើទោះបី ប្រតិបត្តិការក្នុងឆ្នាំ2024 ស្ថិតក្នុងបរិយាកាសដែលពោរពេញដោយបញ្ហាប្រឈម ប្រតិបត្តិការអាជីវកម្ម និងប្រាក់ចំណេញរបស់ធនាគារកម្ពុរក្សាបាននូវស្ថិរភាពដដែល។

ធនាគារកម្ពុសម្រេចបានប្រាក់ចំណេញមុនបង់ពន្ធចំនួន 80.63 លានដុល្លារអាមេរិក គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2024។

ឥណទាន និងបុរេប្រទានដុលបានកើនឡើងចំនួន 90.47 លានដុល្លារអាមេរិក ឬ 6.45% ពោលកើនឡើងដល់ 1,494.06 លានដុល្លារអាមេរិក គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 ខណៈដែលប្រាក់បញ្ញើរបស់អតិថិជនបានកើនឡើងចំនួន 139.05 លានដុល្លារអាមេរិក ឬ 10.40% ពោលកើនឡើងដល់ 1,476.46 លានដុល្លារអាមេរិក គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2024។

សហការជាមួយក្រុមហ៊ុនអភិវឌ្ឍលំនៅដ្ឋានដែលមានតម្លៃសមរម្យ ធនាគារកម្ពុបានជួយដល់អតិថិជនច្រើនជាង 390 នាក់ ក្នុងការទទួលបានប្រាក់កម្ចីគេហដ្ឋាន ដោយបានអនុម័តផ្តល់ហិរញ្ញប្បទានប្រមាណ 11 លានដុល្លារអាមេរិក នៅក្នុងឆ្នាំ2024។ លើសពីនេះទៅទៀត ធនាគារកម្ពុបានបន្តចូលរួមគម្រោងធានាស្តារធុរកិច្ចឡើងវិញ តាមរយៈសាជីវកម្មធានាឥណទានកម្ពុជា ដើម្បីគាំទ្រសហគ្រាសខ្នាតតូច និងមធ្យម។ ស្ថិតក្រោមគម្រោងនេះ សាជីវកម្មធានាឥណទានកម្ពុជាបានផ្តល់ការធានាចំនួន 70%-80% នៃចំនួនប្រាក់ដើមឥណទានដល់ធុរកិច្ចនានា។ ក្នុងឆ្នាំ2024 ធនាគារអនុម័តផ្តល់ហិរញ្ញប្បទានច្រើនជាង 1.2 លានដុល្លារអាមេរិក ក្រោមគម្រោងនេះ។

ធនាគារនឹងបន្តអនុវត្តយុទ្ធសាស្ត្រអាជីវកម្មរបស់ខ្លួន ដោយផ្តោតការយកចិត្តទុកដាក់ក្នុងការឆ្លើយតបទៅនឹងតម្រូវការផ្នែកធនាគារ និងហិរញ្ញវត្ថុរបស់អតិថិជន និងអាជីវកម្មលើពាណិជ្ជកម្មទីផ្សារខ្នាតមធ្យម ជាពិសេសសហគ្រាសខ្នាតតូច និងមធ្យម ព្រមទាំងយកចិត្តទុកដាក់ក្នុងការស្តាបនាមូលធនប្រាក់បញ្ញើរយៈពេលវែងរបស់អ្នកដាក់ប្រាក់បញ្ញើទាំងឡាយ ដើម្បីពង្រីកតារាងតុល្យការថែមទៀត និងរក្សាប្រវត្តិនៃការកើនឡើងនូវប្រាក់ចំណេញ។

## ទស្សនទានអតិថិជន

### ការប្តេជ្ញាចិត្តក្នុងការផ្តល់សេវាកម្មអតិថិជនល្អឥតខ្ចោះ

វិធីសាស្ត្រផ្តោតលើអតិថិជនក្នុងការផ្តល់សេវាបម្រើអតិថិជនដ៏ល្អឥតខ្ចោះរបស់ធនាគារកម្ពុគឺជាផ្នែកដ៏សំខាន់មួយនៃគុណតម្លៃ និងវប្បធម៌សាជីវកម្មរបស់ធនាគារកម្ពុ។ ពាក្យស្លោកសាជីវកម្មរបស់ធនាគារកម្ពុគឺ "ឧត្តមភាពគឺជាការប្តេជ្ញាចិត្តរបស់យើងខ្ញុំ" ឆ្លុះបញ្ចាំងពីវប្បធម៌បម្រើសេវាអតិថិជនរបស់ធនាគារកម្ពុ ដែលជាសក្ខីភាពនៃការប្តេជ្ញាចិត្តរបស់ធនាគារកម្ពុក្នុងការផ្តល់សេវាកម្មដ៏ល្អឥតខ្ចោះដល់អតិថិជនរបស់ខ្លួន។ ស្មារតីបម្រើសេវាអតិថិជនេះជាសក្ខីភាពដែលបានកំណត់គោលការណ៍ណែនាំដើម្បីពង្រឹងការចូលរួម និងបង្កើតទំនាក់ទំនងជាមួយអតិថិជនរយៈពេលវែង។

នៅក្នុងឆ្នាំ2024 ធនាគារកម្ពុបានទទួលពានរង្វាន់ និងការទទួលស្គាល់ដ៏មានកិត្យានុភាពដូចខាងក្រោម ដែលជាសក្ខីភាពនៃការទទួលស្គាល់លើការប្តេជ្ញាចិត្តដ៏ខ្លាំងក្លាក្នុងការផ្តល់សេវាកម្មធនាគារដ៏ល្អឥតខ្ចោះរបស់ធនាគារកម្ពុះ

1. ពានរង្វាន់ "ធនាគារឆ្នើមនៅកម្ពុជា" ដែលផ្តល់ជូនដោយទស្សនាវដ្តី The Banker ប្រចាំទីក្រុងឡុងដ៍។
2. ពានរង្វាន់ "Best Bank for Diversity & Inclusion in Cambodia" និង "Cambodia's Best Bank for ESG in Cambodia" សម្រាប់រយៈពេល 2 ឆ្នាំជាប់គ្នា (2023 និង 2024) ពីទស្សនាវដ្តី Euromoney
3. ពានរង្វាន់ "Domestic Categories - Best Commercial Bank - SMEs in CLM (Cambodia, Laos, Myanmar)" សម្រាប់រយៈពេល 2 ឆ្នាំជាប់គ្នា (2023 និង 2024) ពីទស្សនាវដ្តី FinanceAsia

# ប្រតិបត្តិការអាជីវកម្ម

## ទស្សនទានអតិថិជន (តពីទំព័រមុន)

### ការប្តេជ្ញាចិត្តក្នុងការផ្តល់សេវាកម្មអតិថិជនល្អឥតខ្ចោះ (តពីទំព័រមុន)

4. ពានរង្វាន់ផ្តល់ជូនដោយទស្សនាវដ្តី Global Banking & Finance Review:
   - Best Corporate Governance Bank Cambodia;
   - Banking Customer Satification & Happiness Cambodia;
   - Best Bank for Sustianable Development Cambodia; និង
   - The Next 100 Global Awards - Banking Group
5. ពានរង្វាន់ "USD Straight-Through-Processing Excellence Award" ក្នុងរយៈពេលប្រាំពីរឆ្នាំជាប់គ្នា (2017 ដល់ 2023) ផ្តល់ជូនដោយ Bank of America Merrill Lynch, New York
6. ពានរង្វាន់នាំមុខ ផ្តល់ជូនដោយ VISA:
   - Spend Per Active Card for VISA Credit in Affluent Segment;
   - Spend Per Active Card for VISA Debit in Affluent Segment; និង
   - Commercial Card Volume Growth
7. ពានរង្វាន់ Leadership in Credit Volume ផ្តល់ជូនដោយ Mastercard

### ភាពពេញចិត្តរបស់អតិថិជនជាអាទិភាពចម្បងរបស់យើងខ្ញុំ

អនុលោមតាមពាក្យស្លោកសាជីវកម្មរបស់ខ្លួន "ឧត្តមភាពគឺជាការប្តេជ្ញាចិត្តរបស់យើងខ្ញុំ" ធនាគារកម្ពុតែងតែប្តេជ្ញាចិត្តពង្រឹងការផ្តល់សេវាកម្មដ៏ល្អឥតខ្ចោះ និងវិធីសាស្ត្រផ្តោតលើអតិថិជនក្នុងការបង្កើតទំនាក់ទំនងជាមួយអតិថិជន។ ធនាគារកម្ពុសង្កត់ធ្ងន់លើបទពិសោធន៍អតិថិជនក្នុងការផ្តល់សេវាបម្រើអតិថិជន ព្រមទាំងការផ្តល់ និងរចនាផលិតផល និងសេវាកម្ម។

ទន្ទឹមនឹងនេះ ការអនុវត្តគោលការណ៍ទំនាក់ទំនងស្មើភាពត្រូវបានបញ្ចូលទៅគ្រប់ប្រតិបត្តិការធនាគារ ដើម្បីធានាថា អតិថិជនទទួលបានសេវាកម្មដែលមានស្មើភាពគ្នា និងការយកចិត្តទុកដាក់គ្រប់ពេល។

នៅលើទីផ្សារដែលមានការប្រកួតប្រជែង គូប្រកួតប្រជែងផ្តល់ផលិតផល និងសេវាកម្មស្រដៀងគ្នា ហើយផ្តោតគោលដៅលើមូលដ្ឋានអតិថិជនដូចគ្នា។ ដោយសារភាពស្រដៀងគ្នា និងការប្រកួតប្រជែងលើផលិតផល និងសេវាកម្មធនាគារផ្សេងៗ សេវាបម្រើអតិថិជនដ៏ល្អឥតខ្ចោះ គឺជាការកំណត់ភាពខុសគ្នាដ៏សំខាន់ដែលជាកត្តាកំណត់សម្រាប់ផ្តល់គន្លឹះនៃការប្រកួតប្រជែង និងបញ្ចុះបញ្ចូលសាធារណជនឱ្យបន្តធ្វើប្រតិបត្តិការជាមួយធនាគារកម្ពុ។

ធនាគារកម្ពុ គឺជាធនាគារដំបូងគេនៅប្រទេសកម្ពុជាដែលដាក់ដំណើរការយុទ្ធាការយកចិត្តទុកដាក់អតិថិជនប្រកបដោយភាពជោគជ័យនៅក្នុងឆ្នាំ2013 ហើយគំនិតផ្តួចផ្តើមនេះបានបន្តអនុវត្តនៅក្នុងឆ្នាំ2016, 2018, 2019 និង2022 ដែលមានគោលបំណងបំផុស និងពង្រឹងឥរិយាបថផ្តល់សេវាអតិថិជនរបស់បុគ្គលិកជួរមុខ ព្រមទាំងស្នើសុំមតិយោបល់របស់អតិថិជនលើកម្រិតគុណភាពសេវាកម្មរបស់ធនាគារ។

នៅក្នុងឆ្នាំ2024 ធនាគារកត់ត្រាអត្រាអនុលោមភាព 98.66% ក្នុងការឆ្លើយតបតាមស្តង់ដារង់ចាំ 5 នាទី សម្រាប់សេវាអតិថិជនជួរមុខ។

# ប្រតិបត្តិការអាជីវកម្ម

### ភាពពេញចិត្តរបស់អតិថិជនជាអាទិភាពចម្បងរបស់យើងខ្ញុំ (តពីទំព័រមុន)

ស្របតាមបទប្បញ្ញត្តិធនាគារជាតិនៃកម្ពុជា ធនាគារកម្ពុបានបង្កើតក្របខណ្ឌគ្រប់គ្រងបណ្ដឹងអតិថិជន ដើម្បីធានាថាបណ្ដឹងអតិថិជនត្រូវបានដោះស្រាយទាន់ពេល និងប្រកបដោយប្រសិទ្ធភាពក្នុងរយៈពេលកំណត់ស្តង់ដា 14 ថ្ងៃ។ បន្ថែមជានេះទៅទៀត ធនាគារកម្ពុបានដាក់ដំណើរការតាមដានបណ្ដឹងតាមអនឡាញ ដើម្បីធានាថា បណ្ដឹងដែលបានដាក់តាមរយៈថ្នាលអនឡាញរបស់ធនាគារកម្ពុត្រូវបានកំណត់ និងដោះស្រាយតាមការពេញចិត្តរបស់អតិថិជន។

ក្នុងឆ្នាំ2024 ការផ្តល់សេវារបស់ធនាគារកម្ពុត្រូវបានបង្ហាញជាមួយនឹងការប្រតិបត្តិតាម 80% ស្របតាមនីតិវិធីដោះស្រាយបណ្តឹងក្នុងរយៈពេលកំណត់ផ្ទៃក្នុង 14 ថ្ងៃ។

### ភាពទូលំទូលាយនៃបណ្ដាញផ្តល់សេវាកម្មអតិថិជន

ជាមួយនឹងកំណើនអតិថិជនដែលស្វែងរកភាពងាយស្រួលក្នុងការធ្វើប្រតិបត្តិការធនាគារ និងការទទួលបានព័ត៌មានអំពីផលិតផល និងសេវាកម្ម ធនាគារកម្ពុបន្តពង្រឹងបទដ្ឋានផ្តល់សេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធ ដែលផ្តោតលើទំនើបកម្មនៃបច្ចេកវិទ្យា ដើម្បីផ្តល់សេវាធនាគារគ្រប់បណ្តាញចែកចាយដោយរលូន។ ធនាគារកម្ពុបានដំឡើងម៉ាស៊ីនអេធីអឹមបន្ថែមចំនួនមួយគ្រឿង និងម៉ាស៊ីនដកដាក់ប្រាក់ចំនួនបីគ្រឿងនៅក្នុងឆ្នាំ2024 ដោយធ្វើឱ្យចំនួនម៉ាស៊ីនដកដាក់ប្រាក់ និងម៉ាស៊ីនអេធីអឹមកើនឡើងដល់ 88 គ្រឿង គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2024។

មណ្ឌលប្រតិបត្តិការធនាគារសម្រាប់ភ្ញៀវកិត្តិយសរបស់ធនាគារកម្ពុ បានបើកដំណើរការនៅសាខាខណ្ឌបឹងកេង-សង្កាត់បឹងកេងកងទីមួយ (អតីតសាខាមហាវិថីព្រះសីហនុ) នៅថ្ងៃទី6 ខែឧសភា ឆ្នាំ2024 ដែលធ្វើឱ្យមណ្ឌលប្រតិបត្តិការធនាគារសម្រាប់ភ្ញៀវកិត្តិយសកើនឡើងសរុបចំនួន 7 ដើម្បីបម្រើសេវាដល់អតិថិជនមានមូលធនច្រើន។

ធនាគារកម្ពុក៏បានចេញប័ណ្ណសមាជិកមណ្ឌលប្រតិបត្តិការធនាគារសម្រាប់ភ្ញៀវកិត្តិយសដល់អតិថិជន វីអាយភី ដើម្បីទទួលបានសេវាធនាគារអាទិភាព និងកម្រៃប្រតិបត្តិការពិសេស។

បណ្ដាញធ្វើប្រតិបត្តិការធនាគារតាមអនឡាញរបស់ធនាគារកម្ពុ គឺប្រតិបត្តិការធនាគារតាមប្រព័ន្ធអ៊ិនធើណិត និងទូរស័ព្ទដៃត្រូវបានបន្តធ្វើបច្ចុប្បន្នភាព ដើម្បីផ្តល់បទពិសោធន៍អ្នកប្រើប្រាស់កាន់តែប្រសើរលើការធ្វើប្រតិបត្តិការធនាគារប្រចាំថ្ងៃ ដូចជាការផ្ទេរប្រាក់ឆ្លងធនាគារតាមប្រព័ន្ធបាគង និងវ៉ែថលផេរបស់ធនាគារជាតិនៃកម្ពុជា ការទូទាត់ទៅពាណិជ្ជករ/អាជីវករតាមឃេអេចឃ្យូអរ ការបង់ពន្ធ ការទូទាត់វិក្កយបត្រទឹកភ្លើង និងការបញ្ចូលទឹកប្រាក់ក្នុងទូរស័ព្ទដៃ ។ល។

គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នែ2024 ធនាគារមានបណ្ដាញសាខាសរុបចំនួន 32 សាខា។

### ទស្សនៈទានព័ត៌មានវិទ្យា

នៅក្នុងពិភពលោកដែលជំរុញដោយបច្ចេកវិទ្យា នវានុវត្តន៍ និងការធ្វើឱ្យប្រសើរឡើងនូវបទពិសោធន៍អតិថិជននៅតែជាដំណើរបន្តសម្រាប់ធនាគារកម្ពុ។ ដោយទទួលស្គាល់អំពីសារសំខាន់នៃការពង្រឹងសេវាដ៏ល្អឥតខ្ចោះ ធនាគារកម្ពុបានប្រើប្រាស់យុទ្ធសាស្ត្រពាក់ព័ន្ធ ដើម្បីផ្តល់សេវាកម្មដែលមានគុណភាពខ្ពស់ ឆាប់រហ័ស និងប្រសិទ្ធភាពសំដៅពង្រឹងតម្លៃអតិថិជន លើកកម្ពស់ភាពស្មោះត្រង់អតិថិជន និងការពង្រឹងបន្ថែមដើម្បីរក្សាអតិថិជន។

ដើម្បីពង្រីកវិសាលភាពនៃផលិតផល និងសេវាកម្មរបស់ធនាគារ និងដើម្បីផ្តល់ភាពងាយស្រួលដល់អតិថិជនក្នុងការធ្វើប្រតិបត្តិការធនាគារក្រៅម៉ោងធ្វើការ ធនាគារបានដាក់ឱ្យដំណើរការសេវាកម្មម៉ាស៊ីនអេធីអឹម/ម៉ាស៊ីនដកដាក់ប្រាក់ និងសេវាកម្មប័ណ្ណឥណទានរបស់ខ្លួន ដោយដាក់ឱ្យដំណើរការប្រភេទប័ណ្ណឥណទានផ្សេងៗមានដូចជាប័ណ្ណឥណទាន ប័ណ្ណឥណពន្ធ VISA និង MasterCard សម្រាប់អតិថិជន និងអាជីវកម្ម ហើយក្រោយមក ធនាគារក៏បានចូលរួមបណ្តាញខេមបូឌាន ស៊ែ ស្វីច (Cambodian Shared Switch) ផងដែរ។ សេវាធនាគារតាមប្រព័ន្ធអ៊ីនធើណិត និងទូរស័ព្ទដៃជាសេវាកម្មបន្ថែមពីរដែលមានសុវត្ថិភាពខ្ពស់ និងអាចប្រើប្រាស់សម្រាប់អតិថិជនឯកត្តបុគ្គល និងក្រុមហ៊ុនក្នុងការធ្វើប្រតិបត្តិការធនាគារក្រៅម៉ោង។

# ប្រតិបត្តិការអាជីវកម្ម

## ទស្សនៈទានព័ត៌មានវិទ្យា (តពីទំព័រមុន)

ជាផ្នែកមួយនៃការពង្រឹងសុវត្ថិភាព នៅក្នុងឆ្នាំ2021 ធនាគារកម្ពុជាបានអនុវត្តកូដនីយកម្មហាដ ឌីស ដោយប្រើប្រាស់បច្ចេកវិទ្យារបស់ក្រុមហ៊ុន Microsoft នៅតាមម៉ាស៊ីនអេធីអឹម និងកន្លែងធ្វើការនៅគ្រប់សាខាទាំងអស់ និងនៅទីស្នាក់ការកណ្ដាល។ ដើម្បីជាដំណោះស្រាយពាណិជ្ជកម្មតាមប្រព័ន្ធអ៊ីនធើណិតកាន់តែទំនើប និងមានភាពបត់បែន និងផ្ទៃប្រឌិត និងដើម្បីរក្សាការប្រកួតប្រជែងក្នុងអាជីវកម្មទិញទំនិញ ជាពិសេសផ្នែកពាណិជ្ជកម្មតាមប្រព័ន្ធអ៊ីនធើណិត ធនាគារកម្ពុជាបានចុះហត្ថលេខាជាមួយក្រុមហ៊ុន Cybersource ដែលជាក្រុមហ៊ុនផ្តល់សេវាទូទាត់ពេញលេញតាម Visa ដែលផ្តល់ដំណោះស្រាយ Cybersource សម្រាប់ការទទួលយកការទូទាត់គ្រប់ប្រភេទនៅទូទាំងសាកលលោក។

ធនាគារកម្ពុជាបន្តផ្សារភ្ជាប់ទំនាក់ទំនងជាមួយសហគមន៍ តាមរយៈបណ្តាញសង្គមផ្លូវការ។ ថ្នាលបណ្តាញសង្គមទាំងនេះនឹងពង្រឹងពាណិជ្ជនាមធនាគារសាធារណៈរបស់យើងខ្ញុំ ដោយផ្សព្វផ្សាយផលិតផល និងសេវាកម្មចាស់ថ្មី ព្រមទាំងយុទ្ធនាការ និងព្រឹត្តិការណ៍ផ្សព្វផ្សាយជាបន្តបន្ទាប់ ដែលជាផ្នែកមួយនៃការជំរុញបរិវត្តកម្មឌីជីថល។

ដើម្បីលុបបំបាត់ហានិភ័យពាក់ព័ន្ធនឹងការផ្លាស់ប្តូរខ្សែអាត់ផ្ទុកទិន្នន័យ បង្កើនប្រសិទ្ធភាពប្រតិបត្តិការ និងកាត់បន្ថយហានិភ័យខ្សែអាត់ផ្ទុកទិន្នន័យដែលមិនអាចប្រើប្រាស់បានដោយសារការពុកផុយ នៅថ្ងៃទី1 ខែមីនា ឆ្នាំ2022 ធនាគារកម្ពុជាបានធ្វើបច្ចុប្បន្នភាពហេដ្ឋារចនាសម្ព័ន្ធផ្ទុកទិន្នន័យ ដោយងាកមកប្រើប្រាស់ដំណោះស្រាយមិនប្រើប្រាស់ខ្សែអាត់ផ្ទុកទិន្នន័យវិញ។

ដើម្បីធានាថា ទិន្នន័យនៅតែអាចប្រើប្រាស់បាន ទុកចិត្តបាន និងសុវត្ថិភាព routers ត្រូវបានដំឡើង និងមានការផ្លាស់ប្តូរម៉ូឌែល ដើម្បីគ្រប់គ្រងកុំព្យូទ័រ ឧបករណ៍ផ្ទុកទិន្នន័យ និងបណ្តាញប្រតិបត្តិការកុំព្យូទ័រក្នុងធនាគារកម្ពុ ខណៈក្រុមហ៊ុន មូលបត្រកម្ពុ ម.ក និងក្រុមហ៊ុនធានារ៉ាប់រង កម្ពុ ឡុនបាក ដែលបានបញ្ចប់ការធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី8 ខែមីនា ឆ្នាំ2024។

ធនាគារកម្ពុបានដាក់ជំនួស DellEMC SAN PowerStore 1000T ជាមួយនឹង Dell EMC PowerStore 1200T Storage Area Network (SAN) និងអនុវត្តម៉ាស៊ីនស្វ័យបម្រើថ្មី គឺម៉ាស៊ីនដកដាក់ប្រាក់ម៉ូឌែល "NCR Selfserv 62" (ប្រភេទ lobby) ដើម្បីធនាគាររក្សាការប្រកួតប្រជែង និងស្របតាមតម្រូវការទីផ្សារ។

## គំនិតផ្តួចផ្តើមនៃផលិតផល និងទីផ្សារ

ធនាគារកម្ពុបានចុះហត្ថលេខាលើភាពជាដៃគូយុទ្ធសាស្ត្ររយៈពេលប្រាំបីឆ្នាំជាមួយក្រុមហ៊ុន ធានារ៉ាប់រង អេអាយអេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ("អេអាយអេ (ខេមបូឌា)") ក្នុងឆ្នាំ2024។ អាជីវកម្មបែងការសួរេនបន្តធ្វើជាផលិតផលបង្កើតចំណូលដ៏សំខាន់មួយរបស់ធនាគារ ដែលបានលើកកម្ពស់ និងផ្តល់ជូនអតិថិជននូវផលិតផលបែងការសួរេនដ៏សំបូរបែប។

ធនាគារនឹងបន្តធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រុមហ៊ុន អេអាយអេ ខេមបូឌា ដើម្បីដាក់ចេញនូវយុទ្ធនាការនវានុវត្តន៍កាន់តែច្រើន និងបង្កើនការលក់ និងសកម្មភាពទីផ្សារ ដើម្បីកំណើនអាជីវកម្មបែងការសួរេននៅកម្ពុជា។

ស្របតាមគំនិតផ្តួចផ្តើមរបស់ធនាគារជាតិនៃកម្ពុជាក្នុងការលើកទឹកចិត្តការប្រើប្រាស់ប្រាក់រៀល និងការដាក់ដំណើរការផលិតផល និងសេវាទូទាត់ជាប្រាក់រៀលកាន់តែច្រើន ធនាគារកម្ពុក៏កំពុងដាក់ដំណើរការ និងធ្វើបច្ចុប្បន្នភាពផលិតផល និងសេវាកម្មរបស់ខ្លួនយ៉ាងសកម្ម តាមរយៈការបញ្ចូលប្រាក់រៀលទៅក្នុងលក្ខណពិសេសនៃផលិតផល។ ជាក់ស្តែងដូចជា ការដាក់ឱ្យប្រើប្រាស់សេវាទូទាត់តណទានតាមអនឡាញជាប្រាក់រៀល ដើម្បីផ្តល់ជូនសហគ្រាសអាជីវកម្មនូវភាពបត់បែនបន្ថែមសម្រាប់ការទូទាត់ទៅកាន់អ្នកផ្គត់ផ្គង់ ឬការទូទាត់ប្រាក់បៀវត្សជូនបុគ្គលិកជារូបិយប័ណ្ណជាតិ ការចូលរួមប្រព័ន្ធផ្ទេរ និងទូទាត់ប្រាក់ឆ្លងគ្រឹះស្ថានរបស់ធនាគារជាតិនៃកម្ពុជា ដែលក្នុងនោះរួមមានការទូទាត់តាម យេអេចយូអរ ទៅ យេអេចយូអរ កូដ ដែលអាចធ្វើអន្តរប្រតិបត្តិការ ព្រមទាំងការផ្អាក និងជំនួសក្រដាសប្រាក់ 10 ដុល្លារអាមេរិក ដោយក្រដាសប្រាក់ 10,000 រៀល ជាបណ្តើរៗក្នុងបណ្តាញម៉ាស៊ីនអេធីអឹម/ម៉ាស៊ីនដកដាក់ប្រាក់ទាំង 88 របស់ធនាគារកម្ពុនៅទូទាំងប្រទេស គឺជាជំហានវិជ្ជមានមួយដើម្បីលើកទឹកចិត្តការប្រើប្រាស់ប្រាក់រៀលរយៈពេលវែង។

# ប្រតិបត្តិការអាជីវកម្ម

### គំនិតផ្តួចផ្តើមនៃផលិតផល និងទីផ្សារ (តពីទំព័រមុន)

នៅក្នុងឆ្នាំ2024 ធនាគារកម្ពុបានដាក់ឱ្យដំណើរការប័ណ្ណឥណទានពាណិជ្ជកម្ម ដែលបានបង្កើតឡើងដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់សហគ្រាសខ្នាតតូច និងមធ្យម ដែលត្រូវការទុនបង្វិល និងការគ្រប់គ្រងលំហូរសាច់ប្រាក់រយៈពេលខ្លី។

នៅក្នុងឆ្នាំ2024 ធនាគារកម្ពុបានធ្វើបច្ចុប្បន្នភាពបញ្ចូលមុខងារបន្ថែមថ្មីចំនួន 13 ហើយបានបន្តផ្តល់អាទិភាពធ្វើបច្ចុប្បន្នភាពថ្នាលធ្វើប្រតិបត្តិការធនាគារតាមប្រព័ន្ធអ៊ីនធើណិត និងទូរស័ព្ទដៃ ដោយធានាផ្តល់បទពិសោធន៍អ្នកប្រើប្រាស់រលូនជាមួយនឹងមុខងារដ៏សំបូរបែប។

### ការអភិវឌ្ឍន៍ធនធានមនុស្ស

គន្លឹះដើម្បីឈានទៅរកភាពជោគជ័យ និងលទ្ធផលដ៏គួរឱ្យស្ញប់ស្ញែងរបស់ធនាគារកម្ពុ គឺបានមកពីការរួមចំណែករបស់បុគ្គលិកដែលមានការប្តេជ្ញាចិត្ត មានឆន្ទៈ និងប្រកបដោយចំណេះដឹងខ្ពស់ក្នុងការសម្រេចបាននូវឧត្តមភាពការងារជាបន្តបន្ទាប់ ។

ធនាគារកម្ពុឱ្យតម្លៃខ្ពស់លើការអភិវឌ្ឍន៍ធនធានមនុស្ស ហើយបន្តជំរុញភាពខ្លាំងរបស់បុគ្គលិកតាមរយៈការផ្តល់ជូននូវការបណ្តុះបណ្តាលដែលទូលំទូលាយ និងមានប្រសិទ្ធភាព ដើម្បីអភិវឌ្ឍជំនាញដល់បុគ្គលិករបស់ខ្លួន។ ធនាគារកម្ពុបន្តបណ្តុះបណ្តាលធនធានមនុស្សរបស់ខ្លួនតាមរយៈប្រព័ន្ធផ្តល់រង្វាន់លើការបំពេញកិច្ចការងារ ដែលជាលទ្ធផលបានបង្កើតនូវវប្បធម៌បំពេញការងារមានភាពខ្លាំងក្លាដើម្បីសម្រេចបាននូវលទ្ធផលសម្រាប់តម្រូវការអាជីវកម្មនាពេលបច្ចុប្បន្ន និងអនាគត។

ធនាគារកម្ពុបានដំណើរការផែនការស្វែងមុខតំណែងដើម្បីកំណត់អត្តសញ្ញាណ និងបង្កើតក្រុមបុគ្គលិកមានទេពកោសល្យជាមួយនឹងជំនាញ បទពិសោធន៍ត្រឹមត្រូវ និងសមត្ថភាពដឹកនាំ ដើម្បីបង្កើនកំណើនអ្នកស្នងតំណែងផ្ទៃក្នុង ព្រមទាំងរៀបចំផែនការស្នងតំណែងក្នុងមុខតំណែងដឹកនាំសំខាន់ៗក្នុងធនាគារ ដើម្បីធានាថាការរៀបចំការដឹកនាំមានស្ថិរភាពចាប់ពីមុខតំណែងមន្ត្រី រហូតដល់ផ្នែកមួយនៃតំណែងជាគណៈគ្រប់គ្រងនៅថ្ងៃណាមួយ។

ធនាគារយកចិត្តទុកដាក់តម្រូវការ និងសុខុមាលភាពបុគ្គលិកទាំងអស់។ ក្នុងការលើកកម្ពស់សុខុមាលភាពបុគ្គលិក ធនាគារកម្ពុបន្តខិតខំប្រឹងប្រែងគាំទ្របុគ្គលិករបស់ខ្លួនទាំងផ្នែកវិជ្ជាជីវៈ និងបុគ្គល តាមរយៈការទំនុកបម្រុងលើកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងផ្តល់អត្រាការប្រាក់ទាបសម្រាប់កម្ចីគេហដ្ឋាន និងយានយន្ត បូករួមទាំងផ្តល់រង្វាន់ជាដំណើរកំសាន្តទៅក្រៅប្រទេសផងដែរ។

### ការអភិវឌ្ឍន៍ធនធានមនុស្សសម្រាប់និរន្តរភាពនៃឧត្តមភាព

ចំណេះធ្វើ ជំនាញ និងឯកទេសរបស់បុគ្គលិកបន្តធ្វើជាផ្នែកមួយនៃមូលធនបញ្ញារបស់ធនាគារ។ តាមរយៈការគាំទ្រការសិក្សា និងការអភិវឌ្ឍន៍រយៈពេលវែង ធនាគារបានបង្ហាញពីការទទួលស្គាល់របស់ខ្លួនលើការបណ្តុះបណ្តាលជាចលករគន្លឹះមួយដែលបានជួយដល់ធនាគារក្នុងការសម្រេចនូវលទ្ធផលល្អលើសពីគូប្រកួតប្រជែង។

ការផ្តល់សិទ្ធិចូលសិក្សា និងការអភិវឌ្ឍន៍ជាបន្តបន្ទាប់ទាំងជំនាញប្រតិបត្តិការ និងការគ្រប់គ្រងគឺការប្តេជ្ញាចិត្តរបស់ធនាគារដើម្បីលើកកម្ពស់កម្រិតលទ្ធផលរបស់បុគ្គលិកទាំងអស់។

បុគ្គលិកដែលទើបនឹងជ្រើសរើសថ្មីត្រូវបានបង្ហាត់បង្ហាញតាមរយៈកម្មវិធីបណ្តុះបណ្តាល ដែលមានរួមបញ្ចូលនូវគុណតម្លៃសាជីវកម្ម ប្រព័ន្ធធនាគារ ដំណើរការ និងនីតិវិធីប្រតិបត្តិការ កម្មវិធីប្រឆាំងការសម្អាតប្រាក់/ហិរញ្ញប្បទានភេរវកម្ម និងទណ្ឌកម្មផ្នែកហិរញ្ញវត្ថុ និងគោលនយោបាយប្រឆាំងការស៊ីសំណូក និងពុករលួយ ដើម្បីធានាថាបុគ្គលិកទាំងអស់ត្រូវបានបំពាក់បំប៉នបានយ៉ាងល្អ ដើម្បីបំពេញតម្រូវការអតិថិជន។

# ប្រតិបត្តិការអាជីវកម្ម

## ការអភិវឌ្ឍន៍ធនធានមនុស្សសម្រាប់និរន្តរភាពនៃឧត្តមភាព (តពីទំព័រមុន)

ធនាគារកម្ពុក៏បានផ្តល់ឱកាសហាត់ការដល់និស្សិតដើម្បីទទួលបានបទពិសោធន៍ក្នុងវិស័យធនាគារ។ ស្ថិតក្នុងកម្មវិធីហាត់ការនេះ ធនាគារផ្តល់បទពិសោធន៍រៀនសូត្រ ដែលសមស្របទៅទេពកោសល្យរបស់បុគ្គលិកហាត់ការ ដោយជួយជំរុញពួកគេទទួលបាននូវបទពិសោធន៍ដ៏មានតម្លៃស្តីពីប្រតិបត្តិការធនាគារប្រចាំថ្ងៃ។ ក្នុងន័យនេះបុគ្គលិកហាត់ការដែលមានសមត្ថភាពអាចទទួលបានឱកាសបម្រើការងារនៅធនាគារ ដែលនឹងចូលរួមចំណែកអភិវឌ្ឍធនធានមនុស្សបន្ថែមទៀត។

កត្តានេះបានជំរុញ និងលើកកម្ពស់ការទទួលយកការផ្លាស់ប្តូរមុខតំណែងរបស់បុគ្គលិកនៅក្នុងធនាគារ និងបង្កើតក្រុមបុគ្គលិកដែលមានភាពស្មោះត្រង់ ជំនាញ និងចំណេះដឹង។

ខណៈដែលពិភពលោកបន្តប្រែប្រួលយ៉ាងឆាប់រហ័ស ធនាគារកម្ពុបានដាក់ចេញនូវផែនការបណ្តុះបណ្តាល និងអភិវឌ្ឍដែលនាំមកជាមួយនូវការធ្វើផែនការ និងការអនុវត្តកម្មវិធីអភិវឌ្ឍសំដៅសម្រេចបាននូវបេសកម្មរបស់ធនាគារ។ ការណ៍នេះរាប់បញ្ចូលទាំងការពង្រឹងចំណេះដឹង និងជំនាញឧស្សាហកម្មរបស់បុគ្គលិក និងការរៀបចំកម្មវិធីបណ្តុះបណ្តាលដើម្បីបំពេញតម្រូវការរបស់បុគ្គលិកដែលមានតួនាទីខុសគ្នានៅក្នុងធនាគារ។

បន្ថែមជាងនេះទៅទៀត ឱកាសសម្រាប់ពង្រីកជំនាញ និងចំណេះដឹងបន្ថែមរបស់បុគ្គលិកក៏បានផ្តល់ជូនផងដែរតាមរយៈមេរៀន និងមុខវិជ្ជាជាច្រើនមាននៅក្នុងកម្មវិធីសិក្សាតាមបណ្តាញអ៊ីនធើណិត(e-learning) របស់ធនាគារ 24 ម៉ោង។

ការបណ្តុះបណ្តាល និងការអភិវឌ្ឍន៍ក៏ត្រូវបានធ្វើឡើងនៅក្រៅប្រទេសផងដែរ។ ខណៈពេលដែលបុគ្គលិកទទួលបានការឧបត្ថម្ភសិក្សាដើម្បីទទួលវិញ្ញាបនបត្រក្នុង និងក្រៅស្រុក និងកម្មវិធីសិក្សាវិជ្ជាជីវៈ ដូចជា AICB Professional Banker, the Asain Banking School វិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ Coursera និង LinkedIn Learning។ ធនាគារ ជឿជាក់ ថាធនធានមនុស្សដែលមានសមត្ថភាពពេញលេញគឺជាកម្លាំងចលករ ដ៏សំខាន់មួយដែលជួយរុញច្រានធនាគារឈានដល់ចំណុចល្អប្រសើរជាងនេះ និងឈានដល់កម្រិតជោគជ័យថ្មីមួយទៀត។

## បង្កើនការពេញចិត្តទៅលើសេវាកម្ម

ស្របជាមួយនឹងពាក្យស្លោក"ឧត្តមភាពគឺជាការប្តេជ្ញាចិត្តរបស់យើងខ្ញុំ "បុគ្គលិកទាំងអស់ត្រូវបានជំរុញនិងលើកទឹកចិត្តឱ្យបំពេញកាតព្វកិច្ចលើសពីអ្វីដែលមានក្នុងកិច្ចសន្យាដើម្បីផ្តល់សេវាកម្មដែលចេញពីទឹកចិត្តស្រឡាញ់។ ធនាគារកម្ពុរក្សាការសង្កត់ធ្ងន់លើការផ្តល់សេវាកម្មអតិថិជនរបស់ខ្លួនដែលជាកត្តាជះឥទ្ធិពលដោយផ្ទាល់ទៅលើលទ្ធភាពរកប្រាក់ចំណេញ។ ការពេញចិត្តលើឧត្តមភាពនៃសេវាកម្មរបស់ធនាគារបានបង្ហាញយ៉ាងច្បាស់តាមរយៈការធ្វើឱ្យប្រសើរឡើងក្នុងជំនាញ និងចំណេះដឹងជាបន្តបន្ទាប់។

យុទ្ធសាស្ត្រធនធានមនុស្សរបស់ធនាគារកម្ពុតែងតែត្រូវបានតម្រែតម្រង់ ដើម្បីធ្វើឱ្យមានប្រសិទ្ធភាពលើគោលដៅអាជីវកម្មនានាដូចជាកំណើនប្រាក់ចំណូល កំណើនប្រាក់បញ្ញើ ផលិតភាពបុគ្គលិក ការបំពេញតម្រូវការអតិថិជន ការទប់ស្កាត់ចំណាយ និងការកាត់បន្ថយចំនួនបុគ្គលិកលាឈប់ ដើម្បីទទួលបានអត្ថប្រយោជន៍ប្រកួតប្រជែងសម្រាប់ធនាគារ ។

ធនាគារកម្ពុនឹងបន្តកិច្ចខិតខំប្រឹងប្រែងដើម្បីធ្វើឱ្យមានធនធានមនុស្សល្អលើសគេ ដោយធនាគារមានជំនឿថា តាមរយៈបុគ្គលិករបស់ខ្លួន ធនាគារនឹងកំណត់បាននូវកម្ពស់ថ្មីនៃឧត្តមភាព និងទទួលបាននូវកំណើនយ៉ាងឆាប់រហ័ស។

# ប្រតិបត្តិការអាជីវកម្ម

## វិស័យធនាគារ

តម្រូវការឥណទានបានធ្លាក់ចុះដោយសារបញ្ហាប្រឈមដែលមានភាពលាយលំគ្នា។ ប៉ុន្តែ នៅតែមានតម្រូវការសម្រាប់ហិរញ្ញប្បទានកម្រិតទាបទៅមធ្យមសម្រាប់ទិញគេហដ្ឋាន និងកម្ចីអាជីវកម្មសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម។

កម្រិតនៃការប្រកួតប្រជែងនៅក្នុងវិស័យធនាគារត្រូវបានរំពឹងថានឹងមានសន្ទុះកាន់តែខ្លាំងឡើង ដោយសារធនាគារផ្សេងទៀតកំពុងអនុវត្តយុទ្ធសាស្រ្តទីផ្សារដែលមានលក្ខណៈប្រកួតប្រជែងខ្លាំង ដើម្បីបង្កើនចំណែកទីផ្សាររបស់ខ្លួន។ ប៉ុន្តែ បើទោះជាមានការប្រកួតប្រជែងដែលមានលក្ខណៈខ្លាំងក្លានៅក្នុងវិស័យធនាគារក្នុងព្រះរាជាណាចក្រកម្ពុជា ធនាគារកម្ពុបានដាក់ឱ្យដំណើរការនូវយុទ្ធសាស្រ្តអាជីវកម្ម ដើម្បីពង្រីកសកម្មភាពអាជីវកម្មស្នូល ជាពិសេសគឺការផ្តល់ប្រាក់កម្ចីដល់វិស័យលក់ដុំនិងរាយ វិស័យសេវាកម្ម និងសហគ្រាសពាណិជ្ជកម្ម ជាពិសេសគឺអាជីវកម្មខ្នាតតូច និងមធ្យម ដោយប្រកាន់ភ្ជាប់នូវបទដ្ឋាន និងការអនុវត្តឥណទានប្រុងប្រយ័ត្នរបស់ខ្លួន។

# ការវិភាគរបាយការណ៍ហិរញ្ញវត្ថុ

## ការវិភាគរបាយការណ៍ប្រាក់ចំណូល

### ចំណូលការប្រាក់សុទ្ធ

ចំណូលការប្រាក់សុទ្ធរបស់ធនាគារបានកើនឡើងចំនួន 1.86% ស្មើនឹង 107.06 លានដុល្លារអាមេរិក ក្នុងឆ្នាំ2024 បើធៀបនឹងឆ្នាំ2023 មានចំនួន 105.11 លានដុល្លារអាមេរិក ដែលបន្តចូលរួមចំណែកសំខាន់សម្រាប់ប្រាក់ចំណូលសរុបរបស់ធនាគារក្នុងឆ្នាំ2024។ ការកើនឡើងនេះគឺដោយសារការកើនឡើងចំណូលការប្រាក់ពីឥណទាន។

### ចំណូលសុទ្ធលើកម្រៃជើងសា និងថ្លៃឈ្នួល

ចំណូលសុទ្ធលើកម្រៃជើងសា និងថ្លៃឈ្នួលរបស់ធនាគារបានធ្លាក់ចុះចំនួន 3.89% មកត្រឹម 9.14 លានដុល្លារអាមេរិក ក្នុងឆ្នាំ2024 បើធៀបនឹងឆ្នាំ2023 មានចំនួន 9.51 លានដុល្លារអាមេរិក។ ការធ្លាក់ចុះនេះដោយសារស្ថានភាពទីផ្សារនៅមានកម្រិតទាបនាំឱ្យកម្រៃផ្ទេរប្រាក់មានការធ្លាក់ចុះ។

### ចំណាយលើប្រតិបត្តិការផ្សេងៗ

ការចំណាយមិនមែនប្រតិបត្តិការរបស់ធនាគារកម្ពុមានចំនួន 33.23 លានដុល្លារអាមេរិក ក្នុងឆ្នាំ2024 ដែលមានចំនួន 5.19% ខ្ពស់ជាងចំណាយក្នុងឆ្នាំ2023 ចំនួន 31.59 លានដុល្លារអាមេរិក។

ធនាគារកម្ពុរក្សាអនុបាតចំណាយធៀបចំណូលល្អប្រសើរដែលមានចំនួន 27.36% ក្នុងឆ្នាំ2024 ដែលជាកម្រិតប្រសើរជាងអនុបាតចំណាយធៀបចំណូលរបស់វិស័យធនាគារមានចំនួន 49.87% ។

### ការខាតបង់ឥណទានរំពឹងទុកសម្រាប់ឥណទាន និងបុរេប្រទាន

ការខាតបង់ឥណទានរំពឹងទុកសម្រាប់ឥណទាន និងបុរេប្រទានបានធ្លាក់ចុះចំនួន 41.60% មកត្រឹម 7.61 លានដុល្លារអាមេរិក ក្នុងឆ្នាំ2024 ដែលភាគច្រើនដោយសារការធ្លាក់ចុះការខាតបង់ឥណទានរំពឹងទុក ដោយសារភាពគ្រប់គ្រាន់លើការធ្វើសំវិធានធនដែលបានផ្តល់ក្នុងឆ្នាំមុនៗ បូករួមទាំងការទូទាត់សងត្រឡប់ថេរ និងនិន្នាការនៃភាពមិនប្រក្រតីត្រូវបានតាមដាន បន្ទាប់ពីការផុតកំណត់នៃកម្មវិធីជំនួយទូទាត់សងត្រឡប់ផ្សេងៗ។

### ពន្ធលើប្រាក់ចំណេញ

ពន្ធលើប្រាក់ចំណេញសម្រាប់ឆ្នាំនេះបានកើនឡើងចំនួន 1.37 លានដុល្លារអាមេរិក ឬ 9.33% ពោលមានចំនួនកើនឡើងដល់ 16.06 លានដុល្លារអាមេរិក ដោយសារការកើនឡើងប្រាក់ចំណេញ។

ធនាគារកម្ពុបង់ពន្ធលើប្រាក់ចំណេញនៅអត្រា 20% នៃប្រាក់ចំណេញជាប់ពន្ធ។

# ការវិភាគរបាយការណ៍ហិរញ្ញវត្ថុ

## ការវិភាគតារាងតុល្យការ

### ទ្រព្យសកម្មសរុប

ទ្រព្យសកម្មសរុបរបស់ធនាគារកម្ពុមានចំនួន 2,410.48 លានដុល្លារអាមេរិក គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 ដែលជាទំហំទ្រព្យសកម្មដ៏ច្រើនបំផុតមួយក្នុងចំណោមទំហំទ្រព្យសកម្មរបស់ធនាគារធំៗនៅកម្ពុជា។

### សមតុល្យមាននៅជាមួយធនាគារជាតិនៃកម្ពុជា និងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុផ្សេងៗ

សមតុល្យមាននៅជាមួយធនាគារជាតិនៃកម្ពុជា និងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុផ្សេងៗបានកើនឡើងចំនួន 20.08% មានចំនួន 819.12 លានដុល្លារអាមេរិក គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2024។

### ឥណទាន និងបុរេប្រទាន

ឥណទាន និងបុរេប្រទានសុទ្ធរបស់ធនាគារបានកើនឡើងចំនួន 6.54% ឬស្មើនឹង 90.91 លានដុល្លារអាមេរិក ពោលគឺកើនឡើងដល់ 1,480.46 លានដុល្លារអាមេរិក ក្នុងឆ្នាំ2024។

### ទ្រព្យអកម្មសរុប និងមូលនិធិម្ចាស់ហ៊ុន

ទ្រព្យអកម្មសរុបរបស់ធនាគារកម្ពុបានកើនឡើងចំនួន 11.42% ឬស្មើនឹង 159.44 លានដុល្លារអាមេរិក ពោលគឺកើនឡើងដល់ 1,555.37 លានដុល្លារអាមេរិកនៅឆ្នាំ2024 ភាគច្រើនដោយសារការកើនឡើងនូវការដាក់ប្រាក់បញ្ញើរបស់អតិថិជន។

មូលនិធិម្ចាស់ហ៊ុនរបស់ធនាគារកម្ពុមានចំនួន 855.10 លានដុល្លារអាមេរិក គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2024។

### ប្រាក់បញ្ញើរបស់អតិថិជន

ប្រាក់បញ្ញើរបស់អតិថិជនក្នុងធនាគារកម្ពុបានកើនឡើង 10.40% មានចំនួន 1,476.46 លានដុល្លារអាមេរិកក្នុងឆ្នាំ2024។

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលរបស់ ធនាគារកម្ពុជាសាធារណៈ ភីអិលស៊ី ("ធនាគារ") បង្ហាញនូវរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ (រួមគ្នាហៅថា "ក្រុមហ៊ុនរួម") និងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែករបស់ធនាគារ (រួមបញ្ចូលគ្នាហៅថា "របាយការណ៍ហិរញ្ញវត្ថុ") នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 និង សម្រាប់ការិយបរិច្ឆេទបញ្ចប់។

## ព័ត៌មានអំពីក្រុមហ៊ុនរួម

### ធនាគារ

ធនាគារគឺជាធនាគារពាណិជ្ជដែលធ្វើប្រតិបត្តិការអាជីវកម្មដោយអនុលោមទៅតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មនៃកម្ពុជា និងស្ថិតក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជាតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៃកម្ពុជា និងអនុលោមតាមអាជ្ញាប័ណ្ណធ្វើប្រតិបត្តិការធនាគារលេខ ធ.ព.01 ដែលចេញដោយធនាគារជាតិនៃកម្ពុជា។ អាជ្ញាប័ណ្ណរបស់ធនាគារត្រូវបានធ្វើជាថ្មីនៅថ្ងៃទី28 ខែវិច្ឆិកា ឆ្នាំ2006 សម្រាប់រយៈពេលអចិន្ត្រៃយ៍ក្រោមប្រកាសរបស់ធនាគារជាតិនៃកម្ពុជាលេខ ធ7-06-207 ចុះថ្ងៃទី13 ខែកញ្ញា ឆ្នាំ2006។ ក្រោយមក អាជ្ញាប័ណ្ណរបស់ធនាគារត្រូវបានធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី7 ខែធ្នូ ឆ្នាំ2023 ស្របតាមតម្រូវការនៃលិខិតរបស់ធនាគារជាតិនៃកម្ពុជា លេខ ធ7-023-818 ចុះថ្ងៃទី20 ខែកញ្ញា ឆ្នាំ2023 ដែលបានចេញផ្សាយសម្រាប់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ស្តីពីការផ្លាស់ប្តូរអាជ្ញាប័ណ្ណក្នុងទម្រង់ថ្មី។

ធនាគារមានសកម្មភាពអាជីវកម្មចម្បងក្នុងទិដ្ឋភាពទាំងឡាយនៃមុខជំនួញធនាគារ និងការផ្តល់សេវាហិរញ្ញវត្ថុដែលពាក់ព័ន្ធ ក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការិយាល័យកណ្តាល និងសាខារបស់ធនាគារនៅក្នុងរាជធានីភ្នំពេញ និង តាមបណ្តាខេត្ត។

ទីស្នាក់ការចុះបញ្ជីរបស់ធនាគារមានទីតាំងស្ថិតនៅ អគារលេខ 23 ផ្លូវលេខ 114 សង្កាត់ផ្សារថ្មីទី2 ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

### ក្រុមហ៊ុនបុត្រសម្ព័ន្ធ

| *ឈ្មោះក្រុមហ៊ុនបុត្រសម្ព័ន្ធ* | *សកម្មភាពចម្បង* | *ប្រទេសដែលក្រុមហ៊ុនប្រតិបត្តិការ* | *ចំនួនភាគរយដែលមានប្រសិទ្ធភាពជាម្ចាស់កម្មសិទ្ធិ* | |
|---|---|---|---|---|
| | | | 2024 | 2023 |
| ក្រុមហ៊ុនធានារ៉ាប់រងកម្ពុ ឡុនប៉ាក ភីអិលស៊ី | ធានារ៉ាប់រងទូទៅ | ប្រទេសកម្ពុជា | 51% | 51% |
| ក្រុមហ៊ុន មូលបត្រ កម្ពុ ម.ក | ធានាទិញ ជួញដូរ និងជើងសាមូលបត្រ | ប្រទេសកម្ពុជា | 100% | 100% |

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

## លទ្ធផលអាជីវកម្ម និងភាគលាភ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួម និងរបស់ធនាគារមានដូចខាងក្រោម៖

| | ក្រុមហ៊ុនរួម | | ធនាគារ | |
|---|---|---|---|---|
| | *2024* | *2023* | *2024* | *2023* |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| ប្រាក់ចំណេញមុនពន្ធលើប្រាក់ចំណូល | 81,906,882 | 75,044,711 | 80,626,598 | 74,001,857 |
| ចំណាយពន្ធលើប្រាក់ចំណូល | ( 16,173,862 ) | ( 14,789,263 ) | ( 16,056,483 ) | ( 14,686,481 ) |
| **ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | **65,733,020** | **60,255,448** | **64,570,115** | **59,315,376** |
| **សមមូលពាន់រៀល** | **267,599,124** | **247,649,892** | **262,864,938** | **243,786,194** |
| **ត្រូវបែងចែកដូចខាងក្រោម៖** | | | | |
| ភាគទុនិករបស់ធនាគារ | 65,226,839 | 59,827,587 | 64,570,115 | 59,315,376 |
| ភាគកម្មអប្បភាគ | 506,181 | 427,861 | - | - |
| | **65,733,020** | **60,255,448** | **64,570,115** | **59,315,376** |

## ដើមទុនបានបង់

ពុំមានការប្រែប្រួលទៅលើដើមទុនបានបង់របស់ក្រុមហ៊ុនរួម និងធនាគារ ក្នុងការិយបរិច្ឆេទនោះទេ។

## ទុនបម្រុង និងសំវិធានធន

ពុំមានការផ្លាស់ប្តូរជាសារវន្តទៅកាន់ ឬពីគណនីទុនបម្រុង និងសំវិធានធនសម្រាប់ការិយបរិច្ឆេទក្រៅពីអ្វីដែលបានលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះទេ។

## សំវិធានធនលើការខាតបង់ឥណទានរំពឹងទុកលើឥណទាន និងបុរេប្រទាន

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួម និងរបស់ធនាគារត្រូវបានរៀបចំឡើង អភិបាលបានចាត់វិធានការសមស្របនានា ដើម្បីឈានដល់ការអះអាងថា នីតិវិធីពាក់ព័ន្ធជាមួយនឹងការលុបបំបាត់ចោលឥណទានអាក្រក់ ឬការទទួលស្គាល់សំវិធានធនសម្រាប់ការខាតបង់ឥណទានរំពឹងទុកលើឥណទាន និងបុរេប្រទាន ហើយអភិបាលជឿជាក់ថារាល់ឥណទាន និងបុរេប្រទានអាក្រក់ ដែលបានដឹងត្រូវបានលុបបំបាត់ចោល និងត្រូវបានផ្តល់សំវិធានធនសមស្របសម្រាប់ការខាតបង់ឥណទានរំពឹងទុក។

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ អភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលអាចបណ្តាលឱ្យចំនួនទឹកប្រាក់នៃឥណទាន និងបុរេប្រទានអាក្រក់ដែលបានលុបចេញពីបញ្ជី ឬចំនួនទឹកប្រាក់សំវិធានធនសម្រាប់ការខាតបង់ឥណទានរំពឹងទុកចំពោះឥណទាន និងបុរេប្រទានក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួម និងធនាគារមិនគ្រប់គ្រាន់រហូតដល់ដំណាក់កាលជាសារវន្តនោះទេ។

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

## ទ្រព្យសកម្ម

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួម និងធនាគារ ត្រូវបានរៀបចំឡើង អភិបាលបានចាត់វិធានការសមស្រប ដើម្បីធានាថាទ្រព្យសកម្ម ដែលមិនអាចលក់បានតាមប្រតិបត្តិការអាជីវកម្មធម្មតាក្នុងតម្លៃដែលបានបង្ហាញនៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុនរួម និងធនាគារ ត្រូវបានកាត់បន្ថយឱ្យនៅស្មើនឹងតម្លៃដែលរំពឹងថានឹងអាចលក់បាន។

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ អភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងធ្វើឱ្យប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្មនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួម និងធនាគារ ថាមានភាពមិនត្រឹមត្រូវរហូតដល់ដំណាក់កាលជាសារវន្តនោះទេ។

## វិធីសាស្រ្តនៃការវាយតម្លៃ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ អភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើង ហើយអាចនឹងធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តវិធីសាស្រ្តកន្លងមកក្នុងការវាយតម្លៃនៃទ្រព្យសកម្ម និងទ្រព្យអកម្មនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួម និងធនាគារមានភាពមិនត្រឹមត្រូវ ឬមិនសមស្របរហូតដល់ដំណាក់កាលជាសារវន្តនោះទេ។

## យថាភាព និងទ្រព្យអកម្មផ្សេងៗ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ៖

- ពុំមានការដាក់បញ្ចាំទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុនរួម និងធនាគារដែលកើតមានឡើងនៅចុងការិយបរិច្ឆេទហិរញ្ញវត្ថុសម្រាប់ធានាចំពោះទ្រព្យអកម្មរបស់បុគ្គលណាមួយ និង
- ពុំមានទ្រព្យអកម្មយថាភាពណាមួយកើតមានឡើងចំពោះក្រុមហ៊ុនរួម និងធនាគារចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុក្រៅពីប្រតិបត្តិការអាជីវកម្មធម្មតា។

តាមមតិរបស់អភិបាលពុំមានទ្រព្យអកម្មយថាភាព ឬទ្រព្យអកម្មផ្សេងៗទៀតរបស់ក្រុមហ៊ុនរួម និងរបស់ធនាគារដែលអាច ឬទំនងក្លាយជាកាតព្វកិច្ចក្នុងអំឡុងរយៈពេលដប់ពីរខែ បន្ទាប់ពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះដែលនឹង ឬអាចប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុនរួម ឬធនាគារ ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅពេលទ្រព្យអកម្មទាំងនោះដល់កាលកំណត់សងនោះទេ។

## ព្រឹត្តិការណ៍បន្តបន្ទាប់

ពុំមានព្រឹត្តិការណ៍សំខាន់ណាបានកើតឡើង ក្រោយពីកាលបរិច្ឆេទរាយការណ៍ដែលតម្រូវឱ្យមានការលាតត្រដាង ឬការធ្វើនិយ័តកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុនោះទេ។

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលនៅក្នុងការិយបរិច្ឆេទ និងនាកាលបរិច្ឆេទនៃរបាយការណ៍នេះមាននាមដូចខាងក្រោម៖

| | |
|---|---|
| Dato' Mohammed Najeeb Bin Abdullah | ប្រធានក្រុមប្រឹក្សាភិបាលឯករាជ្យ និងមិនប្រតិបត្តិ |
| លោក Quah Poh Keat | អភិបាលមិនឯករាជ្យ និងមិនប្រតិបត្តិ |
| Dato' Chang Kat Kiam | អភិបាលមិនឯករាជ្យ និងមិនប្រតិបត្តិ |
| បណ្ឌិត ផៃ ទូច | អភិបាលឯករាជ្យ និងមិនប្រតិបត្តិ |
| លោក អុង មឹងតិច | អភិបាលប្រតិបត្តិ |

## សវនករ

ក្រុមហ៊ុនសវនកម្មឯករាជ្យ អ៊ីនស្ទ៍ អ៊ែន យ៉ាំង (ខេមបូឌា) គឺជាសវនកររបស់ក្រុមហ៊ុនរួម និងធនាគារ។

ប្រាក់កម្រៃរបស់សវនករលើសេវាកម្ម ដែលបានផ្ដល់ឱ្យទៅក្រុមហ៊ុនរួមក្នុងអំឡុងការិយបរិច្ឆេទបញ្ចប់ ឆ្នាំ2024 និងឆ្នាំ2023 មានដូចតទៅ៖

| | *2024* | | *2023* | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល | ដុល្លារអាមេរិក | សមមូលពាន់រៀល |
| សេវាសវនកម្ម | 147,000 | 598,437 | 121,100 | 497,721 |
| សេវាមិនមែនសវនកម្ម | - | - | 1,500 | 6,165 |
| សរុប | **147,000** | **598,437** | **122,600** | **503,886** |

## ភាគហ៊ុនកាន់កាប់របស់អភិបាល

ពុំមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់មានភាគហ៊ុនក្នុងក្រុមហ៊ុនរួម និងធនាគារទេ។

## អត្ថប្រយោជន៍របស់អភិបាល

គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 ពុំមានការព្រមព្រៀងណាមួយដែលមានក្រុមហ៊ុនរួម ឬធនាគារចូលរួមជាភាគីក្នុងគោលបំណងជួយដល់អភិបាលរបស់ធនាគារដើម្បីទទួលបាននូវអត្ថប្រយោជន៍តាមរយៈការទិញភាគហ៊ុន ឬ លិខិតទ្រព្យអកម្មពីក្រុមហ៊ុនរួម ឬធនាគារ ឬពីក្រុមហ៊ុនដទៃទៀតឡើយ។

ពុំមានអភិបាលណាមួយរបស់ធនាគារ ដែលបានទទួល ឬមានសិទ្ធិនឹងទទួលបាននូវអត្ថប្រយោជន៍ណាមួយ តាមរយៈការចុះកិច្ចសន្យាដែលបានធ្វើឡើងដោយក្រុមហ៊ុនរួម ឬធនាគារ ឬជាមួយនឹងក្រុមហ៊ុនដែលក្រុមប្រឹក្សាភិបាលនោះជាសមាជិក ឬក៏ជាមួយក្រុមហ៊ុនដែលក្រុមប្រឹក្សាភិបាលនោះមានផលប្រយោជន៍ហិរញ្ញវត្ថុជាសារវន្ត ក្រៅពីប្រតិបត្តិការ ដូចបានលាតត្រដាងក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះទេ។

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

## របាយការណ៍ស្តីពីការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលចំពោះរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលជាអ្នកទទួលខុសត្រូវក្នុងការបញ្ជាក់ថារបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងយ៉ាងត្រឹមត្រូវដើម្បីបង្ហាញនូវទិដ្ឋភាពពិតប្រាកដ និងត្រឹមត្រូវលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួម និងធនាគារនាថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 និងលទ្ធផលហិរញ្ញវត្ថុហើយនិងស្ថានភាពលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់ដោយអនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("CIFRSs") ជាមួយនឹងការពន្យារពេលអនុវត្ត CIFRS 17 - *កិច្ចសន្យាធានារ៉ាប់រង* ដែលស្របតាមការជូនដំណឹង និងអនុម័តរបស់និយ័តករគណនេយ្យ និងសវនកម្ម ("CIFRSs ជាមួយនឹងការពន្យារពេលអនុវត្ត CIFRS 17")។ ក្រុមប្រឹក្សាភិបាលត្រួតពិនិត្យលើការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់គណៈគ្រប់គ្រងដែលបានតម្រូវឱ្យ៖

i) អនុម័តនូវគោលនយោបាយគណនេយ្យសមស្រប ដែលផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្នហើយត្រូវអនុវត្តគោលនយោបាយទាំងនេះជាអចិន្ត្រៃយ៍។

ii) អនុលោមតាម CIFRSs ជាមួយនឹងការពន្យារពេលអនុវត្ត CIFRS 17 ឬប្រសិនបើមានការប្រាសចាកគម្លាតក្នុងគោលបំណងបង្ហាញព័ត៌មានឱ្យត្រឹមត្រូវ ការប្រាសចាកទាំងនោះត្រូវបានលាតត្រដាង បកស្រាយ និងកំណត់ចំនួនទឹកប្រាក់ដោយសមស្របក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

iii) រក្សាទុកបញ្ជីគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព។

IV) រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លើកលែងតែមានករណីមិនសមរម្យក្នុងការសន្មតថា ក្រុមហ៊ុនរួម និងធនាគារ នឹងមិនបន្តធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួននាពេលអនាគត និង

V) ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនរួម និងធនាគារប្រកបដោយប្រសិទ្ធភាពលើការសម្រេចជាសារវន្ត ដែលអាចប៉ះពាល់ដល់ប្រតិបត្តិការ និងលទ្ធផលហើយត្រូវប្រាកដថាកិច្ចការទាំងនេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

គណៈគ្រប់គ្រងជាអ្នកទទួលខុសត្រូវ ដើម្បីធានាថាបញ្ជីគណនេយ្យមានភាពត្រឹមត្រូវ ហើយត្រូវបានរក្សាទុក និងលាតត្រដាងអំពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួម និងធនាគារឱ្យបានត្រឹមត្រូវ សមហេតុផលគ្រប់ពេល និងធានាថាបញ្ជីគណនេយ្យស្របតាមប្រព័ន្ធគណនេយ្យដែលបានចុះបញ្ជី។ គណៈគ្រប់គ្រង ក៏ជាអ្នកទទួលខុសត្រូវក្នុងការថែរក្សាទ្រព្យសកម្មរបស់ក្រុមហ៊ុនរួម និងធនាគារ ហើយក៏ត្រូវចាត់វិធានការសមស្របដើម្បីទប់ស្កាត់ និងស្វែងរកកំហុសចេតនា និងភាពមិនប្រក្រតីផ្សេងៗ។

ក្រុមប្រឹក្សាភិបាលបញ្ជាក់ថា ក្រុមហ៊ុនរួម និងធនាគារបានអនុវត្តតាមលក្ខខណ្ឌតម្រូវចាំបាច់នានា ដូចដែលបានបញ្ជាក់ខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

យើងខ្ញុំ ដែលជាក្រុមប្រឹក្សាភិបាល អនុម័តលើរបាយការណ៍ហិរញ្ញវត្ថុដូចដែលមានភ្ជាប់ជាមួយទាំងនេះដែលបានបង្ហាញនូវទិដ្ឋភាពពិតប្រាកដ និងត្រឹមត្រូវទៅលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួម និងធនាគារនាថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 និងលទ្ធផលនៃប្រតិបត្តិការហិរញ្ញវត្ថុ ហើយនិងស្ថានភាពលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់ដោយអនុលោមទៅតាម CIFRSs ជាមួយនឹងការពន្យារពេលអនុវត្ត CIFRS 17។

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

**ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ** (តពីទំព័រមុន)

តំណាងក្រុមប្រឹក្សាភិបាល




| | |
|---|---|
| Dato' Mohammed Najeeb Bin Abdullah | Quah Poh Keat |
| ប្រធានក្រុមប្រឹក្សាភិបាលមិនប្រតិបត្តិឯករាជ្យ | អភិបាលមិនប្រតិបត្តិមិនឯករាជ្យ |

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី26 ខែកុម្ភៈ ឆ្នាំ2025

# របាយការណ៍របស់សវនករឯករាជ្យ

## ជូនចំពោះ៖ ភាគទុនិក នៃធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី

### មតិយោបល់

យើងខ្ញុំ បានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ធនាគារកម្ពុជាសាធារណៈ ភីអិលស៊ី ("ធនាគារ") និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួន (រួមគ្នាហៅថា "ក្រុមហ៊ុនរួម") និងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែករបស់ធនាគារ ដែលមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរួម និងដាច់ដោយឡែក នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 និងរបាយការណ៍លទ្ធផលរួម និងដាច់ដោយឡែក របាយការណ៍បម្រែបម្រួលមូលធនរួម និងដាច់ដោយឡែក ព្រមទាំងរបាយការណ៍លំហូរសាច់ប្រាក់រួម និងដាច់ដោយឡែក សម្រាប់ការិយបរិច្ឆេទបញ្ចប់ ហើយនិងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែកនោះ ដែលរួមមានគោលនយោបាយគណនេយ្យជាសារវន្ត (រួមគ្នាហៅថា "របាយការណ៍ហិរញ្ញវត្ថុ")។

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែកទាំងនេះ បង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួម និងធនាគារ នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុរួម និងដាច់ដោយឡែក ហើយនិងលំហូរសាច់ប្រាក់រួម និងដាច់ដោយឡែក សម្រាប់ការិយបរិច្ឆេទបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("CIFRSs") ជាមួយនឹងការពន្យារពេលអនុវត្ត CIFRS 17 - *កិច្ចសន្យាធានារ៉ាប់រង* ស្របតាមការជូនដំណឹង និងអនុម័តរបស់និយ័តករគណនេយ្យ និងសវនកម្ម ("CIFRSs ជាមួយនឹងការពន្យារពេលអនុវត្ត CIFRS 17")។

### មូលដ្ឋានក្នុងការផ្តល់មតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដាអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា ("CISAs")។

ការទទួលខុសត្រូវរបស់យើងខ្ញុំ យោងតាមស្តង់ដាទាំងនោះ ត្រូវបានបរិយាយបន្ថែមនៅក្នុងផ្នែកនៃ*ការទទួលខុសត្រូវរបស់សវនករចំពោះការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ*នៃរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំមានភាពឯករាជ្យពីក្រុមហ៊ុនរួម និងធនាគារ ដោយអនុលោមទៅតាមក្រមសីលធម៌វិជ្ជាជីវៈរបស់គណនេយ្យករ និងសវនករប្រតិស្រុតដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃកម្ពុជា ជាមួយនឹងតម្រូវការខាងសីលធម៌ដែលទាក់ទងទៅនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុនៅព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំក៏បានបំពេញនូវទំនួលខុសត្រូវខាងសីលធម៌ផ្សេងទៀតរបស់យើងខ្ញុំ ដោយស្របទៅតាមតម្រូវការទាំងនេះ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំបានទទួលមានលក្ខណៈគ្រប់គ្រាន់ និងសមស្រប ដើម្បីជាមូលដ្ឋានសម្រាប់មតិយោបល់របស់យើងខ្ញុំ។

### ការសង្កត់លើបញ្ហា-មូលដ្ឋាននៃគណនេយ្យ

យើងខ្ញុំទាញចំណាប់អារម្មណ៍ទៅលើកំណត់សម្គាល់លេខ 2.2 លើរបាយការណ៍ហិរញ្ញវត្ថុ ដែលពិពណ៌នាអំពីការណែនាំលើការពន្យារពេលក្នុងការអនុវត្ត CIFRS 17។ មតិយោបល់របស់យើងខ្ញុំពុំត្រូវបានកែប្រែឡើយទាក់ទងទៅនឹងបញ្ហានេះ។

### ព័ត៌មានផ្សេងទៀតក្រៅពីរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍របស់សវនករ

ព័ត៌មានផ្សេងទៀតដែលទទួលបាន នាកាលបរិច្ឆេទនៃរបាយការណ៍របស់សវនករ រួមមានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល។ គណៈគ្រប់គ្រងមានទំនួលខុសត្រូវ ចំពោះព័ត៌មានផ្សេងៗនេះ។

មតិយោបល់របស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ពុំគ្របដណ្តប់លើព័ត៌មានផ្សេងៗនេះទេ ហើយយើងខ្ញុំក៏មិនបង្ហាញក្នុងទម្រង់ណាមួយនៃសេចក្តីសន្និដ្ឋានធានាអះអាងទៅលើព័ត៌មានផ្សេងៗនេះដែរ។

# របាយការណ៍របស់សវនករឯករាជ្យ

### ព័ត៌មានផ្សេងទៀតក្រៅពីរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍របស់សវនករ (តពីទំព័រមុន)

ទាក់ទិននឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ទំនួលខុសត្រូវរបស់យើងខ្ញុំ គឺអានព័ត៌មានផ្សេងៗនេះ ហើយធ្វើការពិចារណាថាតើព័ត៌មានផ្សេងៗនេះមានភាពខុសគ្នាជាសារវន្តជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុ ឬចំណេះដឹងរបស់យើងខ្ញុំដែលទទួលបាននៅក្នុងការងារសវនកម្ម ឬថាតើព័ត៌មានផ្សេងៗនេះមានកំហុសឆ្គងសារវន្ត ឬទេ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងសារវន្តលើព័ត៌មានផ្សេងៗនេះ ដោយផ្អែកលើការងារដែលបានអនុវត្ត យើងខ្ញុំត្រូវតម្រូវឱ្យរាយការណ៍តាមភាពជាក់ស្តែង។

យើងខ្ញុំពុំមានអ្វីត្រូវរាយការណ៍ចំពោះព័ត៌មានផ្សេងៗនេះទេ។

### ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង និងអ្នកទទួលបន្ទុកលើអភិបាលកិច្ចចំពោះរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រង ជាអ្នកទទួលខុសត្រូវចំពោះការរៀបចំ និងការបង្ហាញទិដ្ឋភាពពិត និងត្រឹមត្រូវ នៃរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមទៅតាម CIFRSs ជាមួយនឹងការពន្យារពេលអនុវត្ត CIFRS 17 និងទទួលខុសត្រូវផងដែរចំពោះប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងគិតថាមានសារៈប្រយោជន៍ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលពុំមានកំហុសឆ្គងសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬការភាន់ច្រឡំ។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រង ជាអ្នកទទួលខុសត្រូវក្នុងការវាយតម្លៃលទ្ធភាពនិរន្តរភាពអាជីវកម្មរបស់ក្រុមហ៊ុនរួម និងធនាគារ និងធ្វើការលាតត្រដាង (ប្រសិនបើមាន) នូវបញ្ហាទាំងឡាយណាដែលទាក់ទងនឹងនិរន្តរភាពអាជីវកម្ម និងការប្រើប្រាស់មូលដ្ឋាននិរន្តរភាពអាជីវកម្មនៅក្នុងប្រព័ន្ធគណនេយ្យរបស់ក្រុមហ៊ុនរួម និងធនាគារ លើកលែងតែក្នុងករណីគណៈគ្រប់គ្រងមានបំណងរំលាយ ឬបញ្ឈប់ប្រតិបត្តិការក្រុមហ៊ុនរួម និងធនាគារ ឬក៏គ្មានមធ្យោបាយជាក់លាក់ណាមួយទៀតក្រៅពីនេះ។

អ្នកទទួលបន្ទុកលើអភិបាលកិច្ច មានទំនួលខុសត្រូវក្នុងការត្រួតពិនិត្យមើលលើដំណើរ នៃការរាយការណ៍អំពីហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួម និងធនាគារ។

### ការទទួលខុសត្រូវរបស់សវនករចំពោះសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបាននូវការធានាអះអាងដែលសមហេតុផលថា របាយការណ៍ហិរញ្ញវត្ថុទាំងមូលមិនមានកំហុសឆ្គងសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬការភាន់ច្រឡំ ហើយធ្វើការចេញផ្សាយរបាយការណ៍របស់សវនករដែលរួមមានមតិយោបល់របស់យើងខ្ញុំ។ ការធានាអះអាងដែលសមហេតុផល គឺជាការធានាអះអាងកម្រិតខ្ពស់មួយ ប៉ុន្តែមិនមែនជាការធានាថាការងារសវនកម្មដែលប្រព្រឹត្តទៅដោយអនុលោមតាម CISAs តែងតែរកឃើញកំហុសឆ្គងសារវន្តដែលមាននោះទេ។ កំហុសឆ្គងអាចកើតចេញពីការក្លែងបន្លំ ឬការភាន់ច្រឡំ និងត្រូវបានចាត់ទុកថាសារវន្តប្រសិនបើកំហុសឆ្គងទាំងអស់នោះ (តែមួយ ឬបញ្ចូលគ្នាជារួម) អាចមានឥទ្ធិពលលើការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ដោយផ្អែកលើមូលដ្ឋានរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

ជាផ្នែកមួយនៃការងារសវនកម្មដែលអនុលោមតាម CISAs យើងខ្ញុំ បានធ្វើការវិនិច្ឆ័យ និងរក្សានូវចម្ងល់ប្រកបដោយវិជ្ជាជីវៈក្នុងដំណើរការសវនកម្ម។ យើងខ្ញុំក៏បាន៖

- កំណត់ និងវាយតម្លៃហានិភ័យនៃកំហុសឆ្គងជាសារវន្ត នៃរបាយការណ៍ហិរញ្ញវត្ថុ ដែលបណ្តាលមកពីការក្លែងបន្លំ ឬការភាន់ច្រឡំ បង្កើត និងអនុវត្តនីតិវិធីសវនកម្ម ដែលឆ្លើយតបទៅនឹងហានិភ័យទាំងនោះ ហើយប្រមូលភស្តុតាងសវនកម្មឱ្យបានគ្រប់គ្រាន់ និងសមស្របសម្រាប់ផ្តល់ជាមូលដ្ឋានក្នុងការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញកំហុសឆ្គងសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំមានកម្រិតខ្ពស់ជាង ហានិភ័យដែលមិនអាចរកឃើញកំហុសឆ្គង ដែលបណ្តាលមកពីការភាន់ច្រឡំ ព្រោះថាការក្លែងបន្លំអាចពាក់ព័ន្ធនឹងការឃុបឃិត ការបន្លំ ការលុបចេញដោយចេតនាការរាយការណ៍មិនត្រឹមត្រូវ ឬមិនគោរពតាមប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។

# របាយការណ៍របស់សវនករឯករាជ្យ

## ការទទួលខុសត្រូវរបស់សវនករចំពោះសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

- ស្វែងយល់អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធនឹងការងារសវនកម្មដើម្បីបង្កើតជានីតិវិធីសវនកម្ម ដែលសមស្រប ទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនសម្រាប់គោលបំណងដើម្បីបញ្ចេញមតិយោបល់លើប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុនរួម និងធនាគារទេ។

- វាយតម្លៃភាពសមស្របនៃគោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ និងការបង្ហាញដែលជាប់ទាក់ទងផ្សេងទៀតដែលធ្វើឡើងដោយគណៈគ្រប់គ្រង។

- ធ្វើសេចក្តីសន្និដ្ឋានទៅលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាពអាជីវកម្ម នៅក្នុងប្រព័ន្ធគណនេយ្យដោយគណៈគ្រប់គ្រង និងតាមរយៈភស្តុតាងសវនកម្មដែលទទួលបាន យើងខ្ញុំធ្វើការសន្និដ្ឋាន ថាតើមានវត្តមាននៃភាពមិនប្រាកដប្រជាសារវន្តទាក់ទងនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌទាំងឡាយណាដែលនាំឱ្យមានការសង្ស័យសារវន្តទៅលើនិរន្តរភាពនៃដំណើរការអាជីវកម្មរបស់ក្រុមហ៊ុនរួម និងធនាគារ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានវត្តមាននៃភាពមិនប្រាកដប្រជាសារវន្ត យើងខ្ញុំតម្រូវឲ្យទាញចំណាប់អារម្មណ៍ក្នុងរបាយការណ៍សវនករលើកំណត់សម្គាល់ដែលពាក់ព័ន្ធដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើកំណត់សម្គាល់នេះពុំមានលក្ខណៈគ្រប់គ្រាន់ទេនោះ យើងខ្ញុំនឹងធ្វើការកែប្រែមតិយោបល់របស់យើងខ្ញុំ។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺពឹងផ្អែកលើភស្តុតាងសវនកម្មដែលទទួលបានរហូតដល់ថ្ងៃចេញរបាយការណ៍សវនករ។ តែទោះជាយ៉ាងណាក៏ដោយព្រឹត្តិការណ៍ និងលក្ខខណ្ឌនាពេលអនាគតក៏អាចបង្កឱ្យក្រុមហ៊ុនរួម ឬធនាគារមិនអាចបន្តនិរន្តរភាពអាជីវកម្មបានផងដែរ។

- វាយតម្លៃការដាក់បង្ហាញ ទម្រង់ និងមាតិកាទាំងស្រុងនៃរបាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលទាំងកំណត់សម្គាល់ផ្សេងៗ និងវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុតំណាងឲ្យប្រតិបត្តិការណ៍ និងព្រឹត្តិការណ៍ដែលជាមូលដ្ឋាន ដើម្បីសម្រេចបាននូវការបង្ហាញដ៏ត្រឹមត្រូវ។

- ប្រមូលភស្តុតាងសវនកម្ម ដែលសមស្រប និងគ្រប់គ្រាន់ អំពីព័ត៌មានហិរញ្ញវត្ថុរបស់អង្គភាព ឬ សកម្មភាពអាជីវកម្មនៅក្នុងក្រុមហ៊ុនរួម ដើម្បីបញ្ចេញមតិយោបល់លើរបាយការណ៍ហិរញ្ញវត្ថុរួម។ យើងខ្ញុំមានទំនួលខុសត្រូវចំពោះការដឹកនាំការត្រួតពិនិត្យ និងការអនុវត្តន៍នៃការងារសវនកម្មជាក្រុម។ យើងខ្ញុំមានទំនួលខុសត្រូវទាំងស្រុងចំពោះមតិយោបល់សវនកម្មរបស់យើងខ្ញុំ។

ក្នុងចំណោមបញ្ហាដទៃទៀត យើងខ្ញុំបានធ្វើការទំនាក់ទំនងជាមួយអ្នកទទួលបន្ទុកលើអភិបាលកិច្ចអំពីវិសាលភាព និងពេលវេលាដែលបានគ្រោងទុកនៃការងារសវនកម្ម និងរបកគំហើញសំខាន់ៗ ដែលរួមបញ្ចូលផងដែរនូវកង្វះខាតសំខាន់ៗទៅលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលយើងខ្ញុំរកឃើញក្នុងពេលធ្វើសវនកម្ម។



ឡូន ស៊ីនរតនា
ដៃគូសវនករ

អឺនស្ទ៍ អ៊ែន យ៉ាំង (ខេមបូឌា)

ក្រុមហ៊ុនគណនេយ្យករជំនាញ

សវនករប្រតិស្រុត

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី26 ខែកុម្ភៈ ឆ្នាំ2025

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុរួម

| | កំណត់សម្គាល់ | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5) |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | 3 | 62,985,363 | 253,516,086 | 62,527,987 | 255,426,827 |
| សមតុល្យជាមួយធនាគារជាតិនៃកម្ពុជា | 4 | 265,302,094 | 1,067,840,928 | 237,600,094 | 970,596,384 |
| សមតុល្យជាមួយធនាគារផ្សេងៗ និងគ្រឹះស្ថានហិរញ្ញវត្ថុ | 5 | 576,145,559 | 2,318,985,875 | 461,073,995 | 1,883,487,270 |
| ឥណទាន និងបុរេប្រទាន | 6 | 1,480,461,184 | 5,958,856,266 | 1,389,551,470 | 5,676,317,755 |
| វិនិយោគក្នុងក្រុមហ៊ុនសម្ព័ន្ធញាតិ | 8 | 3,920 | 15,778 | 3,920 | 16,013 |
| ទ្រព្យ និងបរិក្ខារ | 9 | 9,823,734 | 39,540,529 | 11,532,731 | 47,111,206 |
| សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម | 10 | 8,010,356 | 32,241,683 | 7,301,691 | 29,827,408 |
| កម្មវិធីកុំព្យូទ័រ | 11 | 62,183 | 250,287 | 220,211 | 899,562 |
| ពន្ធពន្យារជាទ្រព្យសកម្ម - សុទ្ធ | 15.3 | 3,007,354 | 12,104,600 | 2,929,165 | 11,965,639 |
| ទ្រព្យសកម្មផ្សេងៗ | 12 | 23,924,036 | 96,294,245 | 23,329,511 | 95,301,052 |
| **ទ្រព្យសកម្មសរុប** | | **2,429,725,783** | **9,779,646,277** | **2,196,070,775** | **8,970,949,116** |
| **ទ្រព្យអកម្ម និងមូលធន** | | | | | |
| **ទ្រព្យអកម្ម** | | | | | |
| ប្រាក់បញ្ញើពីធនាគារផ្សេងៗ និងគ្រឹះស្ថានហិរញ្ញវត្ថុ | 13 | 31,182,125 | 125,508,053 | 15,915,608 | 65,015,259 |
| ប្រាក់បញ្ញើពីអតិថិជន | 14 | 1,464,118,701 | 5,893,077,772 | 1,320,694,106 | 5,395,035,423 |
| បំណុលពន្ធលើប្រាក់ចំណូល | 15.2 | 14,468,818 | 58,236,992 | 13,182,538 | 53,850,668 |
| បំណុលភតិសន្យា | 17 | 9,855,465 | 39,668,247 | 9,124,494 | 37,273,558 |
| ទ្រព្យអកម្មផ្សេងៗ | 16 | 36,587,634 | 147,265,227 | 29,374,009 | 119,992,826 |
| **ទ្រព្យអកម្មសរុប** | | **1,556,212,743** | **6,263,756,291** | **1,388,290,755** | **5,671,167,734** |

*កំណត់សម្គាល់ដែលមានភ្ជាប់ជាមួយពីទំព័រ 64 ដល់ 187 គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។*

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុរួម

| | កំណត់សម្គាល់ | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5) |
| **មូលធន** | | | | | |
| ដើមទុនបានបង់ | 18 | 90,000,000 | 360,000,000 | 90,000,000 | 360,000,000 |
| ទុនបម្រុងមិនអាចបែងចែកបាន | 18 | 250,000,000 | 1,006,250,000 | 250,000,000 | 1,021,250,000 |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | | 31,171,051 | 125,463,480 | 21,074,536 | 86,089,480 |
| ប្រាក់ចំណេញរក្សាទុក | | 491,003,459 | 1,993,927,604 | 435,873,135 | 1,769,492,056 |
| លម្អៀងបង្គរពីការប្តូររូបិយប័ណ្ណ | | - | (15,388,681) | - | 18,699,700 |
| **មូលធនដែលកំណត់ថាជារបស់ម្ចាស់មូលធនធនាគារ** | | **862,174,510** | **3,470,252,403** | **796,947,671** | **3,255,531,236** |
| ភាគកម្មអប្បភាគ | | 11,338,530 | 46,012,881 | 10,832,349 | 43,952,218 |
| លម្អៀងបង្គរពីការប្តូររូបិយប័ណ្ណ | | - | (375,298) | - | 297,928 |
| **សរុបមូលធន** | | **873,513,040** | **3,515,889,986** | **807,780,020** | **3,299,781,382** |
| **ទ្រព្យអកម្ម និងមូលធនសរុប** | | **2,429,725,783** | **9,779,646,277** | **2,196,070,775** | **8,970,949,116** |

*កំណត់សម្គាល់ដែលមានភ្ជាប់ជាមួយពីទំព័រ 64 ដល់ 187 គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។*

# របាយការណ៍លទ្ធផលពេញលេញរួម

| | *កំណត់សម្គាល់* | *2024* | | *2023* | |
|---|---|---|---|---|---|
| | | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់លេខ 2.5)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់លេខ 2.5)* |
| ចំណូលការប្រាក់គណនាតាមវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព | 19 | 134,608,977 | 547,993,145 | 126,226,003 | 518,788,872 |
| ចំណាយការប្រាក់ | 20 | (25,976,105) | (105,748,723) | (19,876,147) | (81,690,964) |
| **ចំណូលការប្រាក់សុទ្ធ** | | **108,632,872** | **442,244,422** | **106,349,856** | **437,097,908** |
| ចំណូលថ្លៃឈ្នួល និងកម្រៃជើងសា | 21 | 10,119,528 | 41,196,598 | 10,727,824 | 44,091,357 |
| ចំណាយថ្លៃឈ្នួល និងកម្រៃជើងសា | 21 | (1,110,995) | (4,522,861) | (1,330,779) | (5,469,502) |
| **ចំណូលថ្លៃឈ្នួល និងកម្រៃជើងសាសុទ្ធ** | 21 | **9,008,533** | **36,673,737** | **9,397,045** | **38,621,855** |
| ចំណូលសុទ្ធពីសកម្មភាពធានារ៉ាប់រង | | 1,270,970 | 5,174,119 | 1,315,834 | 5,408,078 |
| សំវិធានធនសម្រាប់ការខាតបង់បានរំពឹងទុក | 22 | (7,421,257) | (30,211,937) | (13,058,805) | (53,671,689) |
| ចំណូលប្រតិបត្តិការផ្សេងៗ | 23 | 5,135,932 | 20,908,379 | 3,871,088 | 15,910,172 |
| **ចំណាយប្រតិបត្តិការផ្សេងៗសុទ្ធ** | | **(1,014,355)** | **(4,129,439)** | **(7,871,883)** | **(32,353,439)** |
| ចំណាយប្រតិបត្តិការផ្សេងៗ | 24 | (34,720,168) | (141,345,804) | (32,830,307) | (134,932,561) |
| **ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល** | | **81,906,882** | **333,442,916** | **75,044,711** | **308,433,763** |
| ចំណាយពន្ធលើប្រាក់ចំណូល | 15.1 | (16,173,862) | (65,843,792) | (14,789,263) | (60,783,871) |
| **ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | | **65,733,020** | **267,599,124** | **60,255,448** | **247,649,892** |
| ចំណូលលម្អិតផ្សេងៗ៖ | | | | | |
| *ធាតុដែលនឹងមិនចាត់ថ្នាក់ឡើងវិញទៅក្នុងចំណេញ ឬខាត* | | | | | |
| លម្អៀងពីអត្រាប្តូរប្រាក់ | | - | (34,761,607) | - | (17,226,158) |
| **ចំណេញពេញលេញសរុបសម្រាប់ការិយបរិច្ឆេទ** | | **65,733,020** | **232,837,517** | **60,255,448** | **230,423,7341** |
| **ចំណេញពេញលេញសុទ្ធបែងចែកទៅឱ្យ៖** | | | | | |
| ម្ចាស់មូលធនរបស់ធនាគារ | | 65,226,839 | 231,450,080 | 59,827,587 | 229,008,865 |
| ភាគកម្មអប្បភាគ | | 506,181 | 1,387,437 | 427,861 | 1,414,869 |
| | | **65,733,020** | **232,837,517** | **60,255,448** | **230,423,734** |

*កំណត់សម្គាល់ដែលមានភ្ជាប់ជាមួយពីទំព័រ 64 ដល់ 187 គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។*

# របាយការណ៍ស្តីពីបម្រែបម្រួលមូលធនរួម

| | មូលធនដែលកំណត់ថាជារបស់ម្ចាស់មូលធនក្រុមហ៊ុនរួម | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ដើមទុនបានបង់ | | ទុនបម្រុងមិនអាចបែងចែកបាន | | ទុនបម្រុងតាមបទប្បញ្ញត្តិ | | ប្រាក់ចំណេញរក្សាទុក | |
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5) | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5) | ដុល្លារអាមេរិក |
| **សមតុល្យគិតត្រឹមថ្ងៃទី1 ខែមករា ឆ្នាំ2024** | **90,000,000** | **360,000,000** | **250,000,000** | **1,021,250,000** | **21,074,536** | **86,089,480** | **435,873,135** | **1,769,492,056** |
| ចំណេញពេញលេញសរុប | - | - | - | - | - | - | 65,226,839 | 265,538,461 |
| ការផ្ទេរទៅទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | - | - | 10,096,515 | 41,102,913 | ( 10,096,515 ) | ( 41,102,913 ) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | ( 15,000,000 ) | - | ( 1,728,913 ) | - | - |
| **សមតុល្យគិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2024** | **90,000,000** | **360,000,000** | **250,000,000** | **1,006,250,000** | **31,171,051** | **125,463,480** | **491,003,459** | **1,993,927,604** |
| **សមតុល្យគិតត្រឹមថ្ងៃទី1 ខែមករា ឆ្នាំ2023** | **90,000,000** | **360,000,000** | **180,000,000** | **741,060,000** | **23,450,405** | **96,545,317** | **443,669,679** | **1,801,535,851** |
| ចំណេញពេញលេញសរុប | - | - | - | - | - | - | 59,827,587 | **245,891,383** |
| ការបែងចែកនៅក្នុងឆ្នាំ (កំណត់សម្គាល់លេខ 18) | - | - | 70,000,000 | 287,700,000 | - | - | ( 70,000,000 ) | ( 287,700,000 ) |
| ការផ្ទេរពីទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | - | - | ( 2,375,869 ) | ( 9,764,822 ) | 2,375,869 | 9,764,822 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | ( 7,510,000 ) | - | ( 691,015 ) | - | - |
| **សមតុល្យគិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2023** | **90,000,000** | **360,000,000** | **250,000,000** | **1,021,250,000** | **21,074,536** | **86,089,480** | **435,873,135** | **1,769,492,056** |

*កំណត់សម្គាល់ដែលមានភ្ជាប់ជាមួយពីទំព័រ 64 ដល់ 187 គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។*

# របាយការណ៍ស្តីពីបម្រែបម្រួលមូលធនរួម

| | មូលធនដែលកំណត់ថាជារបស់ម្ចាស់មូលធនក្រុមហ៊ុនរួម | | | | | | | |
|---|---|---|---|---|---|---|---|---|
| | លម្អៀងបង្គរពីការប្តូររូបិយប័ណ្ណ | សរុប | | ភាគកម្មអប្បភាគ | | លម្អៀងបង្គរពីការប្តូររូបិយប័ណ្ណ | សរុប | |
| | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5) | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5) | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5) | ដុល្លារអាមេរិក |
| **សមតុល្យគិតត្រឹមថ្ងៃទី1 ខែមករា ឆ្នាំ2024** | 18,699,700 | 796,947,671 | 3,255,531,236 | 10,832,349 | 43,952,218 | 297,928 | 807,780,020 | 3,299,781,382 |
| ចំណេញពេញលេញសរុប | (34,088,381) | 65,226,839 | 231,450,080 | 506,181 | 2,060,663 | (673,226) | 65,733,020 | 232,837,517 |
| ការផ្ទេរទៅទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | - | - | - | - | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | (16,728,913) | - | - | - | - | (16,728,913) |
| **សមតុល្យគិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2024** | (15,388,681) | 862,174,510 | 3,470,252,403 | 11,338,530 | 46,012,881 | (375,298) | 873,513,040 | 3,515,889,986 |
| **សមតុល្យគិតត្រឹមថ្ងៃទី1 ខែមករា ឆ្នាំ2023** | 35,582,218 | 737,120,084 | 3,034,723,386 | 10,404,488 | 42,193,709 | 641,568 | 747,524,572 | 3,077,558,663 |
| ចំណេញពេញលេញសរុប | (16,882,518) | 59,827,587 | 229,008,865 | 427,861 | 1,758,509 | (343,640) | 60,255,448 | 230,423,734 |
| ការបែងចែកនៅក្នុងឆ្នាំ (កំណត់សម្គាល់លេខ 18) | - | - | - | - | - | - | - | - |
| ការផ្ទេរពីទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | - | - | - | - | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | (8,201,015) | - | - | - | - | (8,201,015) |
| **សមតុល្យគិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2023** | 18,699,700 | 796,947,671 | 3,255,531,236 | 10,832,349 | 43,952,218 | 297,928 | 807,780,020 | 3,299,781,382 |

*កំណត់សម្គាល់ដែលមានភ្ជាប់ជាមួយពីទំព័រ 64 ដល់ 187 គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។*

# របាយការណ៍លំហូរសាច់ប្រាក់រួម

| | កំណត់សម្គាល់ | 2024 | | 2023 | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់លេខ 2.5) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់លេខ 2.5) |
| **សាច់ប្រាក់សុទ្ធបានពី (ប្រើក្នុង) សកម្មភាពប្រតិបត្តិការ** | 31 | **47,230,822** | **192,276,676** | **(21,430,082)** | **(88,077,635)** |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ការទិញ៖ | | | | | |
| ទ្រព្យ និងបរិក្ខារ | 9 | (1,246,795) | (5,075,702) | (2,454,458) | (10,087,822) |
| កម្មវិធីកុំព្យូទ័រ | 11 | (35,038) | (142,640) | (71,298) | (293,035) |
| សាច់ប្រាក់ទទួលបានពីការលក់ទ្រព្យ និងបរិក្ខារ | 9 | 21,850 | 88,951 | 28,298 | 116,305 |
| **សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពវិនិយោគ** | | **(1,259,983)** | **(5,129,391)** | **(2,497,458)** | **(10,264,552)** |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញវត្ថុ** | | | | | |
| ការទូទាត់លើចំណែកប្រាក់ដើមនៃបំណុលភតិសន្យា | | (1,774,540) | (7,224,152) | (1,542,205) | (6,338,463) |
| **សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពហិរញ្ញវត្ថុ** | | (1,774,540) | (7,224,152) | (1,542,205) | (6,338,463) |
| **កំណើន (ថយចុះ) សុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | | **44,196,299** | **179,923,133** | **(25,469,745)** | **(104,680,650)** |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាដើមការិយបរិច្ឆេទ | | 317,027,359 | 1,295,056,762 | 342,497,104 | 1,410,060,577 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (21,054,672) | - | (10,323,165) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងការិយបរិច្ឆេទ** | 3 | **361,223,658** | **1,453,925,223** | **317,027,359** | **1,295,056,762** |
| **ព័ត៌មានបន្ថែមពីការប្រាក់ក្នុងលំហូរសាច់ប្រាក់ពីប្រតិបត្តិការ** | | | | | |
| **ចំណូលការប្រាក់បានទទួល** | | 133,385,117 | 543,010,811 | 122,316,360 | 502,720,240 |
| ចំណាយការប្រាក់បានបង់ | | (22,011,090) | (89,607,147) | (17,415,689) | (71,578,482) |

*កំណត់សម្គាល់ដែលមានភ្ជាប់ជាមួយពីទំព័រ 64 ដល់ 187 គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។*

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុជាច់ដោយឡែក

| | កំណត់សម្គាល់ | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5) |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | 3 | 62,984,554 | 253,512,830 | 62,527,521 | 255,424,923 |
| សមតុល្យជាមួយធនាគារជាតិនៃកម្ពុជា | 4 | 263,602,094 | 1,060,998,428 | 235,900,094 | 963,651,884 |
| សមតុល្យជាមួយធនាគារផ្សេងៗ និងគ្រឹះស្ថានហិរញ្ញវត្ថុ | 5 | 555,522,893 | 2,235,979,644 | 446,269,480 | 1,823,010,826 |
| ឥណទាន និងបុរេប្រទាន | 6 | 1,480,461,184 | 5,958,856,266 | 1,389,551,470 | 5,676,317,755 |
| វិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ | 7 | 15,570,000 | 62,669,250 | 15,570,000 | 63,603,450 |
| វិនិយោគក្នុងក្រុមហ៊ុនសម្ព័ន្ធញាតិ | 8 | 3,920 | 15,778 | 3,920 | 16,013 |
| ទ្រព្យ និងបរិក្ខារ | 9 | 9,702,085 | 39,050,892 | 11,354,286 | 46,382,258 |
| សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម | 10 | 7,973,666 | 32,094,006 | 7,275,994 | 29,722,435 |
| កម្មវិធីកុំព្យូទ័រ | 11 | 7,735 | 31,133 | 146,104 | 596,835 |
| ពន្ធពន្យារជាទ្រព្យសកម្ម - សុទ្ធ | 15.3 | 3,007,354 | 12,104,600 | 2,929,165 | 11,965,639 |
| ទ្រព្យសកម្មផ្សេងៗ | 12 | 11,641,597 | 46,857,428 | 14,932,701 | 61,000,085 |
| **ទ្រព្យសកម្មសរុប** | | **2,410,477,082** | **9,702,170,255** | **2,186,460,735** | **8,931,692,103** |
| **ទ្រព្យអកម្ម និងមូលធន** | | | | | |
| **ទ្រព្យអកម្ម** | | | | | |
| ប្រាក់បញ្ញើពីធនាគារផ្សេងៗ និង គ្រឹះស្ថានហិរញ្ញវត្ថុ | 13 | 31,182,125 | 125,508,053 | 15,915,608 | 65,015,259 |
| ប្រាក់បញ្ញើពីអតិថិជន | 14 | 1,476,460,718 | 5,942,754,390 | 1,337,409,447 | 5,463,317,591 |
| បំណុលពន្ធលើប្រាក់ចំណូល | 15.2 | 14,278,328 | 57,470,270 | 13,033,669 | 53,242,538 |
| បំណុលភតិសន្យា | 17 | 9,823,209 | 39,538,416 | 9,098,450 | 37,167,168 |
| ទ្រព្យអកម្មផ្សេងៗ | 16 | 23,629,575 | 95,109,040 | 20,470,549 | 83,622,193 |
| **ទ្រព្យអកម្មសរុប** | | **1,555,373,955** | **6,260,380,169** | **1,395,927,723** | **5,702,364,749** |

*កំណត់សម្គាល់ដែលមានភ្ជាប់ជាមួយពីទំព័រ 64 ដល់ 187 គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។*

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុជាច់ដោយឡែក

| | កំណត់សម្គាល់ | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5) |
| **មូលធន** | | | | | |
| ដើមទុនបានបង់ | 18 | 90,000,000 | 360,000,000 | 90,000,000 | 360,000,000 |
| ទុនបម្រុងមិនអាចបែងចែកបាន | 18 | 250,000,000 | 1,006,250,000 | 250,000,000 | 1,021,250,000 |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | | 31,171,051 | 125,463,480 | 21,074,536 | 86,089,480 |
| ប្រាក់ចំណេញរក្សាទុក | | 483,932,076 | 1,963,166,781 | 429,458,476 | 1,741,404,756 |
| លម្អៀងបង្គរពីការប្តូររូបិយប័ណ្ណ | | - | (13,090,175) | - | 20,583,118 |
| **មូលធនសរុប** | | 855,103,127 | 3,441,790,086 | 790,533,012 | 3,229,327,354 |
| **ទ្រព្យអកម្ម និងមូលធនសរុប** | | 2,410,477,082 | 9,702,170,255 | 2,186,460,735 | 8,931,692,103 |

*កំណត់សម្គាល់ដែលមានភ្ជាប់ជាមួយពីទំព័រ 64 ដល់ 187 គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។*

# របាយការណ៍លទ្ធផលពេញលេញដាច់ដោយឡែក

| | កំណត់សម្គាល់ | 2024 | | 2023 | |
|---|---|---|---|---|---|
| | | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់លេខ 2.5)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់លេខ 2.5* |
| ចំណូលការប្រាក់គណនាតាមវិធីសាស្ត្រ | | | | | |
| ការប្រាក់ប្រសិទ្ធភាព | 19 | 133,441,251 | 543,239,333 | 125,633,438 | 516,353,430 |
| ចំណាយការប្រាក់ | 20 | ( 26,378,122 ) | ( 107,385,335 ) | ( 20,520,170 ) | ( 84,337,899 ) |
| **ចំណូលការប្រាក់សុទ្ធ** | | **107,063,129** | **435,853,998** | **105,113,268** | **432,015,531** |
| ចំណូលថ្លៃឈ្នួល និងកម្រៃជើងសា | 21 | 10,253,183 | 41,740,708 | 10,839,603 | 44,550,768 |
| ចំណាយថ្លៃឈ្នួល និងកម្រៃជើងសា | 21 | ( 1,110,995 ) | ( 4,522,861 ) | ( 1,330,779 ) | ( 5,469,502 ) |
| **ចំណូលថ្លៃឈ្នួល និងកម្រៃជើងសាសុទ្ធ** | 21 | **9,142,188** | **37,217,847** | **9,508,824** | **39,081,266** |
| សំវិធានធនសម្រាប់ការខាតបង់បានរំពឹងទុក | 22 | ( 7,614,020 ) | ( 30,996,675 ) | ( 13,033,892 ) | ( 53,569,296 ) |
| ចំណូលប្រតិបត្តិការផ្សេងៗ | 23 | 5,264,214 | 21,430,615 | 4,000,692 | 16,442,844 |
| **ចំណាយប្រតិបត្តិការផ្សេងៗសុទ្ធ** | | **( 2,349,806 )** | **( 9,566,060 )** | **( 9,033,200 )** | **( 37,126,452 )** |
| ចំណាយប្រតិបត្តិការផ្សេងៗ | 24 | ( 33,228,913 ) | ( 135,274,905 ) | ( 31,587,035 ) | ( 129,822,714 ) |
| **ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល** | | **80,626,598** | **328,230,880** | **74,001,857** | **304,147,631** |
| ចំណាយពន្ធលើប្រាក់ចំណូល | 15.1 | ( 16,056,483 ) | ( 65,365,942 ) | ( 14,686,481 ) | ( 60,361,437 ) |
| **ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | | **64,570,115** | **262,864,938** | **59,315,376** | **243,786,194** |
| ចំណូលលម្អិតផ្សេងៗ៖ | | | | | |
| *ធាតុដែលនឹងមិនចាត់ថ្នាក់ឡើងវិញទៅក្នុងចំណេញ ឬខាត* | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | ( 33,673,293 ) | - | ( 16,680,832 ) |
| **ចំណេញពេញលេញសរុបសម្រាប់ការិយបរិច្ឆេទ** | | **64,570,115** | **229,191,645** | **59,315,376** | **227,105,362** |

*កំណត់សម្គាល់ដែលមានភ្ជាប់ជាមួយពីទំព័រ 64 ដល់ 187 គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។*

# របាយការណ៍បម្រែបម្រួលមូលធនដាច់ដោយឡែក

| | ដើមទុនបានបង់ | | ទុនបម្រុងមិនអាចអាចបែងចែកបាន | | ទុនបម្រុងតាមបទប្បញ្ញត្តិ | |
|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5) |
| **សមតុល្យគិតត្រឹមថ្ងៃទី1 ខែមករា ឆ្នាំ2024** | 90,000,000 | 360,000,000 | 250,000,000 | 1,021,250,000 | 21,074,536 | 86,089,480 |
| ចំណេញពេញលេញសរុប | - | - | - | - | - | - |
| ការផ្ទេរទៅទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | - | - | 10,096,515 | 41,102,913 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | (15,000,000) | - | (1,728,913) |
| **សមតុល្យគិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2024** | 90,000,000 | 360,000,000 | 250,000,000 | 1,006,250,000 | 31,171,051 | 125,463,480 |
| **សមតុល្យគិតត្រឹមថ្ងៃទី1 ខែមករា ឆ្នាំ2023** | 90,000,000 | 360,000,000 | 180,000,000 | 741,060,000 | 23,450,405 | 96,545,317 |
| ចំណេញពេញលេញសរុប | - | - | - | - | - | - |
| ការបែងចែកនៅក្នុងឆ្នាំ (កំណត់សម្គាល់លេខ 18) | - | - | 70,000,000 | 287,700,000 | - | - |
| ការផ្ទេរពីទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | - | - | (2,375,869) | (9,764,822) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | (7,510,000) | - | (691,015) |
| **សមតុល្យគិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2023** | 90,000,000 | 360,000,000 | 250,000,000 | 1,021,250,000 | 21,074,536 | 86,089,480 |

*កំណត់សម្គាល់ដែលមានភ្ជាប់ជាមួយពីទំព័រ 64 ដល់ 187 គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។*

# របាយការណ៍បម្រែបម្រួលមូលធនដាច់ដោយឡែក

| | ប្រាក់ចំណេញរក្សាទុក | | លម្អៀងបង្គរពីការប្តូររូបិយប័ណ្ណ | សរុប | |
|---|---|---|---|---|---|
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់លេខ 2.5) | សមមូលពាន់រៀល (កំណត់សម្គាល់លេខ 2.5) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់លេខ 2.5) |
| **សមតុល្យគិតត្រឹមថ្ងៃទី1 ខែមករា ឆ្នាំ2024** | **429,458,476** | **1,741,404,756** | **20,583,118** | **790,533,012** | **3,229,327,354** |
| ចំណេញពេញលេញសរុប | 64,570,115 | 262,864,938 | (33,673,293) | 64,570,115 | 229,191,645 |
| ការផ្ទេរទៅទុនបម្រុងតាមបទប្បញ្ញត្តិ | (10,096,515) | (41,102,913) | - | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | (16,728,913) |
| **សមតុល្យគិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2024** | **483,932,076** | **1,963,166,781** | **(13,090,175)** | **855,103,127** | **3,441,790,086** |
| **សមតុល្យគិតត្រឹមថ្ងៃទី1 ខែមករា ឆ្នាំ2023** | **437,767,231** | **1,775,553,740** | **37,263,950** | **731,217,636** | **3,010,423,007** |
| ចំណេញពេញលេញសរុប | 59,315,376 | 243,786,194 | (16,680,832) | 59,315,376 | 227,105,362 |
| ការបែងចែកនៅក្នុងឆ្នាំ (កំណត់សម្គាល់លេខ 18) | (70,000,000) | (287,700,000) | - | - | - |
| ការផ្ទេរពីទុនបម្រុងតាមបទប្បញ្ញត្តិ | 2,375,869 | 9,764,822 | - | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | (8,201,015) |
| **សមតុល្យគិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2023** | **429,458,476** | **1,741,404,756** | **20,583,118** | **790,533,012** | **3,229,327,354** |

*កំណត់សម្គាល់ដែលមានភ្ជាប់ជាមួយពីទំព័រ 64 ដល់ 187 គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។*

# របាយការណ៍លំហូរសាច់ប្រាក់ជាច់ដោយឡែក

| | កំណត់សម្គាល់ | 2024 | | 2023 | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5) | ដុល្លារអាមេរិក | សមមូលពាន់រៀល កំណត់សម្គាល់ លេខ 2.5) |
| **សាច់ប្រាក់សុទ្ធបានពី (ប្រើក្នុង) សកម្មភាពប្រតិបត្តិការ** | 31 | **47,721,480** | **194,274,144** | **(22,055,142)** | **(90,646,636)** |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ការទិញ៖ | | | | | |
| ទ្រព្យ និងបរិក្ខារ | 9 | (1,241,639) | (5,054,712) | (2,329,884) | (9,575,823) |
| កម្មវិធីកុំព្យូទ័រ | 11 | (35,038) | (142,640) | (45,486) | (186,947) |
| សាច់ប្រាក់ទទួលបានពីការលក់ ទ្រព្យ និងបរិក្ខារ | 9 | 21,850 | 88,951 | 28,298 | 116,305 |
| **សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាព វិនិយោគ** | | **(1,254,827)** | **(5,108,401)** | **(2,347,072)** | **(9,646,465)** |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញវត្ថុ** | | | | | |
| ការទូទាត់លើចំណែកប្រាក់ដើមនៃ បំណុលភតិសន្យា | | (1,749,964) | (7,124,103) | (1,525,071) | (6,268,042) |
| **សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាព ហិរញ្ញវត្ថុ** | | **(1,749,964)** | **(7,124,103)** | **(1,525,071)** | **(6,268,042)** |
| **កំណើន (តំហយ) សុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | | **44,716,689** | **182,041,640** | **(25,927,285)** | **(106,561,143)** |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលនា ដើមការិយបរិច្ឆេទ | | 316,484,614 | 1,292,839,648 | 342,411,899 | 1,409,709,788 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (21,046,043) | - | (10,308,997) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាចុងការិយបរិច្ឆេទ** | 3 | **361,201,303** | **1,453,835,245** | **316,484,614** | **1,292,839,648** |
| **ព័ត៌មានបន្ថែមពីការប្រាក់ក្នុងលំហូរ សាច់ប្រាក់ពីប្រតិបត្តិការ** | | | | | |
| ចំណូលការប្រាក់បានទទួល | | 132,549,308 | 539,608,233 | 122,150,237 | 502,037,474 |
| ចំណាយការប្រាក់បានបង់ | | (22,571,471) | (91,888,458) | (18,299,851) | (75,212,388) |

*កំណត់សម្គាល់ដូចមានភ្ជាប់មកជាមួយពីទំព័រ 64 ដល់ 187 គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។*

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក

## 1. ព័ត៌មានអំពីសាជីវកម្ម

ធនាគារកម្ពុជាសាធារណៈ ភីអិលសី ("ធនាគារ") និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារ (រួមគ្នាត្រូវបានហៅថា "ក្រុមហ៊ុនរួម") ត្រូវបានបង្កើតឡើង និងចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ក្រុមហ៊ុនបុត្រសម្ព័ន្ធដែលបានរួមបញ្ចូល

របាយការណ៍ហិរញ្ញវត្ថុរួម រួមបញ្ចូលរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ និងរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ និងត្រូវបានរៀបចំឡើងសម្រាប់កាលបរិច្ឆេទរបាយការណ៍ដូចគ្នា ព្រមទាំងប្រើប្រាស់គោលនយោបាយគណនេយ្យស្របគ្នា។ ធនាគារមិនមានក្រុមហ៊ុនរួមទុនទេ។

ព័ត៌មានលម្អិតរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធទាំងពីររបស់ធនាគារ នាកាលបរិច្ឆេទនៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុមានដូចខាងក្រោម៖

| *ឈ្មោះក្រុមហ៊ុនបុត្រសម្ព័ន្ធ* | *សកម្មភាពចម្បង* | *ប្រទេសដែលក្រុមហ៊ុនធ្វើប្រតិបត្តិការ* | *ភាគរយប្រសិទ្ធភាពនៃភាពជាម្ចាស់កម្មសិទ្ធិ* | |
|---|---|---|---|---|
| | | | 2024 | 2023 |
| ក្រុមហ៊ុនធានារ៉ាប់រងកម្ពុ ឡុនប៉ាក ភីអិលស៊ី ("Campu Lonpac") | ធានារ៉ាប់រងទូទៅ | ប្រទេសកម្ពុជា | 51% | 51% |
| ក្រុមហ៊ុន មូលបត្រ កម្ពុ ម.ក ("CSP") | ធានាទិញ ជួញដូរ និងជើងសាមូលបត្រ | ប្រទេសកម្ពុជា | 100% | 100% |

### ការបង្កើត និងប្រតិបត្តិការ

ធនាគារ ត្រូវបានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជា នៅថ្ងៃទី20 ខែកុម្ភៈ ឆ្នាំ1992 ក្រោមការចុះបញ្ជីលេខ Co-2083/96M និងបានចាប់ផ្តើមប្រតិបត្តិការអាជីវកម្ម នៅថ្ងៃទី25 ខែឧសភា ឆ្នាំ1992។ ក្រុមហ៊ុនមេផ្ទាល់ និងក្រុមហ៊ុនមេធំបំផុតរបស់ធនាគារ គឺធនាគារ Public Bank Berhad ("PBB") ជាធនាគារដែលមានអាជ្ញាប័ណ្ណ និងធ្វើអាជីវកម្មក្នុងប្រទេសម៉ាឡេស៊ី។ នៅថ្ងៃទី28 ខែវិច្ឆិកា ឆ្នាំ2006 ធនាគារជាតិនៃកម្ពុជា ("NBC") បានប្រកាសអាជ្ញាប័ណ្ណសម្រាប់ធ្វើប្រតិបត្តិការធនាគារសាជាថ្មី ដល់ធនាគារសម្រាប់រយៈពេលជាអចិន្ត្រៃយ៍។ ក្រោយមក អាជ្ញាប័ណ្ណរបស់ធនាគារត្រូវបានធ្វើបច្ចុប្បន្នភាពស្របតាមទម្រង់ថ្មីនៅថ្ងៃទី7 ខែធ្នូ ឆ្នាំ2023 ស្របតាមសេចក្តីជូនដំណឹងរបស់ធនាគារជាតិនៃកម្ពុជា។

សកម្មភាពចម្បងរបស់ធនាគារ គឺការផ្តល់នូវសេវាកម្មប្រតិបត្តិការធនាគារ និងសេវាកម្មហិរញ្ញវត្ថុពាក់ព័ន្ធជាច្រើនទៀតក្នុងប្រទេសកម្ពុជា។

របាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុម័តឱ្យចេញផ្សាយដោយក្រុមប្រឹក្សាភិបាលនាថ្ងៃទី26 ខែកុម្ភៈ ឆ្នាំ2025។

ទីស្នាក់ការចុះបញ្ជីរបស់ធនាគារ មានទីតាំងនៅអគារលេខ 23 ផ្លូវលេខ 114 សង្កាត់ផ្សារថ្មីទី2 ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ធនាគារមានសាខាសរុបទាំងអស់ 32 សាខាដែលមានទីតាំងស្ថិតក្នុងរាជធានីភ្នំពេញ និងតាមបណ្តាខេត្តសំខាន់ៗក្នុងប្រទេសកម្ពុជា (ឆ្នាំ2023៖ 32 សាខា)។

### ដើមទុនបានបង់

គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 ដើមទុនរបស់ធនាគារដែលបានបង់មានចំនួន 90,000,000 ដុល្លារអាមេរិក (ឆ្នាំ2023៖ 90,000,000 ដុល្លារអាមេរិក)។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក

## 1. ព័ត៌មានអំពីសាជីវកម្ម (តពីទំព័រមុន)

### ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលនៅក្នុងការិយបរិច្ឆេទ និងនាកាលបរិច្ឆេទនៃរបាយការណ៍នេះមាននាមដូចខាងក្រោម៖

| | |
|---|---|
| Dato' Mohammed Najeeb Bin Abdullah | ប្រធានក្រុមប្រឹក្សាភិបាលឯករាជ្យ និងមិនប្រតិបត្តិ |
| លោក Quah Poh Keat | អភិបាលមិនឯករាជ្យ និងមិនប្រតិបត្តិ |
| Dato' Chang Kat Kiam | អភិបាលមិនឯករាជ្យ និងមិនប្រតិបត្តិ |
| បណ្ឌិត ផៃ ទូច | អភិបាលឯករាជ្យ និងមិនប្រតិបត្តិ |
| លោក អុង មីងតិច | អភិបាលប្រតិបត្តិ |

### និយោជិត

ត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 ក្រុមហ៊ុនរួម មាននិយោជិតសរុបចំនួន 970នាក់ (ឆ្នាំ2023៖ 992 នាក់)។

## 2. គោលនយោបាយគណនេយ្យជាសារវន្ត

គោលនយោបាយគណនេយ្យជាសារវន្ត ដែលប្រើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែកមានកំណត់ដូចខាងក្រោម។ គោលនយោបាយទាំងនេះ ត្រូវបានអនុវត្តយ៉ាងជាប់លាប់ នៅគ្រប់ការិយបរិច្ឆេទដែលបានបង្ហាញ លុះត្រាតែមានចែងផ្សេងពីនេះ។

### 2.1 មូលដ្ឋាននៃការរៀបចំ

របាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែកត្រូវបានរៀបចំតាមមូលដ្ឋានថ្លៃដើម លុះត្រាតែមានការចង្អុលបង្ហាញក្រៅពីនេះ ដែលមានក្នុងកំណត់សម្គាល់នៃរបាយការណ៍ហិរញ្ញវត្ថុ។

#### ឆ្នាំសារពើពន្ធ

ឆ្នាំសារពើពន្ធរបស់ក្រុមហ៊ុនរួម គឺចាប់ផ្តើមពីថ្ងៃទី1 ខែមករា និងបញ្ចប់នៅថ្ងៃទី31 ខែធ្នូ។

### 2.2 របាយការណ៍នៃអនុលោមភាព

របាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក (ហៅថា "របាយការណ៍ហិរញ្ញវត្ថុ") របស់ក្រុមហ៊ុនរួម ត្រូវបានរៀបចំដោយអនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("CIFRSs") ជាមួយនឹងការពន្យារពេលអនុវត្ត CIFRS 17 - កិច្ចសន្យាធានារ៉ាប់រង ស្របតាមការអនុម័តរបស់និយ័តករគណនេយ្យ និងសវនកម្ម ("CIFRSs ជាមួយនឹងការពន្យារពេលអនុវត្ត CIFRS 17")។ ហេតុដូចនេះ ក្រុមហ៊ុនរួមបានអនុវត្ត CIFRS 4 - កិច្ចសន្យាធានារ៉ាប់រង ដើម្បីទទួលស្គាល់ការកត់ត្រាគណនេយ្យសម្រាប់កិច្ចសន្យាធានារ៉ាប់រង។

### 2.3 ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក

ធនាគារបង្ហាញរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែករបស់ខ្លួន តាមលំដាប់នៃសន្ទនីយភាព ដោយផ្អែកតាមបំណង និងការយល់ឃើញរបស់ធនាគារក្នុងការទទួលបានមកវិញ/ការទូទាត់នៃទ្រព្យសកម្ម/ទ្រព្យអកម្មភាគច្រើននៃធាតុនីមួយៗក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ការវិភាគទាក់ទងនឹងការទទួលបានមកវិញ ឬការទូទាត់ក្នុងរយៈពេល 12ខែ បន្ទាប់ពីកាលបរិច្ឆេទរបាយការណ៍ (រយៈពេលខ្លី) និងច្រើនជាង 12ខែ បន្ទាប់ពីកាលបរិច្ឆេទរបាយការណ៍ (រយៈពេលវែង) ត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់លេខ 30។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក

## 2. គោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

### 2.4 មូលដ្ឋាននៃការរួមបញ្ចូល

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធត្រូវបានរៀបចំសម្រាប់កាលបរិច្ឆេទរាយការណ៍ដូចគ្នាទៅនឹងធនាគារ។

ក្រុមហ៊ុនបុត្រសម្ព័ន្ធទាំងអស់ត្រូវបានរួមបញ្ចូលចាប់ពីកាលបរិច្ឆេទ នៃការទិញយកជាកាលបរិច្ឆេទដែលធនាគារទទួលបានការគ្រប់គ្រង ហើយបន្តរួមបញ្ចូលរហូតដល់កាលបរិច្ឆេទ ដែលការគ្រប់គ្រងបែបនោះត្រូវបញ្ឈប់។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម សមតុល្យក្នុងក្រុម ប្រតិបត្តិការ និងចំណេញ ឬខាតមិនជាក់ស្តែងក្នុងក្រុមត្រូវបានលុបចោលទាំងស្រុង។ គោលនយោបាយគណនេយ្យឯកភាព ត្រូវបានអនុម័តនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួមសម្រាប់ប្រតិបត្តិការ និងព្រឹត្តិការណ៍ផ្សេងៗក្នុងកាលៈទេសៈស្រដៀងគ្នា។

ការទិញយកក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវបានរាប់បញ្ចូលដោយប្រើវិធីសាស្ត្រទិញគណនេយ្យ។ តម្លៃតបស្នងផ្ទេរសម្រាប់ការទិញយកក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវបានវាស់វែងតាមតម្លៃសមស្របនៃទ្រព្យសកម្មដែលបានផ្តល់ឱ្យឧបករណ៍មូលធនដែលចេញផ្សាយ និងទ្រព្យអកម្មដែលកើតឡើង ឬបានសន្មតនៅកាលបរិច្ឆេទនៃការដោះដូរ ក៏ដូចជាតម្លៃតបស្នងជាយថាភាពដែលបានផ្តល់ឱ្យ។ ចំណាយទាក់ទងនឹងការទិញយកត្រូវកត់ជាចំណាយតាមពេល ដែលបានកើតឡើងក្នុងរបាយការណ៍លទ្ធផល ពេញលេញរួម។ ទ្រព្យសកម្មទិញដែលអាចកំណត់បាន និងទ្រព្យអកម្ម និងទ្រព្យអកម្មសន្មតជាយថាភាពបានវាស់វែងតាមតម្លៃសមស្របជាលើកដំបូងនៅកាលបរិច្ឆេទទិញ។

### 2.5 រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណបង្ហាញ

រូបិយប័ណ្ណជាតិនៃប្រទេសកម្ពុជា គឺជាប្រាក់រៀល ("KHR") ហើយក្រុមហ៊ុនរួម និងធនាគារមានប្រតិបត្តិការជាប្រាក់រៀល អឺរ៉ូ ("EUR") ដុល្លារសិង្ហបុរី ("SGD") ថៃបាត ("THB") យ៉េនជប៉ុន ("JPY") និងដុល្លារអាមេរិក ("USD")។ ប៉ុន្តែដោយសារក្រុមហ៊ុនរួម និងធនាគារធ្វើប្រតិបត្តិការអាជីវកម្ម និងរក្សាកំណត់ត្រាគណនេយ្យចម្បងរបស់ខ្លួនជាប្រាក់ដុល្លារអាមេរិក គណៈគ្រប់គ្រងបានកំណត់ដុល្លារអាមេរិកជារូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណបង្ហាញរបស់ក្រុមហ៊ុនរួម និងធនាគារដោយសារវាបានឆ្លុះបញ្ចាំងពីសារធាតុសេដ្ឋកិច្ចនៃមូលដ្ឋានរបស់ព្រឹត្តិការណ៍ និងកាលៈទេសៈរបស់ក្រុមហ៊ុនរួម និងធនាគារ។ ការប្តូររូបិយប័ណ្ណប្រាក់ដុល្លារអាមេរិកទៅជាប្រាក់រៀល គឺធ្វើឡើងដើម្បីបំពេញតម្រូវការស្របតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្មប៉ុណ្ណោះ។

ទ្រព្យសកម្ម និងបំណុលរូបិយវត្ថុនានា ដែលកំណត់ជារូបិយប័ណ្ណបរទេសនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ត្រូវបានប្តូររូបិយប័ណ្ណតាមអត្រាចុងគ្រា នៅថ្ងៃកាលបរិច្ឆេទរាយការណ៍ ចំណែកឯចំណូល និងចំណាយសម្រាប់របាយការណ៍លទ្ធផលពេញលេញនីមួយៗ ដែលបានបង្ហាញត្រូវបានប្តូររូបិយប័ណ្ណតាមអត្រាមធ្យមសម្រាប់ការិយបរិច្ឆេទបញ្ចប់។ រាល់ភាពខុសគ្នាដែលកើតឡើងចេញពីការប្តូររូបិយប័ណ្ណត្រូវទទួលស្គាល់ ក្នុងរបាយការណ៍លទ្ធផលពេញលេញ។ តួលេខដុល្លារអាមេរិក ដែលបានប្តូរមកជាប្រាក់រៀល រួចហើយតាមអត្រាប្តូរប្រាក់នេះ ឬអត្រាប្តូរប្រាក់ផ្សេងទៀតមិនគួរយកមកបកស្រាយថាជាតួលេខប្រាក់រៀលដែលតំណាង ឬអាចត្រូវបាន ឬនឹងត្រូវបាននោះឡើយ។ តម្លៃជាប្រាក់រៀលទាំងអស់បានបង្គត់ទៅជាសមមូលខ្ទង់ពាន់ លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញជាប្រាក់រៀលផ្អែកលើអត្រាប្តូរប្រាក់ គិតក្នុង 1 ដុល្លារអាមេរិក ដូចខាងក្រោម៖

| | *2024* | *2023* |
|---|---|---|
| អត្រាចុងគ្រា | 4,025 | 4,085 |
| អត្រាមធ្យម | 4,071 | 4,110 |

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក

## 2. គោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

### 2.6 ការវិនិច្ឆ័យ និងការប៉ាន់ស្មានគណនេយ្យសំខាន់ៗ

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ តម្រូវឱ្យក្រុមហ៊ុនរួម ធ្វើការវិនិច្ឆ័យ និងការប៉ាន់ស្មាន ដែលប៉ះពាល់ទៅលើតម្លៃរបស់ទ្រព្យសកម្ម ទ្រព្យអកម្ម ចំណូល និងចំណាយ ដែលបានរាយការណ៍ និងការលាតត្រដាងនៃទ្រព្យសកម្មជាយថាភាព និងទ្រព្យអកម្មជាយថាហេតុ។ ព្រឹត្តិការណ៍នាពេលអនាគតអាចនឹងកើតឡើងដែលបណ្តាលឱ្យមានការប្រែប្រួលលើការសន្មតដែលបានប្រើនៅក្នុងការប៉ាន់ស្មាន។ ផលប៉ះពាល់របស់ការផ្លាស់ប្តូរណាមួយទៅលើការប៉ាន់ស្មានត្រូវបានឆ្លុះបញ្ចាំងទៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនៅពេលដែលមានការកំណត់ថាសមហេតុផល។

ខាងក្រោមនេះ គឺជាការវិនិច្ឆ័យ ការសន្មត និងផ្នែកសំខាន់ៗនៃការប៉ាន់ស្មានដែលមានហានិភ័យខ្ពស់លើនិយ័តកម្មជាសារវន្ត ទៅនឹងតម្លៃយោងនៃទ្រព្យសកម្ម និងទ្រព្យអកម្មក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុបន្ទាប់៖

#### ក. វិធីសាស្រ្តអត្រាការប្រាក់ប្រសិទ្ធភាព ("EIR")

វិធីសាស្រ្ត EIR របស់ក្រុមហ៊ុនរួមទទួលស្គាល់ចំណូលការប្រាក់ដោយប្រើអត្រាចំណូល ដែលតំណាងឱ្យការប៉ាន់ស្មានល្អបំផុតរបស់អត្រាចំណូលថេរ តាមអាយុកាលរំពឹងទុកនៃឥណទាន និងប្រាក់បញ្ញើ ព្រមទាំងទទួលស្គាល់ការប៉ះពាល់ជាសក្តានុពលនៃអត្រាការប្រាក់ខុសៗគ្នា ដែលត្រូវបានគិតនៅដំណាក់កាលផ្សេងៗគ្នា និងលក្ខណៈផ្សេងទៀតនៃវដ្តជីវិតរបស់ឧបករណ៍ហិរញ្ញវត្ថុ (រួមទាំងការទូទាត់ជាមុន ការប្រាក់ពិន័យ និងការគិតថ្លៃ)។ ការប៉ាន់ស្មាននេះ តម្រូវឱ្យមានការវិនិច្ឆ័យទាក់ទងនឹងអាកប្បកិរិយាដែលរំពឹងទុក និងវដ្តជីវិតរបស់ឧបករណ៍ហិរញ្ញវត្ថុ ក៏ដូចជាការផ្លាស់ប្តូរទៅលើមូលដ្ឋានអត្រាការប្រាក់ដែលរំពឹងទុក និងចំណូល/ចំណាយផ្សេងៗទៀតរបស់ក្រុមហ៊ុនរួម ដែលជាផ្នែកសំខាន់នៃឧបករណ៍ហិរញ្ញវត្ថុនោះ។

#### ខ. ភតិសន្យា

ក្រុមហ៊ុនរួម បានកំណត់រយៈពេលនៃកិច្ចសន្យាជួលនេះថាជារយៈពេលដែលមិនអាចបញ្ឈប់បាន រួមជាមួយនឹងរយៈពេលណាមួយ ដែលត្រូវបានគ្របដណ្តប់ដោយជម្រើសដើម្បីបន្តកិច្ចសន្យាជួល ប្រសិនបើមានហេតុផលជាក់លាក់ដើម្បីអនុវត្តការបន្តនេះ ឬរយៈពេលណាមួយ ដែលមានជម្រើសដើម្បីបញ្ចប់កិច្ចសន្យាជួល ប្រសិនបើមានហេតុផលជាក់លាក់ថា ក្រុមហ៊ុនរួមនឹងមិនអនុវត្ត។

##### ជម្រើសនៃការបន្ត និងបញ្ចប់កិច្ចសន្យា

ក្រុមហ៊ុនរួម មានកិច្ចសន្យាជួលជាច្រើនដែលរួមមានជម្រើសបន្ត និងបញ្ចប់កិច្ចសន្យា។ ក្រុមហ៊ុនរួមអនុវត្តការវិនិច្ឆ័យក្នុងការវាយតម្លៃ ថាតើវាមានហេតុផលជាក់លាក់ដើម្បីអនុវត្តជម្រើសបន្ត ឬបញ្ចប់កិច្ចសន្យាជួល។ ក្រុមហ៊ុនរួមចាត់ទុកកត្តាពាក់ព័ន្ធទាំងអស់ដូចជាការកែលម្អអគារជួល និងទីតាំង ដែលបង្កើតជាអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចសម្រាប់ក្រុមហ៊ុនរួមដើម្បីអនុវត្តទាំងការបន្ត ឬការបញ្ចប់។ បន្ទាប់ពីកាលបរិច្ឆេទចាប់ផ្តើមជួល ក្រុមហ៊ុនរួមវាយតម្លៃរយៈពេលជួលឡើងវិញប្រសិនបើមានព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរនៃកាលៈទេសៈសំខាន់ៗ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន ហើយប៉ះពាល់ដល់សមត្ថភាពរបស់ក្រុមហ៊ុនរួមក្នុងការមិនប្រើជម្រើសក្នុងការបន្ត ឬបញ្ចប់។

##### ការប៉ាន់ប្រមាណនៃកំនើនរបស់អត្រាប្រាក់កម្ចី ("IBR") សម្រាប់បំណុលភតិសន្យា

ក្រុមហ៊ុនរួមមិនអាចកំណត់បាននូវអត្រាការប្រាក់ដែលមាននៅក្នុងភតិសន្យាឡើយហេតុដូច្នេះក្រុមហ៊ុនបានប្រើប្រាស់ IBR ដើម្បីវាស់វែងបំណុលភតិសន្យា។ IBR សម្រាប់បំណុលភតិសន្យា គឺជាអត្រាការប្រាក់ដែលក្រុមហ៊ុនរួមនឹងត្រូវបង់ដើម្បីខ្ចីក្នុងរយៈពេលប្រហាក់ប្រហែលគ្នា ហើយដោយមានទ្រព្យធានាស្រដៀងគ្នាដែលជាទឹកប្រាក់ចាំបាច់ដើម្បីទទួលបានទ្រព្យសកម្ម ដែលមានតម្លៃប្រហាក់ប្រហែលនឹងទ្រព្យសកម្មនៃសិទ្ធិក្នុងការប្រើប្រាស់នៅក្នុងបរិស្ថានសេដ្ឋកិច្ចស្រដៀងគ្នា។ ក្រុមហ៊ុនរួម ប៉ាន់ប្រមាណ IBR សម្រាប់បំណុលភតិសន្យាដោយប្រើធាតុចូលដែលអាចអង្កេតបាន (ដោយយោងទៅលើអត្រាគ្មានហានិភ័យទូទៅ) ដែលត្រូវបានកែតម្រូវដោយគិតទាំងហានិភ័យឥណទានរបស់ក្រុមហ៊ុនរួម (ឧទាហរណ៍៖ ការពង្រីកឥណទាន)។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក

## 2. គោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

### គ. ការខាតបង់អ៊ីមភែរមិនលើឥណទាន បុរេប្រទាន និងហិរញ្ញប្បទាន

ការវាស់វែងនៃការខាតបង់អ៊ីមភែរមិនលើឥណទាន បុរេប្រទាន និងហិរញ្ញប្បទានតម្រូវឱ្យមានការវិនិច្ឆ័យ ជាពិសេសការប៉ាន់ស្មានចំនួន និងពេលវេលានៃលំហូរសាច់ប្រាក់នាពេលអនាគត ការវាយតម្លៃនៃការកើនឡើងហានិភ័យឥណទានគួរឱ្យកត់សម្គាល់ និងការបញ្ចូលព័ត៌មានដែលមើលទៅអនាគតក្នុងការវាស់វែងនៃការខាតបង់អ៊ីមភែរមិន។ ការប៉ាន់ប្រមាណទាំងនេះត្រូវបានជំរុញដោយកត្តាមួយចំនួន ការផ្លាស់ប្តូរ ដែលអាចបណ្តាលឱ្យមានការខាតបង់អ៊ីមភែរមិន មានភាពខុសគ្នាជាកម្រិត។

ការខាតបង់អ៊ីមភែរមិនត្រូវបានគណនាដោយផ្អែកលើម៉ូឌែលឥណទានបាត់បង់ដែលរំពឹងទុក ("ECL") គឺជាលទ្ធផលនៃម៉ូឌែលស្មុគស្មាញដែលមានការសន្មតមូលដ្ឋានមួយចំនួនទាក់ទងនឹងជម្រើសនៃធាតុចូលអថេរ និងភាពអាស្រ័យគ្នា។ ការវិនិច្ឆ័យសំខាន់ៗមួយចំនួនត្រូវបានតម្រូវផងដែរក្នុងការអនុវត្តតម្រូវការគណនេយ្យសម្រាប់វាស់ការខាតបង់អ៊ីមភែរមិន ដូចជាការកំណត់លក្ខណៈវិនិច្ឆ័យសម្រាប់ការកើនឡើងហានិភ័យឥណទានគួរឱ្យកត់សម្គាល់ ការជ្រើសរើសម៉ូឌែលសមស្រប និងការសន្មតសម្រាប់ការវាស់វែងនៃការខាតបង់អ៊ីមភែរមិន បង្កើតការបែងចែកជាផ្នែកទៅលើឥណទានសម្រាប់គោលបំណង ក្នុងការវាស់វែងការខាតបង់អ៊ីមភែរមិនតាមមូលដ្ឋានរួម កំណត់ធាតុចូលផ្នែកសេដ្ឋកិច្ចមួយចំនួន (ឧទាហរណ៍៖ អត្រាកំណើនផលិតផលក្នុងស្រុកដុល សន្ទស្សន៍តម្លៃទំនិញ សន្ទស្សន៍តម្លៃផ្ទះ-ល-) ក៏ដូចជាផលប៉ះពាល់លើអត្រាមិនសងប្រាក់ និងអត្រាប្រមូលប្រាក់មកវិញ និងការជ្រើសរើសសេណារីយ៉ូម៉ាក្រូសេដ្ឋកិច្ចនាពេលអនាគត និងកំណត់ប្រូបាប៊ីលីតេទម្ងន់របស់វា។

ចំពោះការថយចុះតម្លៃនៃឥណទាន បុរេប្រទាន និងហិរញ្ញប្បទាន ("ឥណទាន") ដែលត្រូវបានវាយតម្លៃជាលក្ខណៈបុគ្គល ការវិនិច្ឆ័យដោយគណៈគ្រប់គ្រង គឺចាំបាច់ក្នុងការប៉ាន់ស្មានតម្លៃ និងពេលវេលានៃលំហូរសាច់ប្រាក់នាពេលអនាគតក្នុងការកំណត់ នៃការខាតបង់អ៊ីមភែរមិន។ ក្នុងការប៉ាន់ស្មានលំហូរសាច់ប្រាក់ទាំងនេះ ការវិនិច្ឆ័យត្រូវបានធ្វើឡើងអំពីតម្លៃដែលអាចលក់បាននៃទ្រព្យបញ្ចាំដែលបានសន្យា និងស្ថានភាពហិរញ្ញវត្ថុរបស់អ្នកខ្ចី។ ការប៉ាន់ស្មានទាំងនេះផ្អែកលើការសន្មត និងលទ្ធផលជាក់ស្តែង ដែលអាចខុសគ្នា ហេតុដូច្នេះជាលទ្ធផលបណ្តាលឱ្យមានការផ្លាស់ប្តូរក្នុងការទទួលស្គាល់លើការខាតបង់អ៊ីមភែរមិន។

## 2.7 សង្ខេបនៃគោលនយោបាយគណនេយ្យជាសារវន្ត

គោលនយោបាយគណនេយ្យដែលបានកំណត់ខាងក្រោម ត្រូវបានអនុវត្តយ៉ាងជាប់លាប់គ្រប់ការិយបរិច្ឆេទដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ លុះត្រាតែមានចែងផ្សេងពីនេះ

### 2.7.1 ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

#### (i) ការទទួលស្គាល់ និងការវាស់វែងដំបូង

ក្រុមហ៊ុនរួម និងធនាគារទទួលស្គាល់ឥណទាន និងបុរេប្រទានទៅអតិថិជន និងប្រាក់បញ្ញើពីអតិថិជននៅកាលបរិច្ឆេទដែលកើតមាន។ សម្រាប់ឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតត្រូវបានទទួលស្គាល់នៅពេលដែលក្រុមហ៊ុនរួម និងធនាគារក្លាយជាភាគីតាមលក្ខខណ្ឌកិច្ចសន្យានៃឧបករណ៍នោះ។

ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុត្រូវបានវាស់វែងជាដំបូងតាមតម្លៃសមស្រប បូក ឬដកចំណាយប្រតិបត្តិការដែលកើតឡើងដោយផ្ទាល់ទៅលើការទិញ ឬចេញផ្សាយសម្រាប់ឧបករណ៍មិនវាស់វែងតាមតម្លៃសមស្របក្នុងចំណេញខាត ("FVTPL")។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក

## 2. គោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

### 2.7 សង្ខេបនៃគោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

### 2.7.1 ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (តពីទំព័រមុន)

(ii) ចំណាត់ថ្នាក់

ទ្រព្យសកម្មហិរញ្ញវត្ថុ

នៅលើការទទួលស្គាល់ដំបូង ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានចាត់ថ្នាក់តាមវិធីសាស្រ្តវាស់វែងដូចជា តម្លៃរំលស់ វាស់វែងតាមតម្លៃសមស្របក្នុងចំណូលលម្អិតផ្សេងៗ ("FVOCI") ឬ FVTPL។

តម្លៃរំលស់

ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានវាស់តាមតម្លៃរំលស់ ប្រសិនបើទ្រព្យនោះបំពេញតាមលក្ខខណ្ឌទាំងពីរដូចខាងក្រោម ហើយមិនត្រូវបានកំណត់ជា FVTPL៖

- ទ្រព្យសកម្មត្រូវបានអនុវត្តតាមម៉ូឌែលអាជីវកម្ម ដែលមានគោលបំណងកាន់កាប់ទ្រព្យសកម្មដើម្បីប្រមូលលំហូរសាច់ប្រាក់តាមកិច្ចសន្យា
- លក្ខខណ្ឌកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុ ផ្តល់ឱ្យមានការកើនឡើងតាមកាលបរិច្ឆេទជាក់លាក់នៃលំហូរសាច់ប្រាក់ដែលជា SPPI។

FVOCI

ឧបករណ៍បំណុលត្រូវបានវាស់វែងតាម FVOCI លុះត្រាតែឧបករណ៍នោះបំពេញតាមលក្ខខណ្ឌទាំងពីរដូចខាងក្រោម និងមិនត្រូវបានកំណត់តាម FVTPL៖

- ទ្រព្យសកម្មត្រូវបានអនុវត្តតាមម៉ូឌែលអាជីវកម្ម ដែលមានគោលដៅក្នុងការប្រមូលលំហូរសាច់ប្រាក់តាមកិច្ចសន្យា និងការលក់ទ្រព្យសកម្មហិរញ្ញវត្ថុ និង
- លក្ខខណ្ឌកិច្ចសន្យា នៃទ្រព្យសកម្មហិរញ្ញវត្ថុ ផ្តល់ឱ្យមានការកើនឡើងតាមកាលបរិច្ឆេទជាក់លាក់នៃលំហូរសាច់ប្រាក់ដែលជា SPPI។

នៅពេលទទួលស្គាល់ដំបូងនៃការវិនិយោគភាគហ៊ុនដែលមិនត្រូវបានរក្សាទុកសម្រាប់ការលក់ដូរ ក្រុមហ៊ុនរួម និងធនាគារអាចជ្រើសរើសដោយមិនមានការបដិសេធដើម្បីបង្ហាញពីការផ្លាស់ប្តូរជាបន្តបន្ទាប់នៃតម្លៃសមស្រប នៅក្នុងលទ្ធផលលម្អិតផ្សេងៗ។ ការជ្រើសរើសនេះត្រូវបានធ្វើឡើងដោយផ្អែកលើមូលដ្ឋានទៅតាមការវិនិយោគនីមួយៗ។

FVTPL

ក្រុមហ៊ុនរួម និងធនាគារអាចជ្រើសរើសដោយមិនមានការបដិសេធ នៅពេលទទួលស្គាល់ដំបូង និងវាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុតាម FVTPL ប្រសិនបើវាមិនបំពេញលក្ខខណ្ឌវាស់វែងតាមតម្លៃរំលស់ និង FVOCI ប្រសិនបើធ្វើដូច្នេះ លុបបំបាត់ ឬកាត់បន្ថយយ៉ាងខ្លាំងនូវភាពមិនស៊ីគ្នានៃគណនេយ្យដែលអាចនឹងកើតឡើង។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក

## 2. គោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

### 2.7 សង្ខេបនៃគោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

### 2.7.1 ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (តពីទំព័រមុន)

(ii) ចំណាត់ថ្នាក់ (តពីទំព័រមុន)

#### ការវាយតម្លៃម៉ូឌែលអាជីវកម្ម

ក្រុមហ៊ុនរួម និងធនាគារធ្វើការវាយតម្លៃអំពីគោលបំណងនៃម៉ូឌែលអាជីវកម្មដែលទ្រព្យសកម្មត្រូវបានរក្សាទុកជាកម្រិតសំពៀត ដែលឆ្លុះបញ្ចាំងយ៉ាងច្បាស់ពីវិធីគ្រប់គ្រងអាជីវកម្ម និងព័ត៌មានដែលបានផ្តល់ជូនគណៈគ្រប់គ្រង។ ព័ត៌មានដែលបានពិចារណារួមមាន៖

- គោលនយោបាយ និងគោលបំណងដែលបានបញ្ជាក់សម្រាប់សំពៀត និងប្រតិបត្តិការនៃគោលនយោបាយទាំងនោះនៅក្នុងការអនុវត្តជាក់ស្តែង។ ជាពិសេសថាតើ យុទ្ធសាស្ត្ររបស់គណៈគ្រប់គ្រងផ្តោតលើការទទួលបានចំណូលការប្រាក់តាមកិច្ចសន្យា ការរក្សានូវទម្រង់អត្រាការប្រាក់ជាក់លាក់មួយ ការធ្វើឱ្យមានភាពស៊ីសង្វាក់គ្នារវាងរយៈពេលនៃទ្រព្យសកម្មហិរញ្ញវត្ថុទៅនឹងរយៈពេល នៃបំណុលដែលជាហិរញ្ញប្បទានរបស់ទ្រព្យសកម្មទាំងនោះ ឬការទទួលលំហូរសាច់ប្រាក់តាមរយៈការលក់ទ្រព្យសកម្មនោះ។
- របៀបដែលលទ្ធផលនៃសំពៀតមួយត្រូវបានវាយតម្លៃ និងរាយការណ៍ទៅគណៈគ្រប់គ្រងរបស់ក្រុមហ៊ុនរួម និងធនាគារ
- ហានិភ័យដែលប៉ះពាល់ដល់លទ្ធផលម៉ូឌែលអាជីវកម្ម (និងទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមាននៅក្នុងម៉ូឌែលអាជីវកម្មនោះ) និងយុទ្ធសាស្ត្ររបស់ម៉ូឌែលអាជីវកម្មសម្រាប់ការគ្រប់គ្រងហានិភ័យទាំងនោះ
- របៀបដែលអ្នកគ្រប់គ្រងអាជីវកម្មទទួលបានអត្ថប្រយោជន៍ (ឧទាហរណ៍ ថាតើអត្ថប្រយោជន៍ គឺផ្អែកលើតម្លៃសមស្របនៃទ្រព្យសកម្មដែលបានគ្រប់គ្រង ឬលំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលបានប្រមូល) និង
- ភាពញឹកញាប់ បរិមាណ និងពេលវេលានៃការលក់ក្នុងរយៈពេលកន្លងមក ហេតុផលសម្រាប់ការលក់ និងការរំពឹងទុករបស់ខ្លួនអំពីសកម្មភាពលក់នាពេលអនាគត។ ទោះយ៉ាងណាព័ត៌មានអំពីសកម្មភាពលក់ គឺមិនត្រូវបានពិចារណាដាច់ដោយឡែកទេ ប៉ុន្តែរួមជាផ្នែកមួយនៃការវាយតម្លៃទូទៅអំពីវិធីដែលគោលបំណងរបស់ក្រុមហ៊ុនរួម និងធនាគារមានចែងដើម្បីសម្រេចបានការគ្រប់គ្រងទ្រព្យសកម្ម និងវិធីដែលលំហូរសាច់ប្រាក់ត្រូវទទួលបាន។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានរក្សាសម្រាប់ការលក់ដូរ ហើយលទ្ធផលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុនោះត្រូវបានវាយតម្លៃដោយផ្អែកលើមូលដ្ឋានតម្លៃសមស្រប ត្រូវបានវាស់វែងតាម FVTPL។

#### ការវាយតម្លៃថាតើលំហូរសាច់ប្រាក់តាមកិច្ចសន្យាគឺជាការទូទាត់ប្រាក់ដើម និងការប្រាក់

សម្រាប់គោលបំណងនៃការវាយតម្លៃ "ប្រាក់ដើម" ត្រូវបានកំណត់ជាតម្លៃសមស្របនៃទ្រព្យសកម្មហិរញ្ញវត្ថុតាមការទទួលស្គាល់ដំបូង។ "ការប្រាក់" ត្រូវបានកំណត់ជាតម្លៃតបស្នង សម្រាប់តម្លៃពេលវេលានៃទឹកប្រាក់ និងសម្រាប់ហានិភ័យឥណទាន ដែលទាក់ទងនឹងចំនួនថ្លៃដើមដែលនៅសល់ក្នុងអំឡុងពេលជាក់លាក់ណាមួយ និងសម្រាប់ហានិភ័យ និងចំណាយរបស់មូលដ្ឋានខ្ចីផ្សេងទៀត (ឧទាហរណ៍៖ ហានិភ័យសន្ទនីយភាព និងចំណាយរដ្ឋបាល) ក៏ដូចជាកម្រិតចំណេញ។

ក្នុងការវាយតម្លៃថាតើលំហូរសាច់ប្រាក់តាមកិច្ចសន្យាជា SPPI ក្រុមហ៊ុនរួម និងធនាគារពិចារណាលើលក្ខខណ្ឌក្នុងកិច្ចសន្យានៃឧបករណ៍នេះ។ នេះរួមបញ្ចូលទាំងការវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុមានរយៈពេលកិច្ចសន្យាដែលអាចផ្លាស់ប្តូររយៈពេល ឬតម្លៃលំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលថាវានឹងមិនបំពេញតាមលក្ខខណ្ឌនេះទេ។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក

## 2. គោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

### 2.7 សង្ខេបនៃគោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

#### 2.7.1 ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (តពីទំព័រមុន)

(ii) ចំណាត់ថ្នាក់ (តពីទំព័រមុន)

ការវាយតម្លៃថាតើលំហូរសាច់ប្រាក់តាមកិច្ចសន្យាគឺជាការទូទាត់ប្រាក់ដើម និងការប្រាក់ (តពីទំព័រមុន)

ក្នុងការរវាយតម្លៃក្រុមហ៊ុនរួម និងធនាគារពិចារណាលើ៖

- ព្រឹត្តិការណ៍យថាភាពដែលអាចផ្លាស់ប្តូរចំនួន និងរយៈពេលនៃលំហូរសាច់ប្រាក់
- លក្ខណៈពិសេសអានុភាព
- លក្ខខណ្ឌបង់ប្រាក់ជាមុន និងការពន្យារពេល
- លក្ខខណ្ឌដែលធ្វើឱ្យក្រុមហ៊ុនរួម និងធនាគារមានកម្រិតក្នុងការទាមទារចំពោះលំហូរសាច់ប្រាក់ពីទ្រព្យសកម្មជាក់លាក់ (ឧទាហរណ៍៖ ឥណទានមិនទាមទារសំណង) និង
- លក្ខណៈពិសេស ដែលកែប្រែតម្លៃតបស្នងសម្រាប់តម្លៃពេលវេលានៃទឹកប្រាក់(ឧទាហរណ៍៖ ការកំណត់អត្រាការប្រាក់ឡើងវិញតាមពេលវេលាណាមួយ)។

ឥណទានមិនទាមទារសំណង

ក្នុងករណីខ្លះ៖ ឥណទានត្រូវបានធ្វើឡើងដោយក្រុមហ៊ុនរួម និងធនាគារដែលត្រូវបានធានាដោយទ្រព្យបញ្ចាំរបស់អ្នកខ្ចី ដែលក្រុមហ៊ុនរួម និងធនាគារមានកំណត់ក្នុងកាទាមទារលំហូរសាច់ប្រាក់នៃទ្រព្យបញ្ចាំមូលដ្ឋាននោះ (ឥណទានមិនទាមទារសំណង)។ ក្រុមហ៊ុនរួម និងធនាគារអនុវត្តការវិនិច្ឆ័យក្នុងការវាយតម្លៃ ថាតើឥណទានមិនទាមទារសំណងឆ្លើយតបនឹងលក្ខណៈវិនិច្ឆ័យរបស់ SPPI ដែរឬទេ។ ក្រុមហ៊ុនរួម និងធនាគារជាធម្មតាពិចារណាលើព័ត៌មានដូចខាងក្រោមនៅពេលធ្វើការវិនិច្ឆ័យនេះ៖

- ថាតើការរៀបចំកិច្ចសន្យាបានកំណត់ចំនួនជាក់លាក់ និងកាលបរិច្ឆេទនៃការទូទាត់ជាសាច់ប្រាក់នៃឥណទានទេ
- តម្លៃសមស្របនៃទ្រព្យបញ្ចាំទាក់ទងនឹងតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុដែលបានធានា
- សមត្ថភាព និងឆន្ទៈរបស់អ្នកខ្ចីក្នុងការទូទាត់តាមកិច្ចសន្យា ទោះបីមានការធ្លាក់ចុះនៃតម្លៃទ្រព្យបញ្ចាំក៏ដោយ
- ថាតើអ្នកខ្ចី គឺជាបុគ្គល ឬជាអង្គភាពប្រតិបត្តិការសំខាន់ ឬជាអង្គភាពដែលមាន គោលបំណងពិសេស
- ហានិភ័យរបស់ក្រុមហ៊ុនរួម និងធនាគារក្នុងការខាតបង់លើទ្រព្យសកម្មទាក់ទងនឹងឥណទានទាមទារសំណងពេញលេញ
- ទំហំដែលទ្រព្យបញ្ចាំតំណាងឱ្យទាំងអស់ ឬជាផ្នែកសំខាន់នៃទ្រព្យសកម្មរបស់អ្នកខ្ចី និង
- ថាតើក្រុមហ៊ុនរួម និងធនាគារនឹងទទួលបានអត្ថប្រយោជន៍ពីការឡើងតម្លៃណាមួយនៃទ្រព្យសកម្មមូលដ្ឋាននោះដែរឬទេ។

ការធ្វើចំណាត់ថ្នាក់ឡើងវិញ

ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញនៅពេលដែលក្រុមហ៊ុនរួម និងធនាគារផ្លាស់ប្តូរម៉ូឌែលអាជីវកម្មសម្រាប់ការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុរបស់ខ្លួនតែប៉ុណ្ណោះ។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក

## 2. គោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

### 2.7 សង្ខេបនៃគោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

### 2.7.1 ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (តពីទំព័រមុន)

(iii) ការឈប់ទទួលស្គាល់

ទ្រព្យសកម្មហិរញ្ញវត្ថុ

ក្រុមហ៊ុនរួម និងធនាគារ ឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ នៅពេលដែលសិទ្ធិចុះកិច្ចសន្យាសាច់ប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុបានផុតសុពលភាព ឬមានការផ្ទេរសិទ្ធិក្នុងការទទួល លំហូរសាច់ប្រាក់តាមកិច្ចសន្យាក្នុងប្រតិបត្តិការ ដែលហានិភ័យ និងផលចំណេញទាំងអស់នៃភាពជាម្ចាស់លើទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានផ្ទេរ ឬដែលក្រុមហ៊ុនរួម និងធនាគារមិនផ្ទេរ ឬមិនរក្សាទុកនូវរាល់ហានិភ័យ និងផលចំណេញ ហើយមិនរក្សាការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុទេ។

នៅពេលឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ភាពខុសគ្នារវាងតម្លៃយោងក្នុងបញ្ជីរបស់ទ្រព្យសកម្មនោះ (ឬតម្លៃយោង ដែលត្រូវបានបែងចែកតាមចំណែកនៃទ្រព្យសកម្មដែលបានឈប់ទទួលស្គាល់) ជាមួយនឹងផលបូកនៃ (i) ទឹកប្រាក់ដែលទទួលបាន (រាប់បញ្ចូលរាល់ ទ្រព្យសកម្មថ្មីដែលទទួលបានដកបំណុលថ្មីដែលបានសន្មត) និង (ii) រាល់បង្គរចំណេញ ឬខាតដែលបានទទួលស្គាល់រួចនៅក្នុងលទ្ធផលលម្អិតផ្សេងៗត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត។

បំណុលហិរញ្ញវត្ថុ

ក្រុមហ៊ុនរួម និងធនាគារឈប់ទទួលស្គាល់នូវបំណុលហិរញ្ញវត្ថុនៅពេលដែលកាតព្វកិច្ចក្នុងកិច្ចសន្យាត្រូវបានរំសាយ ឬលុបចោល ឬផុតកំណត់។

(iv) ការកែប្រែឥណទាន

នៅពេលដែលឥណទាន បង្ហាញពីភស្តុតាងនៃភាពទន់ខ្សោយឥណទានគួរឱ្យកត់សម្គាល់ ក្រុមហ៊ុនរួម និងធនាគារជូនកាលធ្វើការចរចាឡើងវិញ ឬកែប្រែលំហូរសាច់ប្រាក់តាមកិច្ចសន្យានៃឥណទានជាជាងទទួលការកាន់កាប់ទ្រព្យបញ្ចាំ។ នៅពេលរឿងនេះកើតឡើង ក្រុមហ៊ុនរួម និងធនាគារវាយតម្លៃថាតើលក្ខខណ្ឌថ្មីមានលក្ខណៈខុសគ្នាច្រើន ពីលក្ខខណ្ឌដើមទេ។

ក្រុមហ៊ុនរួម និងធនាគារពិចារណាលើកត្តាដូចខាងក្រោម៖

(ក) ប្រសិនបើអ្នកខ្ចីមានផលលំបាកផ្នែកហិរញ្ញវត្ថុ ថាតើការផ្លាស់ប្តូរគ្រាន់តែកាត់បន្ថយលំហូរសាច់ប្រាក់តាមកិច្ចសន្យាទៅនឹងចំនួនទឹកប្រាក់ដែលអ្នកខ្ចីរំពឹងថាអាចទូទាត់បង់បាន

(ខ) ថាតើមានលក្ខខណ្ឌសំខាន់ថ្មីណាមួយដែលត្រូវបានណែនាំ ហើយជះឥទ្ធិពលខ្លាំងដល់ទម្រង់ហានិភ័យនៃឥណទាននោះដែរឬទេ

(គ) ការពន្យារយៈពេលនៃឥណទានគួរឱ្យកត់សម្គាល់

(ឃ) ការផ្លាស់ប្តូរអត្រាការប្រាក់គួរឱ្យកត់សម្គាល់ និង

(ង) ការបញ្ចូលទ្រព្យបញ្ចាំ ការធានាផ្សេងៗ ឬការកែលម្អឥណទាន ដែលប៉ះពាល់យ៉ាងខ្លាំងដល់ហានិភ័យឥណទានដែលទាក់ទងនឹងឥណទាននោះ។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក

## 2. គោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

### 2.7 សង្ខេបនៃគោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

### 2.7.1 ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (តពីទំព័រមុន)

#### (iv) ការកែប្រែឥណទាន (តពីទំព័រមុន)

ក្រុមហ៊ុនរួម និងធនាគារឈប់ទទួលស្គាល់ឥណទានមួយនៅពេល ដែលលក្ខខណ្ឌនានាត្រូវបានចរចាឡើងវិញក្នុងកម្រិត ដែលឥណទាននោះក្លាយទៅជាឥណទានថ្មី ហើយគណនាឡើងវិញនូវអត្រាការប្រាក់ប្រសិទ្ធភាពថ្មីសម្រាប់ឥណទាននោះ។ កាលបរិច្ឆេទនៃការចរចាឡើងវិញត្រូវបាន ចាត់ទុកថាជាកាលបរិច្ឆេទនៃការទទួលស្គាល់ដំបូងសម្រាប់គោលបំណងគណនាអឺមភែរមិន រួមទាំងគោលបំណងដើម្បីកំណត់ថាតើមានការកើនឡើងនៃហានិភ័យឥណទានគួរឱ្យកត់សម្គាល់ដែរឬទេ។ ទោះជាយ៉ាងណាក្រុមហ៊ុនរួម និងធនាគារក៏វាយតម្លៃផងដែរថាតើឥណទានថ្មីដែលត្រូវបានទទួលស្គាល់ អាចចាត់ទុកថាជាឥណទានមានអ៊ឺមភែរមិននៅពេលទទួលស្គាល់ដំបូងដែរឬទេ ជាពិសេសនៅក្នុងកាលៈទេសៈដែលការចរចាឡើងវិញត្រូវបាន ជំរុញដោយសារកូនបំណុលមិនអាចធ្វើការទូទាត់សងត្រឡប់បានតាមការព្រមព្រៀងលើកដំបូង។

ប្រសិនបើលក្ខខណ្ឌមិនមានលក្ខណៈខុសគ្នាច្រើនការពិភាក្សាឡើងវិញឬការកែប្រែមិនបណ្ដាលឱ្យមានការឈប់ទទួលស្គាល់ ហើយអ៊ឺមភែរមិន នៅតែបន្តវាយតម្លៃសម្រាប់ការកើនឡើងគួរឱ្យកត់សម្គាល់នៃហានិភ័យឥណទានប្រៀបធៀបទៅនឹងហានិភ័យឥណទាននាពេលទទួលស្គាល់ដំបូង។

#### (v) ការកាត់កង

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុអាចកាត់កងគ្នាបាន និងត្រូវបានបង្ហាញជាចំនួនទឹកប្រាក់សុទ្ធនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនៅពេលដែលក្រុមហ៊ុនរួម និងធនាគារមានសិទ្ធិស្របច្បាប់ក្នុងការកាត់កងចំនួនទឹកប្រាក់ ហើយមានបំណងទូទាត់ដោយផ្អែកលើមូលដ្ឋានសុទ្ធ ឬដើម្បីលក់ទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នាតែប៉ុណ្ណោះ។

#### (vi) អ៊ឺមភែរមិន

##### ក) និយមន័យឥណទានអ៊ឺមភែរមិន និងឥណទានខូច

នៅកាលបរិច្ឆេទរបាយការណ៍នីមួយៗ ក្រុមហ៊ុនរួម និងធនាគារវាយតម្លៃថា តើទ្រព្យសកម្មហិរញ្ញវត្ថុមានអ៊ឺមភែរមិនដែរឬទេ។ ជាទូទៅទ្រព្យសកម្មហិរញ្ញវត្ថុមាន អ៊ឺមភែរមិននៅពេលមានព្រឹត្តិការណ៍មួយ ឬច្រើនបានកើតឡើងដែលជះឥទ្ធិពលអាក្រក់ដល់លំហូរសាច់ប្រាក់នាពេលអនាគត ដែលបានរំពឹងទុកនៃទ្រព្យសកម្ម ហិរញ្ញវត្ថុនោះ។

ឥណទានរបស់ក្រុមហ៊ុនរួម និងធនាគារត្រូវបានចាត់ថ្នាក់ជាឥណទានមានអ៊ឺមភែរមិននៅពេលដែលឥណទាននោះស្ថិតក្នុងលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

(1) ប្រាក់ដើម ឬការប្រាក់ ឬទាំងពីរបានហួសកាលកំណត់កៅសិប (90) ថ្ងៃ ឬលើសពីនេះសម្រាប់ឥណទានរយៈពេលវែង (សាមសិបមួយ (31) ថ្ងៃ ឬលើសពីនេះសម្រាប់ឥណទានរយៈពេលខ្លី) ឬ

(2) ចំនួនដែលនៅសល់លើសចំនួនកំណត់ដែលបានអនុម័តក្នុងរយៈពេលកៅសិប (90) ថ្ងៃ ឬលើសនេះសម្រាប់ឥណទានរយៈពេលវែង (សាមសិបមួយ (31) ថ្ងៃឬលើសនេះសម្រាប់ឥណទានរយៈពេលខ្លី) ក្នុងករណីដែលជាឥណទានបង្វិល ឬ

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក

## 2. គោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

### 2.7 សង្ខេបនៃគោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

### 2.7.1 ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (តពីទំព័រមុន)

(vi) អ៊ីមភែរមិន (តពីទំព័រមុន)

ក) និយមន័យឥណទានអ៊ីមភែរមិន និងឥណទានខូច (តពីទំព័រមុន)

(3) នៅពេលដែលឥណទានហួសកាលកំណត់ ឬចំនួនទឹកប្រាក់ដែលនៅសល់លើសចំនួនកំណត់ដែលបានអនុម័តក្នុងរយៈពេលតិចជាងកៅសិប (90) ថ្ងៃ សម្រាប់ឥណទានរយៈពេលវែង (សាមសិបមួយ (31) ថ្ងៃ ឬ តិចជាងនេះសម្រាប់ឥណទានរយៈពេលខ្លី) ប៉ុន្តែឥណទានបង្ហាញពីភាពចុះខ្សោយនៃឥណទានគួរឱ្យកត់សម្គាល់ ឬ

(4) នៅពេលដែលឥណទានមានអ៊ីមភែរមិនត្រូវបានកំណត់ពេលវេលា និងរៀបចំឡើងវិញ ("R&R") ឥណទាននេះនឹងនៅតែចាត់ទុកជាឥណទានមានអ៊ីមភែរមិន រហូតដល់ការសងប្រាក់វិញដោយផ្អែកលើលក្ខខណ្ឌដែលបានផ្លាស់ប្តូរ និង/ឬបានរៀបចំឡើងវិញត្រូវបានបង់ជាបន្តបន្ទាប់ក្នុងរយៈពេលយ៉ាងតិចប្រាំមួយ (6) ខែ ហើយគណនីមានការហួសការកំណត់តិចជាងកៅសិប (90) ថ្ងៃ បន្ទាប់ពីការអនុលោមតាមរយៈពេលថែទាំដែលត្រូវការ ឬ

(5) នៅពេលមានការខូចខាតកើតឡើងភ្លាម សម្រាប់ការទូទាត់សងប្រាក់ត្រឡប់ដែលបានកំណត់នៅចន្លោះពេលកៅសិប (90) ថ្ងៃ ឬលើសពីនេះ រាប់បញ្ចូលទាំងការសងសរុបនាចុងកិច្ចសន្យា។

(6) ការអនុវត្តលើការគ្រប់គ្រងសំពៀត និងហានិភ័យឥទាន ផលប៉ះពាល់ត្រូវគ្រប់គ្រងតាមកម្រិតអ្នកខ្ចី។ កាតព្វកិច្ចទាំងអស់របស់អ្នកខ្ចីមួយ បានកំណត់ថាជាឥណទានមានអ៊ីមភែរមិន ប្រសិនបើមានកាតព្វកិច្ចណាមួយរបស់អ្នកខ្ចីនោះ បានចាត់ទុកថាជាឥណទានខូច។

ជាផ្នែកមួយនៃការវាយតម្លៃអ៊ីមភែរមិនចំពោះទ្រព្យសកម្មហិរញ្ញវត្ថុ ក្រោមម៉ូឌែលនៃការខាតបង់ឥណទានដែលរំពឹងទុក និយមន័យនៃឥណទានខូចត្រូវបានអនុវត្តចំពោះ ម៉ូឌែលប្រូបាប៊ីលីតេនៃឥណទានខូច ("PD") ហានីភ័យនៅពេលឥណទានខូច ("EAD") និងការខាតបង់នៅពេលឥណទានខូច ("LGD")។ និយមន័យនៃឥណទានខូចភាគច្រើនស្របគ្នាទៅនឹងនិយមន័យនៃអ៊ីមភែរមិន សម្រាប់គោលបំណងក្នុងការធ្វើរបាយការណ៍តាមបទប្បញ្ញត្តិ លើកលែងតែហានិភ័យមិនមែនជាសារវន្តដែលមិនត្រូវបានចាត់ទុកថាជាឥណទានខូច ដោយសារការខូចខាតនេះមិនមែនកើតចេញពីហានិភ័យឥណទាន និងហានិភ័យប្រយោលខ្លះទៀត ដែលត្រូវបានចាត់ទុកថាជាការខូចខាតដោយផ្អែកលើមូលដ្ឋានវាយតម្លៃតាមគុណភាព។

ខ) ការវាស់វែងអ៊ីមភែរមិនលើការខាតបង់ឥណទានដែលរំពឹងទុក

ក្រុមហ៊ុនរួម និងធនាគារវាយតម្លៃការខាតបង់ឥណទានរំពឹងទុក ("ECL") តាមមូលដ្ឋាននៃការព្យាករណ៍ទាក់ទងនឹងឧបករណ៍បំណុលទ្រព្យសកម្មរបស់ខ្លួន ដែលបានគិតតាមតម្លៃរំលស់ ហើយជាមួយនឹងហានិភ័យដែលកើតឡើងពីកិច្ចសន្យាឥណទាន និងកិច្ចសន្យាធានាហិរញ្ញវត្ថុ។ ក្រុមហ៊ុនរួម និងធនាគារទទួលស្គាល់នូវសំវិធានធនលើការខាតបង់ ចំពោះការខាតបង់ទាំងនេះតាមកាលបរិច្ឆេទរបាយការណ៍នីមួយៗ។ ការវាស់វែងនៃ ECL ឆ្លុះបញ្ចាំងពីភាពមិនលម្អៀង និងប្រូបាប៊ីលីតេនៃចំនួនទឹកប្រាក់ដែលត្រូវបានកំណត់ដោយមានការវាយតម្លៃលើលទ្ធផលជាច្រើន តម្លៃពេលវេលានៃទឹកប្រាក់ និងភាពសមហេតុផលក៏ដូចជាព័ត៌មានគាំទ្រ ដែលអាចទទួលយកបានដោយមិនចាំបាច់មានចំណាយខ្ពស់ ឬការខិតខំប្រឹងប្រែងនៅកាលបរិច្ឆេទរាយការណ៍ អំពីព្រឹត្តិការណ៍ អតីតកាល លក្ខខណ្ឌបច្ចុប្បន្ន និងការព្យាករណ៍នៃស្ថានភាពសេដ្ឋកិច្ចនាពេលអនាគត។ មិនមានអ៊ីមភែរមិនលើការខាតបង់ទទួលស្គាល់សម្រាប់ភាគហ៊ុនវិនិយោគនោះទេ។

## 2. គោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

### 2.7 សង្ខេបនៃគោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

#### 2.7.1 ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (តពីទំព័រមុន)

(vi) អ៊ីមភែរមិន (តពីទំព័រមុន)

ខ) ការវាស់វែងអ៊ីមភែរមិនលើការខាតបង់ឥណទានដែលរំពឹងទុក (តពីទំព័រមុន)

ក្រុមហ៊ុនរួម និងធនាគារវាយតម្លៃថាតើហានិភ័យឥណទានត្រូវបានកើនឡើងគួរឱ្យកត់សម្គាល់តាមមូលដ្ឋានដាច់ដោយឡែក ឬជារួមដែរឬទេ។ ដំបូងក្រុមហ៊ុនរួម និងធនាគារវាយតម្លៃថាតើមានភស្តុតាងគោលនៃអ៊ីមភែរមិនចំពោះទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមានលក្ខណៈសំខាន់ៗដាច់ដោយឡែកដែរឬទេ។ ប្រសិនបើក្រុមហ៊ុនរួម និងធនាគារកំណត់ថាមានភស្តុតាងនៃអ៊ីមភែរមិន សម្រាប់ទ្រព្យសកម្មដែលបានវាយតម្លៃដាច់ដោយឡែក នោះការខាតបង់ឥណទានដែលរំពឹងទុកមួយអាយុកាល (Lifetime ECL) នឹងត្រូវបានទទួលស្គាល់ចំពោះការខាតបង់នៃអ៊ីមភែរមិននៅពេលកើតឡើង។ ទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានវាយតម្លៃរួមគ្នាត្រូវបានដាក់ជាក្រុមដោយផ្អែកលើលក្ខណៈហានិភ័យឥណទានស្រដៀងគ្នា ដូចជាប្រភេទឧបករណ៍អត្រាហានិភ័យ ឥណទាន ការប្រើប្រាស់ឥណទាន កម្រិតនៃទ្រព្យបញ្ចាំ ប្រភេទទ្រព្យបញ្ចាំ រយៈពេលនៅសល់រហូតដល់កាល និងកត្តាពាក់ព័ន្ធផ្សេងទៀត។ ជារួម សំវិធានធនវាយតម្លៃដាច់ដោយឡែក និងសំវិធានធនវាយតម្លៃជារួម បង្កើតបានជាសំវិធានធនលើអ៊ីមភែរមិន សរុបសម្រាប់ឥណទានបុរេប្រទាន និងហិរញ្ញប្បទាន។

សំវិធានធនសម្រាប់អ៊ីមភែរមិន នឹងត្រូវធ្វើឡើងផ្អែកលើវិធីសាស្ត្របីដំណាក់កាលដូចខាងក្រោម ដែលឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរគុណភាពឥណទាននៃឧបករណ៍ហិរញ្ញវត្ថុចាប់តាំងពីមានការទទួលស្គាល់ដំបូង៖

(1) ដំណាក់កាលទី 1៖ ECL 12 ខែ - មិនមែនឥណទានអ៊ីមភែរមិន

ចំពោះហានិភ័យ ដែលបង្ហាញថាមិនមានការកើនឡើងគួរឱ្យកត់សម្គាល់នៃហានិភ័យឥណទានចាប់តាំងពីការទទួលស្គាល់ដំបូង ហើយដែលមិនមានឥណទានអ៊ីមភែរមិននៅពេលបង្កើតឡើង ECL ទាក់ទងនឹងប្រូបាប៊ីលីតេនៃព្រឹត្តិការណ៍ដែលកើតឡើងក្នុងរយៈពេល 12 ខែបន្ទាប់នឹងទទួលស្គាល់។

(2) ដំណាក់កាលទី 2៖ Lifetime ECL - មិនមែនឥណទានអ៊ីមភែរមិន

ចំពោះហានិភ័យ ដែលបង្ហាញថាមានការកើនឡើងគួរឱ្យកត់សម្គាល់នៃហានិភ័យឥណទានចាប់តាំងពីការទទួលស្គាល់ដំបូង ប៉ុន្តែមិនមែនជាឥណទានអ៊ីមភែរមិន និងមិនមែនជាឥណទានអ៊ីមភែរមិននៅពេលទទួលស្គាល់ដំបូង នោះ Lifetime ECL នឹងត្រូវបានទទួលស្គាល់។

(3) ដំណាក់កាលទី 3៖ Lifetime ECL - ជាឥណទានអ៊ីមភែរមិន

ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានវាយតម្លៃជាឥណទានអ៊ីមភែរមិន នៅពេលមានព្រឹត្តិការណ៍មួយ ឬច្រើនដែលធ្វើឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់លំហូរសាច់ប្រាក់ នាពេលអនាគតរបស់ទ្រព្យសកម្មនោះ។ ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ដែលជាឥណទានអ៊ីមភែរមិន Lifetime ECL នឹងត្រូវបានទទួលស្គាល់។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក

## 2. គោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

### 2.7 សង្ខេបនៃគោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

### 2.7.1 ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (តពីទំព័រមុន)

(vi) អ៊ីមភែរមិន (តពីទំព័រមុន)

ខ) ការវាស់វែងអ៊ីមភែរមិនលើការខាតបង់ឥណទានដែលរំពឹងទុក (តពីទំព័រមុន)

ការកើនឡើងនៃហានិភ័យឥណទានគួរឱ្យកត់សម្គាល់

នៅកាលបរិច្ឆេទរបាយការណ៍នីមួយៗ ក្រុមហ៊ុនរួម និងធនាគារវាយតម្លៃថាតើមានការកើនឡើងគួរឱ្យកត់សម្គាល់នៃហានិភ័យឥណទានចាប់តាំងពីការទទួលស្គាល់ដំបូង ដើម្បីកំណត់ថាតើការប៉ះពាល់ គឺអាស្រ័យលើ ECL 12 ខែ ឬ Lifetime ECL។ ការវាយតម្លៃនេះត្រូវបានអនុវត្តដោយប្រៀបធៀបហានិភ័យនៃការមិនសងប្រាក់ ដែលកើតឡើងក្នុងអាយុកាលរំពឹងទុកដែលនៅសល់ពីកាលបរិច្ឆេទរបាយការណ៍ទៅនឹងកាលបរិច្ឆេទនៃការទទួលស្គាល់ដំបូង។ នៅពេលកំណត់ថាតើហានិភ័យនៃការខកខានសងប្រាក់បានកើនឡើងគួរឱ្យកត់សម្គាល់ចាប់តាំងពីការទទួលស្គាល់ដំបូង ក្រុមហ៊ុនរួម និងធនាគារពិចារណាទាំងបរិមាណ និងគុណភាពនៃព័ត៌មាន និងផ្អែកលើបទពិសោធន៍ដែលមានកន្លងមករបស់ក្រុមហ៊ុនរួម និងធនាគារ និងការវាយតម្លៃហានិភ័យឥណទានរបស់ក្រុមអ្នកជំនាញរួមទាំងព័ត៌មានមើលទៅអនាគត។

លក្ខណៈវិនិច្ឆ័យដើម្បីកំណត់ថាតើហានិភ័យឥណទាន បានកើនឡើងគួរឱ្យកត់សម្គាល់មានភាពខុសគ្នាតាមសំពៀតនីមួយៗ ហើយរួមបញ្ចូលកត្តាបរិមាណ ដូចជាភាពមិនប្រក្រតី ("delinquency") និន្នាការនៃភាពមិនប្រក្រតីកន្លងមក ការផ្លាស់ប្តូរចំណាត់ថ្នាក់ឥណទាន និងកត្តាគុណភាព ក៏ដូចជាព័ត៌មានកន្លងមកដែលផ្អែកលើភាពមិនប្រក្រតី។សម្រាប់សំពៀតលក់រាយ ការរួមបញ្ចូលគ្នានៃភាពមិនប្រក្រតីនិន្នាការនៃភាពមិនប្រក្រតីកន្លងមក និងកត្តាគុណភាព ត្រូវបានប្រើដើម្បីកំណត់ការកើនឡើងនៃហានិភ័យឥណទានគួរឱ្យកត់សម្គាល់។ ចំពោះសំពៀតមិនមែនលក់រាយ ការប្រើប្រាស់ចំណាត់ថ្នាក់ឥណទានផ្ទៃក្នុងត្រូវបានរកឃើញថាជា ការតំណាងសម្រាប់កត្តាល្អបំផុតនៃការកំណត់ហានិភ័យដែលមាន ចំណែកចំណាត់ថ្នាក់ឥណទានតាមប្រភពខាងក្រៅ ដែលកំណត់ដោយភ្នាក់ងារខាងក្រៅបានប្រើប្រាស់សម្រាប់មូលបត្របំណុល។ ក្រុមហ៊ុនរួម និងធនាគារចាត់តាំងសមាជិកនីមួយៗមូលបត្របំណុល និងឧបករណ៍ហិរញ្ញវត្ថុ ចំណាត់ថ្នាក់ឥណទាន នៅពេលទទួលស្គាល់ដំបូង ដោយផ្អែកលើព័ត៌មានដែលអាចរកបានអំពីសមាជិកមូលបត្របំណុល និងឧបករណ៍ហិរញ្ញវត្ថុ។ ហានិភ័យឥណទានត្រូវបានចាត់ទុកថាមានការកើនឡើង ប្រសិនបើចំណាត់ថ្នាក់ឥណទាន បានចុះខ្សោយគួរឱ្យកត់សម្គាល់នាកាលបរិច្ឆេទរបាយការណ៍ដោយប្រៀបធៀបទៅនឹងចំណាត់ថ្នាក់ឥណទាននៅកាលបរិច្ឆេទ នៃការទទួលស្គាល់ដំបូង។ ទោះយ៉ាងណា ដោយមិនគិតពីការផ្លាស់ប្តូរចំណាត់ថ្នាក់ឥណទាន ព័ត៌មានកន្លងមកត្រូវបានប្រើប្រាស់ ហើយទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចាត់ទុកថា មានហានិភ័យ ឥណទានកើនឡើងគួរឱ្យកត់សម្គាល់ ប្រសិនបើទ្រព្យសកម្មហិរញ្ញវត្ថុបានលើសកាលកំណត់ទូទាត់សងតាមកិច្ចសន្យារយៈពេល 30ថ្ងៃ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុរយៈពេលវែង (លើសកាលកំណត់ទូទាត់សងរយៈពេល 15ថ្ងៃ សម្រាប់រយៈពេលខ្លី)។ បន្ថែមពីនេះក្រុមហ៊ុនរួម និងធនាគារអាចកំណត់ថា ហានិភ័យមួយបានបង្ហាញពីការកើនឡើងនៃហានិភ័យ ឥណទានគួរឱ្យកត់សម្គាល់ផ្អែកលើកត្តាគុណភាពជាក់លាក់ដោយប្រើការវិនិច្ឆ័យ ឥណទានជំនាញរបស់ខ្លួន ហើយប្រសិនបើអាចធ្វើបាន យកបទពិសោធន៍ពាក់ព័ន្ធដែលមានកន្លងមក ដែលបទពិសោធន៍នោះត្រូវបានចាត់ទុកថាជាការបង្ហាញពីការកើនឡើងបែបនេះ និងផលប៉ះពាល់ពីនោះមិនអាចឆ្លុះបញ្ចាំងយ៉ាងពេញលេញនៅក្នុងកត្តាបរិមាណរបស់វាទេ។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក

## 2. គោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

### 2.7 សង្ខេបនៃគោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

### 2.7.1 ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (តពីទំព័រមុន)

#### (vi) អ៊ីមផែរមិន (តពីទំព័រមុន)

##### ខ) ការវាស់វែងអ៊ីមផែរមិនលើការខាតបង់ឥណទានដែលរំពឹងទុក (តពីទំព័រមុន)

ការវាស់វែង ECL

ECL ត្រូវបានវាស់វែងដោយប្រើប្រាស់សមាសធាតុបីគឺ PD, LGD និង EAD។ ប៉ារ៉ាម៉ែត្រទាំងនេះត្រូវបានគេយកចេញពីគំរូស្ថិតិផ្ទៃក្នុងដែលត្រូវបានបង្កើតឡើង និងកែសម្រួលដើម្បីឆ្លុះបញ្ចាំងពីព័ត៌មានមានទៅអនាគតដូចដែលបានពិពណ៌នាខាងក្រោម។

PD 12ខែ និងមួយអាយុកាល តំណាងឱ្យប្រូបាប៊ីលីតេនៃពេលវេលាដែលរំពឹងទុក នៃការខកខានសងក្នុងរយៈពេល 12ខែបន្ទាប់ និងអាយុកាលដែលនៅសល់របស់ឧបករណ៍ហិរញ្ញវត្ថុរៀងៗខ្លួន ដោយផ្អែកលើលក្ខខណ្ឌដែលមានស្រាប់ នៅកាលបរិច្ឆេទរបាយការណ៍ និងលក្ខខណ្ឌសេដ្ឋកិច្ចនាពេលអនាគតដែលប៉ះពាល់ដល់ហានិភ័យ ឥណទាន។ LGD តំណាងឱ្យការខាតបង់ដែលរំពឹងទុក ប្រសិនបើព្រឹត្តិការណ៍មួយបានកើតឡើងក្នុងពេលវេលា ដែលបានកំណត់ ដោយគិតគូរពីការកាត់កងនៃទ្រព្យបញ្ចាំដែលជាតម្លៃរំពឹងទុកនៅពេលលក់ និងតម្លៃពេលវេលានៃសាច់ប្រាក់។ EAD តំណាងឱ្យការប៉ះពាល់នៅពេលឥណទានខូចដែលរំពឹងទុក ដោយគិតគូរពីការសងប្រាក់ដើម និងការប្រាក់ចាប់ពីកាលបរិច្ឆេទរបាយការណ៍ទៅនឹងព្រឹត្តិការណ៍នៃឥណទានខូច ជាមួយការដកបន្ថែម នៃឥណទានដែលរំពឹងទុក។ ECL 12ខែ គឺស្មើនឹងការបូកសរុបនៃការបញ្ចុះតម្លៃនៃ PD គុណនឹង LGD និង EAD សម្រាប់រយៈពេល 12 ខែបន្ទាប់។ Lifetime ECL ត្រូវបានគណនាដោយប្រើការបូកសរុបនៃការបញ្ចុះតម្លៃនៃ PD លើអាយុកាលនៅសល់គុណនឹង LGD និង EAD។ អត្រាបញ្ចុះតម្លៃដែលត្រូវបានប្រើក្នុងការវាស់វែង ECL គឺជាអត្រាការប្រាក់មានប្រសិទ្ធភាពដើម ឬប្រហាក់ប្រហែល។

ព័ត៌មានមើលទៅអនាគត

ក្រុមហ៊ុនរួម និងធនាគារបានបង្កើតវិធីសាស្ត្រសម្រាប់អនុវត្តអថេរម៉ាក្រូសេដ្ឋកិច្ចឆ្ពោះទៅមុខ ("MEVs") ដែលមានសូចនាករសេដ្ឋកិច្ច និងស្ថិតិឧស្សាហកម្មក្នុងការវាស់វែង ECL។ នេះពាក់ព័ន្ធនឹងការបញ្ចូល MEVs ទៅក្នុងការប៉ាន់ស្មានរបស់ PD និង LGD តាមរយៈការអនុវត្តនៃខ្នាតមួយ។ ដំណើរការនៃការបង្កើតខ្នាតទាក់ទងនឹងការអភិវឌ្ឍការជាប់ទាក់ទងគ្នានៃ MEVs ទៅនឹងអត្រានៃការមិនសងប្រាក់ និងអត្រានៃការប្រមូលបានមកវិញ សម្រាប់សំពៀតផ្សេងៗនៃទ្រព្យសកម្មហិរញ្ញវត្ថុ ដោយផ្អែកលើការវិភាគទិន្នន័យក្នុងពេលកន្លងមក។ ការជាប់ទាក់ទងគ្នានេះត្រូវបានប្រើ ដើម្បីបង្កើតការព្យាករណ៍មានប្រសិទ្ធភាព (ដែលឆ្លុះបញ្ចាំងតាមរយៈ scalar) រវាង MEVs និង PD ក៏ដូចជា LGD ដោយគិតគូរពីការព្យាករណ៍របស់ MEVs។

MEVsដែលត្រូវបានបញ្ចូលក្នុងការពិចារណារួមមានប៉ុន្តែមិនមានកំណត់ចំពោះអត្រាកំណើនផលិតផលក្នុងស្រុកដុល និងការវិនិយោគ និងតម្រូវឱ្យមានការវាយតម្លៃទាំងនៅពេលបច្ចុប្បន្ន និងការព្យាករណ៍នៃបរិយាកាសសេដ្ឋកិច្ច។ ការព្យាករណ៍របស់ MEVs ត្រូវបានធ្វើឡើងដោយផ្អែកលើលទ្ធផលដែលទំនងបំផុត ("សេណារីយ៉ូសេដ្ឋកិច្ចមូលដ្ឋាន") និងភាពអំណោយផល ("ការតម្លើង") ក៏ដូចជា លទ្ធផលមិនអំណោយផល ("ធ្លាក់ចុះ") បើប្រៀបធៀបទៅនឹងសេណារីយ៉ូសេដ្ឋកិច្ចមូលដ្ឋាន។ សេណារីយ៉ូសេដ្ឋកិច្ចមូលដ្ឋានតំណាងឱ្យលទ្ធផលទំនងបំផុត ហើយស្របតាមព័ត៌មានដែលបានប្រើប្រាស់ដោយក្រុមហ៊ុនរួម និងធនាគារសម្រាប់គោលបំណងផ្សេងទៀត ដូចជាការរៀបចំថវិកា។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក

## 2. គោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

### 2.7 សង្ខេបនៃគោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

#### 2.7.1 ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (តពីទំព័រមុន)

(vi) អ៊ីមភែរមិន (តពីទំព័រមុន)

ខ) ការវាស់វែងអ៊ីមភែរមិនលើការខាតបង់ឥណទានដែលរំពឹងទុក (តពីទំព័រមុន)

ព័ត៌មានមើលទៅអនាគត (តពីទំព័រមុន)

ការព្យាករណ៍ផ្អែកលើសេណារីយ៉ូសេដ្ឋកិច្ចនីមួយៗត្រូវបានអនុម័ត ដោយគណៈកម្មាធិការគ្រប់គ្រងទ្រព្យសម្បត្តិ និងបំណុលរបស់ធនាគារ ("ALCO") ហើយត្រូវបានផ្តល់ជូនក្នុងមួយឆ្នាំម្តង។ ទោះជាយ៉ាងណាក៏ដោយ ការព្យាករណ៍នឹងត្រូវបានពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាព ប្រសិនបើស្ថានភាពសេដ្ឋកិច្ចមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់។ ការថ្លឹងទម្ងន់សេណារីយ៉ូសម្រាប់សេណារីយ៉ូសេដ្ឋកិច្ចនីមួយៗ ក៏ត្រូវបានកំណត់តាមរយៈការវិភាគស្ថិតិ ដោយយោងទៅលើការព្យាករណ៍ពីខាងក្នុងនិងខាងក្រៅ។ ការថ្លឹងទម្ងន់លើ សេណារីយ៉ូនឹងត្រូវបានប្រើ ដើម្បីទទួលប្រូបាប៊ីលីតេទម្ងន់នៃ scalar មួយ សម្រាប់សំពៀតនីមួយៗ ដែលនឹងត្រូវបានប្រើដើម្បីកែតម្រូវ PD និង LGD នៃសំពៀតផ្ទាល់នីមួយៗ។

តម្លៃយោងនៃទ្រព្យសកម្ម (ក្រៅពីឧបករណ៍បំណុលដែលបានវាស់វែងដោយ FVOCI) គឺត្រូវបានកាត់បន្ថយតាមរយៈការប្រើគណនីសំវិធានធន ហើយការខាតបង់ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលពេញលេញ។ ប្រសិនបើក្នុងឆ្នាំបន្តបន្ទាប់ ចំនួនការខាតបង់អ៊ីមភែរមិនដែលបានប៉ាន់ស្មានមានការកើនឡើង ឬថយចុះ ដោយសារតែមានព្រឹត្តិការណ៍កើតឡើងបន្ទាប់ពីអ៊ីមភែរមិនត្រូវបានទទួលស្គាល់ ការខាតបង់អ៊ីមភែរមិនដែលបានទទួលស្គាល់ពីមុនត្រូវបានបន្ថែម ឬបន្ថយដោយការកែសម្រួលលើគណនីសំវិធានធននោះ។

ចំពោះកិច្ចសន្យាឥណទាន និងកិច្ចសន្យាធានាហិរញ្ញវត្ថុ សំវិធានធនបាត់បង់ត្រូវបានទទួលស្គាល់ថាជាសំវិធានធនសម្រាប់អ៊ីមភែរមិនលើកិច្ចសន្យាឥណទាននិងកិច្ចសន្យាធានាហិរញ្ញវត្ថុដែលត្រូវបានរាយការណ៍ក្រោម "ទ្រព្យអកម្មផ្សេងៗ" នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

គ) ការលុបចេញ

នៅពេលដែលឥណទានមិនអាចប្រមូលបាន ឥណទាននោះត្រូវបានលុបចោលធៀបនឹងសំវិធានធនដែលពាក់ព័ន្ធសម្រាប់ឥណទានអ៊ីមភែរមិន។ ឥណទានបែបនេះ ត្រូវបានលុបចោលបន្ទាប់ពីនីតិវិធីចាំបាច់នានាត្រូវបានបញ្ចប់ ហើយតម្លៃនៃការបាត់បង់ត្រូវបានកំណត់។ ការប្រមូលបានមកវិញនូវចំនួនទឹកប្រាក់ដែលបានលុបចោលពីមុន ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលពេញលេញ។

#### 2.7.2 សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សម្រាប់គោលបំណងនៃរបាយការណ៍លំហូរសាច់ប្រាក់ សាច់ប្រាក់ និងសាច់ប្រាក់សមមូលមានដូចជា សាច់ប្រាក់ ប្រាក់បញ្ញើជាមួយធនាគារផ្សេងៗទៀត និងការវិនិយោគសាច់ប្រាក់ងាយស្រួលមានរយៈពេលខ្លី ជាមួយនឹងអាយុកាលកំណត់ដើមតិចជាងកៅសិបថ្ងៃ ហើយអាចបំលែងភ្លាមទៅជាបរិមាណសាច់ប្រាក់បានកំណត់។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក

## 2. គោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

### 2.7 សង្ខេបនៃគោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

#### 2.7.3 មូលធន

ភាគហ៊ុនធម្មតាត្រូវបានចាត់ថ្នាក់ជាមូលធន។ ការចំណាយបន្ថែមដែលទាក់ទងដោយផ្ទាល់ទៅនឹងការចេញផ្សាយប័ណ្ណភាគហ៊ុនត្រូវទទួលស្គាល់ជាមូលធន ដោយកាត់ចេញពីចំណូលនៃការលក់ភាគហ៊ុន។ ការចែកចាយដល់អ្នកកាន់កាប់ឧបករណ៍ហិរញ្ញវត្ថុ ដែលត្រូវបានចាត់ថ្នាក់ជាឧបករណ៍មូលធនត្រូវបានគិតថ្លៃដោយផ្ទាល់ទៅមូលធន។

#### 2.7.4 ទុនបម្រុងមិនអាចបែងចែកបាន និងទុនបម្រុងតាមបទប្បញ្ញត្តិ

ទុនបម្រុងតាមបទប្បញ្ញត្តិត្រូវបានបង្កើតឡើង សម្រាប់ភាពខុសគ្នារវាងការផ្តល់សំវិធានធនសម្រាប់ការខាតបង់ឥណទានរំពឹងទុក ដែលបានកំណត់ក្នុងការអនុលោមតាម CIFRS 9 ឧបករណ៍ហិរញ្ញវត្ថុ និងសំវិធានធនតាមបទប្បញ្ញត្តិដោយអនុលោមតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជា លេខ ធ7-017-344 ចុះថ្ងៃទី1 ខែធ្នូ ឆ្នាំ2017 និងសារាចរណែនាំលេខ ធ7-018-001 ចុះថ្ងៃទី16 ខែកុម្ភៈ ឆ្នាំ2018 ស្តីពីការចាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនសម្រាប់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ។ ធនាគារត្រូវប្រៀបធៀបសំវិធានធនតាមបទប្បញ្ញត្តិ ដែលបានគណនាដោយអនុលោមតាមប្រកាសទៅនឹងសំវិធានធនដែលបានគណនាដោយអនុលោមតាម CIFRS 9 ហើយ៖

(i) ក្នុងករណី សំវិធានធនតាមបទប្បញ្ញត្តិដែលបានគណនាទាបជាងសំវិធានធនដែលបានគណនាដោយអនុលោមតាម CIFRS 9 ធនាគារត្រូវកត់ត្រាសំវិធានធនដែលបានគណនាផ្អែកតាម CIFRS 9 និង

(ii) ក្នុងករណី សំវិធានធនតាមបទប្បញ្ញត្តិដែលបានគណនាខ្ពស់ជាងសំវិធានធនដែលបានគណនាដោយអនុលោមតាម CIFRS 9 ធនាគារត្រូវកត់ត្រាសំវិធានធនដែលបានគណនាផ្អែកតាម CIFRS 9 ហើយផ្ទេរលម្អៀងនោះពីប្រាក់ចំណូលដែលបានរក្សាទុក ឬគណនីខាតបង់បង្គរ ចូលទៅក្នុងគណនីទុនបម្រុងបទប្បញ្ញត្តិក្នុងផ្នែកមូលធននៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

ប្រកាសស្តីពីការធ្វើសំវិធានធនតាមបទប្បញ្ញត្តិ តម្រូវឱ្យធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុចាត់ថ្នាក់សំពៀតឥណទានជាប្រាំថ្នាក់ និងផ្តល់សំវិធានធនតាមបទប្បញ្ញត្តិទូទៅ និងជាក់លាក់ដោយផ្អែកលើចំណាត់ថ្នាក់ឥណទានដូចខាងក្រោម៖

| *ចំណាត់ថ្នាក់* | *ចំនួនថ្ងៃលើសកាលកំណត់* | *អត្រាសំវិធានធន* |
|---|---|---|
| ស្តង់ដា | 0 ទៅ 14 ថ្ងៃ(រយៈពេលខ្លី)<br>0 ទៅ 29 ថ្ងៃ(រយៈពេលវែង) | 1% |
| ឃ្លាំមើល | 15 ថ្ងៃ ទៅ 30 ថ្ងៃ(រយៈពេលខ្លី)<br>30 ថ្ងៃ ទៅ 89 ថ្ងៃ(រយៈពេលវែង) | 3% |
| ក្រោមស្តង់ដារ | 31 ថ្ងៃ ទៅ 60 ថ្ងៃ(រយៈពេលខ្លី)<br>90 ថ្ងៃ ទៅ 179 ថ្ងៃ(រយៈពេលវែង) | 20% |
| សង្ស័យ | 61 ថ្ងៃ ទៅ 90 ថ្ងៃ(រយៈពេលខ្លី)<br>180 ថ្ងៃ ទៅ 359 ថ្ងៃ(រយៈពេលវែង) | 50% |
| បាត់បង់ | ចាប់ពី 91 ថ្ងៃ(រយៈពេលខ្លី)<br>360 ថ្ងៃ ឬលើសពីនេះ(រយៈពេលវែង) | 100% |

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក

## 2. គោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

### 2.7 សង្ខេបនៃគោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

#### 2.7.4 ទុនបម្រុងមិនអាចបែងចែកបាន និងទុនបម្រុងតាមបទប្បញ្ញត្តិ (តពីទំព័រមុន)

ក្នុងខែធ្នូ ឆ្នាំ2021 ធនាគារជាតិនៃកម្ពុជាបានចេញសារាចរណែនាំលេខ ធ7-021-2314 ដើម្បីផ្តល់នូវការណែនាំបន្ថែមទៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុក្នុងការធ្វើចំណាត់ថ្នាក់លើឥណទាន ដែលបានធ្វើការរៀបចំឡើងវិញគិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 ហើយផ្តល់សំវិធានធនតាមបទប្បញ្ញត្តិ។ សារាចរណែនាំនេះតម្រូវឱ្យធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុធ្វើចំណាត់ថ្នាក់ចំពោះឥណទានរៀបចំឡើងវិញដូចតទៅ៖

- ឃ្លាំមើល - បើសិនឥណទានដែលរៀបចំឡើងវិញមាន ស្ថានភាព "ល្អ" ឬ "ឥណទានដំណើការ"
- ក្រោមស្តង់ដា - បើសិនជាឥណទានដែលរៀបចំឡើងវិញលើកទីមួយ ហើយនឹងត្រូវការធ្វើការរៀបចំឡើងវិញបន្ថែមទៀត
- សង្ស័យ - បើសិនជាឥណទានដែលរៀបចំឡើងវិញលើកទីពីរ ហើយនឹងត្រូវការធ្វើការរៀបចំឡើងវិញបន្ថែមទៀត
- បាត់បង់ - បើសិនឥណទានដែលរៀបចំឡើងវិញមាន ស្ថានភាព "មិនល្អ" ឬ "ឥណទានមិនដំណើរការ"

ឥណទានដែលបានរៀបចំឡើងវិញត្រូវបានធ្វើចំណាត់ថ្នាក់ដោយអនុលោមតាមរយៈពេលវាយតម្លៃនិងរយៈពេលថៃទាំព្រមទាំងការណែនាំផ្សេងៗដែលបានចេញផ្សាយក្រោមសារាចរណែនាំនេះ និងបានផ្តល់ សំវិធានធនតាមបទប្បញ្ញត្តិដែលពាក់ព័ន្ធ។

#### 2.7.5 ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារ

ការដាក់ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារត្រូវបានកត់ត្រាតាមតម្លៃដើមដកនឹងអ៊ីមផែរមិនសម្រាប់ចំនួនមិនអាចប្រមូលបាន។

#### 2.7.6 ឥណទាន និងបុរេប្រទាន

ឥណទាន និងបុរេប្រទាន ដែលមានក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុត្រូវបានវាស់វែងដោយតម្លៃរំលស់។ ដំបូងឥណទាន និងបុរេប្រទានត្រូវបានវាស់វែងតាមតម្លៃសមស្រប បូកនឹងចំណាយប្រតិបត្តិការបន្ថែមផ្ទាល់ ហើយក្រោយមក គិតជាតម្លៃរំលស់ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់មានប្រសិទ្ធភាព។

#### 2.7.7 ក្រុមហ៊ុនបុត្រសម្ព័ន្ធ

ក្រុមហ៊ុនបុត្រសម្ព័ន្ធ គឺជាអង្គភាពដែលធនាគារមានសមត្ថភាពគ្រប់គ្រងគោលនយោបាយហិរញ្ញវត្ថុ និងប្រតិបត្តិការដើម្បីទទួលបានអត្ថប្រយោជន៍ពីសកម្មភាពរបស់ពួកគេ។ អាទិភាព និងឥទ្ធិពលនៃសិទ្ធិបោះឆ្នោតដែលមានសក្តានុពលដែលបច្ចុប្បន្នអាចអនុវត្តបាន ឬផ្លាស់ប្តូរត្រូវបានពិចារណានៅពេលវាយតម្លៃថាតើធនាគារមានអំណាចបែបនេះលើអង្គភាពផ្សេងទៀតដែរឬទេ។

នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ការវិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវបានកត់ត្រា តាមតម្លៃដើមដកអ៊ីមផែរមិនលើការខាតបង់។ ចំពោះការលក់លើការវិនិយោគ ភាពខុសគ្នារវាងចំណូលពីការលក់សុទ្ធទៅនឹងតម្លៃយោង ត្រូវបានបញ្ចូលទៅក្នុងរបាយការណ៍លទ្ធផលពេញលេញ។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក

## 2. គោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

### 2.7 សង្ខេបនៃគោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

### 2.7.8 ការរួមបញ្ចូលអាជីវកម្ម

ការរួមបញ្ចូលអាជីវកម្មត្រូវបានរាប់បញ្ចូលដោយប្រើវិធីសាស្ត្រទិញ។ ថ្លៃដើមនៃការទិញត្រូវបានវាស់វែងជាការបូកសរុបនៃតម្លៃតបស្នងដែលបានផ្ទេរ វាស់វែងនៅកាលបរិច្ឆេទនៃការទិញជាតម្លៃសមស្រប និងចំនួនទឹកប្រាក់របស់ភាគកម្មអប្បភាគដែលមានក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ។សម្រាប់ការរួមបញ្ចូលអាជីវកម្មនីមួយៗក្រុមហ៊ុនរួមត្រូវជ្រើសរើសថាតើត្រូវវាស់វែងភាគកម្មអប្បភាគ ដែលមានក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធតាមតម្លៃសមស្រប ឬតាមចំណែកសមាមាត្រនៃទ្រព្យសកម្មសុទ្ធដែលអាចកំណត់អត្តសញ្ញាណបាន។ ការចំណាយពីការទិញដែលបានកើតឡើង ត្រូវបានកត់ជាចំណាយហើយរាប់បញ្ចូលទៅក្នុងចំណាយរដ្ឋបាល។ នៅពេលក្រុមហ៊ុនរួមទិញអាជីវកម្មមួយ ក្រុមហ៊ុនរួមវាយតម្លៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ ដែលត្រូវបានសន្មតសម្រាប់ការធ្វើចំណាត់ថ្នាក់ និងការរចនាសមស្របតាមលក្ខខណ្ឌកិច្ចសន្យាស្ថានភាពសេដ្ឋកិច្ច និងលក្ខខណ្ឌពាក់ព័ន្ធគិតត្រឹមកាលបរិច្ឆេទទិញ។ ក្នុងនោះក៏មានរួមបញ្ចូលទាំងការបំបែកនៃនិស្សន្ទដែលបានបង្កប់នៅក្នុងកិច្ចសន្យាគោលរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធផងដែរ។

### 2.7.9 ទ្រព្យ និងបរិក្ខារ

#### (i) ការទទួលស្គាល់ និងការវាស់វែង

ទ្រព្យ និងបរិក្ខារទាំងអស់ ត្រូវបានវាស់តាមតម្លៃដើមដករំលស់បង្គរ និងការខាតបង់អឹមតែរមិនបង្គរដែលមាន។ ថ្លៃដើមរួមបញ្ចូលការចំណាយ ដែលកើតចេញដោយផ្ទាល់ពីការទិញទ្រព្យសកម្ម និងការចំណាយផ្សេងៗទៀតដែលកើតចេញដោយផ្ទាល់ ដើម្បីធ្វើឱ្យទ្រព្យសកម្មមានលក្ខណៈដំណើរការបានតាមការប្រើប្រាស់ដែលបានគ្រោងទុក។ ការចំណាយលើទ្រព្យសកម្មដែលបង្កើតដោយខ្លួនឯង រួមបញ្ចូលទាំងថ្លៃដើមនៃវត្ថុធាតុដើម និងកម្លាំងពលកម្មផ្ទាល់ផងដែរ។ ការទិញកម្មវិធីដែលជាផ្នែកមួយសំខាន់ចំពោះមុខងារ និងទាក់ទងជាមួយបរិក្ខារមួយត្រូវបានចុះបញ្ជីជាផ្នែកនៃបរិក្ខារនោះ។ នៅពេលផ្នែកសំខាន់ៗនៃទ្រព្យ និងបរិក្ខារមានអាយុកាលប្រើប្រាស់ផ្សេងៗគ្នាផ្នែកទាំងនោះត្រូវបានចាត់ទុកជាទ្រព្យ ដាច់ដោយឡែកពីគ្នា (សមាសធាតុសំខាន់ៗ) នៃទ្រព្យ និងបរិក្ខារ។

ចំណេញ ឬខាតលើការលក់ទ្រព្យ និងបរិក្ខារ ត្រូវបានកំណត់តាមរយៈការប្រៀបធៀបផលចំណេញពីការលក់ជាមួយនឹងតម្លៃយោងនៃទ្រព្យ និងបរិក្ខារ ហើយត្រូវបានទទួលស្គាល់ក្នុងនៅក្នុងរបាយការណ៍លទ្ធផលពេញលេញ។

#### (ii) ការចំណាយបន្តបន្ទាប់

ការចំណាយក្នុងការប្តូរសមាសធាតុនៃទ្រព្យ និងបរិក្ខារត្រូវបានទទួលស្គាល់ទៅក្នុងតម្លៃយោងនៃទ្រព្យសកម្មនោះប្រសិនបើការចំណាយនោះអាចរំពឹងថា អត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតក្នុងសមាសធាតុនោះនឹងហូរចូលក្រុមហ៊ុនរួម និងធនាគារ ហើយថ្លៃដើមនៃការចំណាយនោះអាចត្រូវបានវាស់វែងប្រកបដោយភាពជឿទុកចិត្តបាន។ តម្លៃយោងរបស់សមាសធាតុដែលបានប្តូរចេញ ត្រូវបានឈប់ទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលពេញលេញ។ ការចំណាយលើការប្រើប្រាស់ប្រចាំថ្ងៃនៃទ្រព្យ និងបរិក្ខារត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលពេញលេញនៅពេលកើតឡើង។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក

## 2. **គោលនយោបាយគណនេយ្យជាសារវន្ត** (តពីទំព័រមុន)

### 2.7 សង្ខេបនៃគោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

#### 2.7.9 ទ្រព្យ និងបរិក្ខារ (តពីទំព័រមុន)

(iii) ការរំលស់

ការរំលស់ ត្រូវបានទទួលស្គាល់ថាជាការចំណាយនៅក្នុងរបាយការណ៍លទ្ធផលពេញលេញតាមអាយុកាលអាចប្រើប្រាស់បានដែលបានប៉ាន់ប្រមាណតាមសមាសធាតុនីមួយៗ នៃធាតុរបស់ទ្រព្យ និងបរិក្ខារមួយ។

ការរំលស់ត្រូវបានទទួលស្គាល់ចាប់ពីកាលបរិច្ឆេទដែលទ្រព្យ និងបរិក្ខារត្រូវបានតំឡើង និងត្រៀមរួចរាល់សម្រាប់ប្រើប្រាស់ ឬចំពោះទ្រព្យសកម្មដែលបានសាងសង់ផ្ទាល់ខ្លួន ចាប់ពីកាលបរិច្ឆេទដែលទ្រព្យសកម្មនោះត្រូវបានបញ្ចប់ការសាងសង់ និងត្រៀមរួចរាល់សម្រាប់ប្រើប្រាស់។

សំណង់ដែលកំពុងសាងសង់មិនត្រូវបានរំលស់ឡើយ។ ការរំលស់លើទ្រព្យ និងបរិក្ខារលើកលែងតែអគារត្រូវបានគិតជាចំណាយក្នុងរបាយការណ៍លទ្ធផលពេញលេញដោយផ្អែកលើមូលដ្ឋានតម្លៃធ្លាក់ចុះក្នុងអត្រាដូចខាងក្រោម៖

| | អត្រា |
|---|---|
| ការកែលម្អអគារជួល | 20% |
| គ្រឿងសង្ហារឹម គ្រឿងបំពាក់ និងបរិក្ខារ | 25% |
| ឧបករណ៍ព័ត៌មានវិទ្យា | 50% |
| យានយន្ត | 25% |

អគារត្រូវបានធ្វើរំលស់តាមវិធីសាស្ត្ររំលស់ថេរតាមអត្រា 5% ក្នុងមួយឆ្នាំ។

វិធីសាស្ត្រធ្វើរំលស់អាយុកាលប្រើប្រាស់ និងតម្លៃសំណល់ត្រូវបានវាយតម្លៃនៅចុងបញ្ចប់នៃកាលបរិច្ឆេទរបាយការណ៍ ហើយការកែសម្រួលនឹងត្រូវធ្វើឡើងនៅពេលមានការផ្លាស់ប្តូរការប៉ាន់ស្មានពីមុន និងលំនាំរំពឹងទុកនៃការប្រើប្រាស់ផលចំណេញសេដ្ឋកិច្ចនាពេលអនាគត ដែលបានបញ្ចូលនៅក្នុងទ្រព្យ និងបរិក្ខារ។

#### 2.7.10 ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបីរួមមាន អាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រដែលទទួលបាន និងថ្លៃដើមដែលទាក់ទង ត្រូវបានកត់ត្រាតាមថ្លៃដើមដករំលស់បង្គរ និងការខាតបង់អ៊ីមតែរមិន។ ចំណាយអាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រដែលទទួលបានត្រូវបានធ្វើមូលធនកម្មនៅពេលវាកើតឡើងដោយផ្ទាល់ដើម្បីធ្វើឱ្យកុំព្យូទ័រនោះអាចដំណើរការបានតាមគម្រោងកំណត់របស់គណៈគ្រប់គ្រង។

ទ្រព្យសកម្មអរូបីត្រូវបានធ្វើរំលស់តាមវិធីសាស្ត្ររំលស់ថេរក្នុងអត្រា 10% ក្នុងមួយឆ្នាំ។

ការចំណាយទាក់ទងនឹងការថែរក្សាកម្មវិធីកុំព្យូទ័រ ត្រូវបានទទួលស្គាល់ថាជាការចំណាយនៅពេលកើតឡើង។

#### 2.7.11 ភតិសន្យា

នៅពេលចាប់ផ្តើមកិច្ចសន្យាក្រុមហ៊ុនរួមនិងធនាគារវាយតម្លៃថាតើកិច្ចសន្យាគឺជាឬមានការជួល។កិច្ចសន្យាដែលជាឬមានការជួល ប្រសិនបើកិច្ចសន្យានោះមានបញ្ជាក់ពីសិទ្ធិគ្រប់គ្រងលើការប្រើប្រាស់ទ្រព្យសកម្មមួយដែលបានកំណត់ក្នុងរយៈពេលកំណត់មួយដើម្បីទូទាត់ជាមួយតម្លៃតបស្នង។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក

## 2. គោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

### 2.7 សង្ខេបនៃគោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

#### 2.7.11 ភតិសន្យា (តពីទំព័រមុន)

ដើម្បីវាយតម្លៃ ថាតើកិច្ចសន្យាមានបញ្ជាក់ពីសិទ្ធិគ្រប់គ្រងលើការប្រើប្រាស់ទ្រព្យសកម្មដែលបានកំណត់ ក្រុមហ៊ុនរួម និងធនាគារវាយតម្លៃថាតើៈ

- កិច្ចសន្យាពាក់ព័ន្ធនឹងការប្រើប្រាស់ទ្រព្យដែលបានកំណត់ នេះអាចត្រូវបានបញ្ជាក់ដោយផ្ទាល់ ឬដោយប្រយោល ហើយគួរតែមានបញ្ជាក់ជាលក្ខណៈរូបវន្ត ឬតំណាងឱ្យទំហំទាំងអស់នៃទ្រព្យសកម្មដែលមានបញ្ជាក់ជាលក្ខណៈរូបវន្ត។ ប្រសិនបើអ្នកផ្គត់ផ្គង់មានសិទ្ធិជំនួសក្នុងរយៈពេលណាមួយក្នុងអំឡុងពេលប្រើប្រាស់ នោះទ្រព្យសកម្មមិនត្រូវអាចកំណត់បានទេ

- ក្រុមហ៊ុនរួម និងធនាគារមានសិទ្ធិទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ចយ៉ាងច្រើនពីការប្រើប្រាស់ទ្រព្យក្នុងអំឡុងពេលប្រើប្រាស់ និង

- ក្រុមហ៊ុនរួម និងធនាគារមានសិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្មដោយផ្ទាល់។ ក្រុមហ៊ុនរួម និងធនាគារមានសិទ្ធិនេះនៅពេល ដែលខ្លួនមានសិទ្ធិធ្វើការសម្រេចចិត្តដែលពាក់ព័ន្ធបំផុតក្នុងការផ្លាស់ប្តូររបៀប និងគោលបំណងសម្រាប់ប្រើប្រាស់ទ្រព្យសកម្មនេះ។ ក្នុងករណីដែលការសម្រេចចិត្តទាំងអស់អំពីរបៀបប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានកំណត់ទុកជាមុន ក្រុមហ៊ុនរួម និងធនាគារៈ
  - មានសិទ្ធិធ្វើប្រតិបត្តិការលើទ្រព្យសកម្ម ឬ
  - មានសិទ្ធិរចនាទ្រព្យសកម្មតាមរបៀបដែលកំណត់ទុកជាមុននូវរបៀប និងគោលបំណងដែលនឹងត្រូវប្រើប្រាស់។

សម្រាប់ការជួលដី និងអគារដែលខ្លួនជាអ្នកជួល ក្រុមហ៊ុនរួម និងធនាគារបានជ្រើសរើសការមិនបំបែកសមាសធាតុមិនមែនជាការជួល ហើយត្រូវរាប់បញ្ចូលសមាសធាតុជាការជួល និងមិនមែនជាការជួលជាសមាសធាតុនៃការជួលតែមួយ។

##### ភតិសន្យាដែលក្រុមហ៊ុនរួម និងធនាគារជាអ្នកជួល

ក្រុមហ៊ុនរួម និងធនាគារទទួលស្គាល់នូវសិទ្ធិប្រើប្រាស់លើទ្រព្យសកម្ម និងបំណុលភតិសន្យានាកាលបរិច្ឆេទចាប់ផ្តើមជួល។ សិទ្ធិប្រើប្រាស់លើទ្រព្យសកម្មត្រូវបានវាស់វែងដំបូងតាមថ្លៃដើម ដែលរួមមានចំនួនទឹកប្រាក់នៃបំណុលភតិសន្យាដំបូង ដែលត្រូវបានកែតម្រូវជាមួយការទូទាត់ភតិសន្យាដែលបានធ្វើឡើងនៅ ឬមុនកាលបរិច្ឆេទចាប់ផ្តើម បូករួមនឹងចំណាយពាក់ព័ន្ធដំបូងដែលបានកើតឡើង និងការប៉ាន់ប្រមាណនៃចំណាយដើម្បីរុះរើ និងដកចេញទ្រព្យសកម្មនោះ ឬដើម្បីស្តារឡើងវិញនូវទ្រព្យសកម្មនោះ ឬទីតាំងរបស់ទ្រព្យនោះ ដកនឹងផលប្រយោជន៍ពីការជួលណាដែលទទួលបាន។

សិទ្ធិនៃការប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានរំលស់ជាបន្តបន្ទាប់ដោយប្រើវិធីសាស្ត្ររំលស់ថេរចាប់ពីកាលបរិច្ឆេទចាប់ផ្តើមរហូតដល់ចុងបញ្ចប់នៃរយៈពេលជួល។ បន្ថែមពីនេះទៀតសិទ្ធិលើការ ប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានកាត់បន្ថយជាទៀងទាត់ដោយការខាតបង់អឹមភែរមិន ប្រសិនបើមាន ហើយត្រូវបានកែតម្រូវតាមការវាស់វែងជាក់លាក់ម្តងទៀតនៃបំណុលភតិសន្យា។

បំណុលភតិសន្យា ត្រូវបានវាស់វែងដំបូងតាមតម្លៃបច្ចុប្បន្ននៃការទូទាត់ភតិសន្យាទាំងអស់ ដែលមិនបានបង់នៅកាលបរិច្ឆេទចាប់ផ្តើម ដោយបានបញ្ចុះតម្លៃតាមអត្រាប្រាក់កម្ចីកើនឡើងរបស់ខ្លួន។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក

## 2. គោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

### 2.7 សង្ខេបនៃគោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

#### 2.7.11 ភតិសន្យា (តពីទំព័រមុន)

ភតិសន្យាដែលក្រុមហ៊ុនរួម និងធនាគារជាអ្នកជួល (តពីទំព័រមុន)

ការទូទាត់ភតិសន្យាដែលមាននៅក្នុងការវាស់វែង នៃបំណុលភតិសន្យារួមមាន៖

- ការទូទាត់ថេរ រួមទាំងការទូទាត់ជារូបធាតុថេរ
- ការទូទាត់ភតិសន្យា ដែលស្ថិតនៅក្នុងជម្រើសនៃការបន្ត ប្រសិនបើក្រុមហ៊ុនរួម និងធនាគារមានភាពប្រាកដក្នុងការអនុវត្តជម្រើសនៃការបន្តនេះ។

បំណុលភតិសន្យា ត្រូវបានវាស់វែងតាមចំណាយរំលស់ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។ បំណុលនេះត្រូវបានវាស់វែងឡើងវិញនៅពេលមានការផ្លាស់ប្តូររយៈពេលជួល ឬការផ្លាស់ប្តូរការ ទូទាត់ ភតិសន្យានាពេលអនាគត។

នៅពេលដែលបំណុលភតិសន្យាត្រូវបានកែប្រែឡើងវិញតាមវិធីនេះ ការកែតម្រូវឱ្យត្រូវគ្នាត្រូវបានធ្វើឡើងចំពោះតម្លៃយោងរបស់សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្មឬត្រូវបានកត់ក្នុងរបាយការណ៍លទ្ធផលពេញលេញប្រសិនបើតម្លៃយោងរបស់សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្មត្រូវបានកាត់បន្ថយដល់សូន្យ។

ភតិសន្យារយៈពេលខ្លី និងភតិសន្យានៃទ្រព្យសកម្មមានតម្លៃទាប

ក្រុមហ៊ុនរួម និងធនាគារបានជ្រើសរើសមិនទទួលស្គាល់សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម និងបំណុលជួលសម្រាប់ភតិសន្យារយៈពេលខ្លី ដែលមានរយៈពេលជួល 12ខែ ឬតិចជាងនេះ និងភតិសន្យានៃទ្រព្យសកម្មមានតម្លៃទាប។ ក្រុមហ៊ុនរួម និងធនាគារទទួលស្គាល់ការទូទាត់ភតិសន្យាដែលទាក់ទងនឹងភតិសន្យាទាំងនេះជាការចំណាយផ្អែកលើមូលដ្ឋានថេរតាមរយៈពេលជួល។

#### 2.7.12 សំវិធានធន

សំវិធានធនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ នៅពេលដែលក្រុមហ៊ុនរួម និងធនាគារមានកាតព្វកិច្ចផ្លូវច្បាប់ ឬតាមការសន្មតដែលជាលទ្ធផលនៃព្រឹត្តិការណ៍កន្លងមក ហើយវាអាចទៅរួចដែលថាលំហូរចេញនៃអត្ថប្រយោជន៍សេដ្ឋកិច្ច នឹងត្រូវការដើម្បីដោះស្រាយកាតព្វកិច្ចនោះ។ ប្រសិនបើផលប៉ះពាល់នៃតម្លៃពេលវេលានៃទឹកប្រាក់មានភាពជាសារវន្ត សំវិធានធនត្រូវបានកំណត់ដោយការធ្វើអប្បហារលំហូរសាច់ប្រាក់នាពេលអនាគតដែលរំពឹងទុកក្នុងអត្រាមុនពន្ធ ដែលឆ្លុះបញ្ចាំងពីការវាយតម្លៃលើទីផ្សារបច្ចុប្បន្ន នៃតម្លៃពេលវេលានៃទឹកប្រាក់ និងនៅពេលដែលសមស្រប ហានិភ័យជាក់លាក់ចំពោះបំណុលនោះ។ អប្បហារត្រឡប់មកវិញត្រូវបានទទួលស្គាល់ថាជាចំណាយហិរញ្ញវត្ថុ។

#### 2.7.13 ចំណូល និងចំណាយការប្រាក់

អត្រាការប្រាក់មានប្រសិទ្ធភាព

ចំណូល និងចំណាយការប្រាក់ បានទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផលពេញលេញ ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់មានប្រសិទ្ធភាព។ "អត្រាការប្រាក់មានប្រសិទ្ធភាព" គឺជាអត្រាដែលបញ្ចុះតម្លៃយ៉ាងជាក់លាក់ដោយប៉ាន់ស្មានការទូទាត់សាច់ប្រាក់នាពេលអនាគត ឬវិក្កយបត្រតាមអាយុកាលរំពឹងទុករបស់ឧបករណ៍ហិរញ្ញវត្ថុទៅនឹង៖

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក

## 2. គោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

### 2.7 សង្ខេបនៃគោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

#### 2.7.13 ចំណូល និងចំណាយការប្រាក់

អត្រាការប្រាក់មានប្រសិទ្ធភាព (តពីទំព័រមុន)

- តម្លៃយោងដុលនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬ
- តម្លៃរំលស់នៃបំណុលហិរញ្ញវត្ថុ។

នៅពេលគណនាអត្រាការប្រាក់មានប្រសិទ្ធភាពសម្រាប់ឧបករណ៍ហិរញ្ញវត្ថុ ក្រៅពីទ្រព្យសកម្មដែលបានទិញ ឬមានប្រភពដើមជាឥណទានអ៊ីមតែរមិន ធនាគារប៉ាន់ស្មានលំហូរសាច់ប្រាក់នាពេលអនាគតរាប់បញ្ចូលរយៈពេលកិច្ចសន្យាទាំងអស់របស់ឧបករណ៍ហិរញ្ញវត្ថុ ប៉ុន្តែមិនគិត ECL។ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានទិញ ឬមានប្រភពដើមជាអ៊ីមតែរមិននៃឥណទាន អត្រាការប្រាក់មានប្រសិទ្ធភាពនៃឥណទានកែសម្រួល ត្រូវបានគណនាដោយប្រើប្រាស់ការប៉ាន់ស្មានលំហូរសាច់ប្រាក់នាពេលអនាគត រាប់បញ្ចូល ECL។ ការគណនាអត្រាការប្រាក់មានប្រសិទ្ធភាពរួមបញ្ចូលចំណាយប្រតិបត្តិការ និងកម្រៃបានបង់ ឬទទួល ដែលជាផ្នែកសំខាន់មួយនៃអត្រាការប្រាក់មានប្រសិទ្ធភាព។ ចំណាយប្រតិបត្តិការរួមបញ្ចូល ចំណាយបន្ថែមដែលកើតមានផ្ទាល់ពីការទិញទ្រព្យសកម្មហិរញ្ញវត្ថុ ឬបោះផ្សាយបំណុលហិរញ្ញវត្ថុ។

តម្លៃរំលស់ និងតម្លៃយោងដុល

តម្លៃរំលស់របស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ គឺជាតម្លៃដែលទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុដែលបានវាស់វែងនៅពេលទទួលស្គាល់ដំបូង ដកការបង់ថ្លៃដើម បូក ឬដករំលស់បង្គរតាមវិធីសាស្ត្រអត្រាការប្រាក់មានប្រសិទ្ធភាពនៃលម្អៀងរវាង តម្លៃដំបូង និងតម្លៃអាយុកាលកំណត់ ហើយកែសម្រួលនូវ ECL ណាដែលមានសម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុ។

តម្លៃយោងដុលនៃទ្រព្យសកម្មហិរញ្ញវត្ថុ គឺជាតម្លៃរំលស់របស់ទ្រព្យសកម្មហិរញ្ញវត្ថុ មុនពេលកែសម្រួលនូវ ECL ដែលមាន។

ការគណនានៃចំណូល និងចំណាយការប្រាក់

អត្រាការប្រាក់មានប្រសិទ្ធភាពរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានគណនានៅពេលទទួលស្គាល់ដំបូងរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។ ក្នុងការគណនាចំណូល និងចំណាយការប្រាក់ អត្រាការប្រាក់មានប្រសិទ្ធភាព គឺបានអនុវត្តលើតម្លៃយោងដុលនៃទ្រព្យសកម្ម (នៅពេលទ្រព្យសកម្មមិនមែនជាឥណទានអ៊ីមតែរមិន) ឬទៅលើតម្លៃរំលស់របស់បំណុល។ អត្រាការប្រាក់មានប្រសិទ្ធភាព ត្រូវបានកែតម្រូវតាមលទ្ធផលនៃការប៉ាន់ស្មានឡើងវិញលើសាច់ប្រាក់នៃឧបករណ៍មានអត្រាប្រែប្រួលដើម្បីឆ្លុះបញ្ចាំងពីចលនានៅក្នុងអត្រាការប្រាក់ទីផ្សារ។ អត្រាការប្រាក់មានប្រសិទ្ធភាពក៏ត្រូវបានកែប្រែ ដើម្បីធ្វើនិយ័តកម្មក្នុងការទប់ស្កាត់ហានិភ័យនៃតម្លៃសមស្របនាកាលបរិច្ឆេទធ្វើរំលស់នៃការធ្វើនិយ័តកម្មទប់ស្កាត់ហានិភ័យចាប់ផ្តើម។

ដោយឡែក សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានក្លាយជាឥណទានអ៊ីមតែរមិន បន្ទាប់ពីការទទួលស្គាល់ដំបូង ចំណូលការប្រាក់ត្រូវបានគណនា ដោយអនុវត្តតាមអត្រាការប្រាក់ មានប្រសិទ្ធភាពទៅលើតម្លៃរំលស់នៃទ្រព្យសកម្មហិរញ្ញវត្ថុនោះ។ ប្រសិនបើទ្រព្យសកម្មនោះលែងជាឥណទានអ៊ីមតែរមិន នោះការគណនានៃចំណូលការប្រាក់ប្តូរទៅជាមូលដ្ឋានដុលវិញ។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក

## 2. គោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

### 2.7 សង្ខេបនៃគោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

#### 2.7.13 ចំណូល និងចំណាយការប្រាក់ (តពីទំព័រមុន)

ការគណនានៃចំណូល និងចំណាយការប្រាក់ (តពីទំព័រមុន)

សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានក្លាយជាឥណទានអ៊ីមតែរមិន នៅពេលទទួលស្គាល់ដំបូងចំណូលការប្រាក់ត្រូវបានគណនា ដោយអនុវត្តតាមអត្រាការប្រាក់មានប្រសិទ្ធភាពនៃឥណទានដែលបានកែតម្រូវ ទៅលើតម្លៃរំលស់នៃទ្រព្យសកម្មហិរញ្ញវត្ថុ។ ការគណនាចំណូលការប្រាក់មិនត្រូវប្តូរទៅជាមូលដ្ឋានដុលវិញទេ ទោះបីជាហានិភ័យឥណទានរបស់ទ្រព្យសកម្មនោះបានប្រសើរឡើងក៏ដោយ។

ការបង្ហាញ

ចំណូល និងចំណាយការប្រាក់ ដែលបានបង្ហាញក្នុងរបាយការណ៍លទ្ធផលពេញលេញ ដោយគណនាក្នុងវិធីសាស្ត្រការប្រាក់មានប្រសិទ្ធភាព រួមបញ្ចូលទាំងការប្រាក់លើទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុដែលវាស់វែងតាមតម្លៃរំលស់។

#### 2.7.14 ចំណូល និងចំណាយថ្លៃឈ្នួល និងកម្រៃជើងសា

ធនាគាររកប្រាក់ចំណូលពីថ្លៃឈ្នួល និងកម្រៃជើងសាពីសេវាកម្មហិរញ្ញវត្ថុផ្សេងៗ ដែលផ្តល់ជូនអតិថិជនរបស់ខ្លួន។ ចំណូលថ្លៃឈ្នួល និងកម្រៃជើងសាត្រូវបានទទួលស្គាល់នៅចំនួនដែលឆ្លុះបញ្ចាំងពីតម្លៃតបស្នងដែលធនាគាររំពឹងថានឹងបានពីការផ្តល់សេវាទាំងនោះ។

ចំណូល និងចំណាយថ្លៃឈ្នួល និងកម្រៃជើងសា ដែលជាផ្នែកនៃអត្រាការប្រាក់ប្រសិទ្ធភាព របស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬ បំណុលហិរញ្ញវត្ថុត្រូវបានបញ្ចូលទៅក្នុងអត្រាការប្រាក់ប្រសិទ្ធភាព (កំណត់សម្គាល់លេខ 2.7.13)។

ថ្លៃឈ្នួលដែលទទួលបានពីការផ្តល់សេវាកម្មលើផលិតផលឥណទានក្នុងអំឡុងថេរៈវេលាមួយ ដូចជាកម្រៃលើកិច្ចសន្យារបស់ឥណទានវិបារូបន៍ គឺត្រូវបានបង្គរតាមថេរៈវេលានោះ។ ថ្លៃឈ្នួលដែលទទួលបានមុនពីអតិថិជនលើផលិតផលឥណទានរបស់ធនាគារក្នុងអំឡុងពេលមួយជាក់លាក់ ដូចជាកម្រៃជើងសាលើហិរញ្ញប្បទានពាណិជ្ជកម្ម កម្រៃទម្រង់ការ និងកម្រៃបន្តឥណទាន ត្រូវបានទទួលស្គាល់ជាចំណូលតាមវិធីសាស្ត្ររំលស់ថេរ ដោយអត្ថប្រយោជន៍លើសេវាកម្មត្រូវបានផ្ទេរទៅអតិថិជនក្នុងចន្លោះពេលវេលានោះស្មើៗគ្នា។

ចំណូលថ្លៃឈ្នួល និងកម្រៃជើងសាផ្សេងទៀតដូចជាការផ្ទេរប្រាក់ ចំណូលពីសេវាកម្ម ប័ណ្ណឥណទាន និងចំណូលផ្សេងៗទៀត គឺត្រូវទទួលស្គាល់នៅពេលដែលសេវាកម្មដែលពាក់ព័ន្ធនោះត្រូវបានផ្តល់ឱ្យទៅអតិថិជន។

ចំណាយថ្លៃឈ្នួល និងកម្រៃជើងសាភាគច្រើនទាក់ទងទៅនឹងប្រតិបត្តិការ និងតម្លៃសេវា ដែលបានចំណាយនៅពេលដែលសេវានោះត្រូវបានទទួល។

#### 2.7.15 ធានារ៉ាប់រងទូទៅ

លទ្ធផលពីការធានាទិញធានារ៉ាប់រងទូទៅត្រូវបានកំណត់ បន្ទាប់ពីការរាប់បញ្ចូលធានារ៉ាប់រងបន្ត ទុនបម្រុងសម្រាប់បុព្វលាភរ៉ាប់រងមិនទាន់ទទួលស្គាល់ កម្រៃជើងសាសុទ្ធ និងការទាមទារសំណងសុទ្ធបានកើតឡើង។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក

## 2. គោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

### 2.7 សង្ខេបនៃគោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

#### 2.7.15 ធានារ៉ាប់រងទូទៅ (តពីទំព័រមុន)

ទុនបម្រុងសម្រាប់បុព្វលាភរ៉ាប់រងមិនទាន់ទទួលស្គាល់ ("UPR") គឺជាផ្នែកមួយនៃបុព្វលាភសុទ្ធនៃគោលនយោបាយធានារ៉ាប់រង ដែលបានសរសេរជាលាយលក្ខណ៍អក្សរពាក់ព័ន្ធនឹងរយៈពេលដែលមិនទាន់ផុតកំណត់នៃគោលនយោបាយទាំងនោះនៅចុងបញ្ចប់នៃការិយបរិច្ឆេទហិរញ្ញវត្ថុ។ វិធីសាស្ត្រគណនាតាមភាគរយថេរ ឬតាមការបែងចែករយៈពេល គឺត្រូវបានប្រើប្រាស់ដើម្បីគណនា UPR នៅកាលបរិច្ឆេទរបាយការណ៍។

សំវិធានធនត្រូវបានផ្តល់ឱ្យលើការទាមទារសំណងដែលមិនទាន់ទូទាត់ ដោយផ្អែកតាមចំណាយប៉ាន់ស្មានរបស់បណ្តឹងទាមទារសំណងទាំងអស់ បូកបញ្ចូលជាមួយចំណាយពាក់ព័ន្ធ ហើយដកនឹងការប្រមូលបានមកវិញពីធានារ៉ាប់រងបន្តលើការទាមទារសំណងទាំងនោះ ដែលបានរាយការណ៍ប៉ុន្តែមិនទាន់ទូទាត់នៅកាលបរិច្ឆេទរបាយការណ៍។ សំវិធានធនក៏ត្រូវបានផ្តល់ឱ្យសម្រាប់ចំណាយ លើបណ្តឹងទាមទារ និងចំណាយពាក់ព័ន្ធដែលបានកើតឡើងប៉ុន្តែមិនទាន់បានរាយការណ៍ ("IBNR") នៅកាលបរិច្ឆេទរបាយការណ៍ផងដែរ។ ការប៉ាន់ប្រមាណលើការផ្តល់សំវិធានធនសម្រាប់បណ្តឹងទាមទារពាក់ព័ន្ធនឹងការព្យាករណ៍អំពីបទពិសោធន៍នៃការទាមទារ នាពេលអនាគតរបស់ក្រុមហ៊ុន ដោយផ្អែកលើបទពិសោធន៍នៃពាក្យបណ្តឹងកន្លងមក។ ដូចនេះ បទពិសោធន៍ បណ្តឹងទាមទារនាពេលអនាគតអាចខុសពីបទពិសោធន៍បណ្តឹងទាមទារជាក់ស្តែង ដោយសារកម្រិតនៃភាពមិនប្រាកដប្រជាពាក់ព័ន្ធនឹងការព្យាករណ៍បទពិសោធន៍ការទាមទារនាពេលអនាគត ផ្អែកលើបទពិសោធន៍នៃពាក្យបណ្តឹងទាមទារកន្លងមក។ ភាពមិនប្រាកដប្រជាទាំងនេះកើតឡើងពីការផ្លាស់ប្តូរហានិភ័យមូលដ្ឋាន ការផ្លាស់ប្តូរនៃគម្លាតហានិភ័យ ពេលវេលា និងចំនួននៃការដោះស្រាយបណ្តឹង ក៏ដូចជាភាពមិនប្រាកដប្រជានៅក្នុងម៉ូឌែលនៃការព្យាករណ៍ និងការសន្មតជាមូលដ្ឋាន។

#### 2.7.16 មូលបត្រ និងភ្នាក់ងារមូលបត្រ

កម្រៃជើងសា និងកម្រៃសេវា

ក្រុមហ៊ុនរួមទទួលស្គាល់ចំណូលពីការផ្តល់សេវាកម្មជាសមាមាត្រ ទៅនឹងដំណាក់កាលនៃការបំពេញប្រតិបត្តិការនាកាលបរិច្ឆេទរបាយការណ៍។ ដំណាក់កាលនៃការបំពេញត្រូវបានវាយតម្លៃដោយផ្អែកលើការអង្កេតលទ្ធផលនៃការងារដែលបានអនុវត្ត។

ប្រសិនបើ ក្រុមហ៊ុនរួមធ្វើសកម្មភាពក្នុងសមត្ថភាពជាភ្នាក់ងារជាជាងក្នុងនាមជាម្ចាស់ដើមក្នុងប្រតិបត្តិការមួយ នោះប្រាក់ចំណូលដែលបានទទួលស្គាល់ គឺជាចំនួនទឹកប្រាក់សុទ្ធនៃកម្រៃជើងសាដែលក្រុមហ៊ុនរួមរកបាន។

#### 2.7.17 ពន្ធលើប្រាក់ចំណូល

ចំណាយពន្ធលើប្រាក់ចំណូលរួមមានពន្ធបច្ចុប្បន្ន និងពន្ធពន្យារ។ ចំណាយនេះត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលពេញលេញ លើកលែងតែធាតុដែលត្រូវបានទទួលស្គាល់ដោយផ្ទាល់នៅក្នុងមូលធន ឬនៅក្នុងចំណូលលម្អិតផ្សេងទៀត។

ក្រុមហ៊ុនរួម និងធនាគារបានធ្វើការវិនិច្ឆ័យលើតម្លៃបំណុលពន្ធ និងពន្ធពន្យារ។ ការប្រើប្រាស់ការសន្មតខុសៗគ្នាអាចនាំឱ្យមានផលប៉ះពាល់ជាសារវន្តទៅលើរបាយការណ៍ហិរញ្ញវត្ថុ។បំណុលពន្ធចុងក្រោយនិងពន្ធពន្យាររបស់ក្រុមហ៊ុនរួម និងធនាគារត្រូវស្ថិតក្រោមការកំណត់ និងកិច្ចព្រមព្រៀងខាងមុខទៀតជាមួយអគ្គនាយកដ្ឋានពន្ធដារ ("GDT")។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក

## 2. គោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

### 2.7 សង្ខេបនៃគោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

#### 2.7.17 ពន្ធលើប្រាក់ចំណូល (តពីទំព័រមុន)

(i) ពន្ធបច្ចុប្បន្ន

ពន្ធបច្ចុប្បន្ន គឺជាបំណុលពន្ធលើប្រាក់ចំណូលសម្រាប់ប្រាក់ចំណូលជាប់ពន្ធក្នុងឆ្នាំ ដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬត្រូវបានអនុម័តជាធរមានតាមកាលបរិច្ឆេទរបាយការណ៍ និងការកែសម្រួលផ្សេងៗទៅបំណុលពន្ធលើប្រាក់ចំណូលដែលទាក់ទងពីឆ្នាំមុនៗ។

គណៈគ្រប់គ្រងបានវាយតម្លៃជាទៀងទាត់នូវស្ថានភាព ដែលមាននៅក្នុងលិខិតប្រកាសពន្ធទាក់ទងនឹងស្ថានភាពដែលបទប្បញ្ញត្តិស្តីពីពន្ធដារត្រូវអនុវត្តតាមការបកស្រាយ និងបង្កើតសំវិធានធននៅពេលសមស្រប។ ការលាតត្រដាងលម្អិតត្រូវបានផ្តល់ជូននៅក្នុងកំណត់សម្គាល់លេខ 15។

(ii) ពន្ធពន្យារ

ពន្ធពន្យារត្រូវបានទទួលស្គាល់លើភាពលម្អៀងបណ្តោះអាសន្ននៅកាលបរិច្ឆេទរបាយការណ៍ រវាងមូលដ្ឋានពន្ធនៃទ្រព្យសកម្ម និងទ្រព្យអកម្ម និងតម្លៃយោងរបស់ពួកវាសម្រាប់គោលបំណងរបាយការណ៍ហិរញ្ញវត្ថុ។

បំណុលពន្ធពន្យារត្រូវបានទទួលស្គាល់សម្រាប់លម្អៀងបណ្តោះអាសន្នជាប់ពន្ធ លើកលែងតែ៖

- នៅពេលដែលបំណុលពន្ធពន្យារកើតឡើងពីការទទួលស្គាល់ដំបូងនៃកេរ្តិ៍ឈ្មោះអាជីវកម្ម ឬទ្រព្យសកម្ម ឬទ្រព្យអកម្មនៅក្នុងប្រតិបត្តិការដែលមិនមែនជាការរួមបញ្ចូលអាជីវកម្ម ហើយនៅពេលប្រតិបត្តិការ (i) មិនមានការប៉ះពាល់ដល់ប្រាក់ចំណេញតាមគណនេយ្យ ឬប្រាក់ចំណេញជាប់ពន្ធនៅក្នុងរបាយការណ៍លទ្ធផលពេញលេញ និង (ii) មិនបង្កើតឱ្យមានការលម្អៀងបណ្តោះអាសន្នជាប់ពន្ធ និងកាត់កងបានស្មើគ្នា។
- ទាក់ទងនឹងលម្អៀងបណ្តោះអាសន្នជាប់ពន្ធ ដែលជាប់ទាក់ទងនឹងការវិនិយោគនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្នុងករណីដែលពេលវេលានៃការកត់ត្រាត្រឡប់នៃលម្អៀងបណ្តោះអាសន្ននោះអាចត្រូវបានគ្រប់គ្រង ហើយទំនងថាលម្អៀងបណ្តោះអាសន្ននោះនឹងមិនកត់ត្រាត្រឡប់មកវិញនាពេលអនាគត។

តម្លៃយោងរបស់ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានពិនិត្យឡើងវិញនៅកាលបរិច្ឆេទរបាយការណ៍នីមួយៗ និងកាត់បន្ថយដល់ទំហំណាមួយដែលមិនអាចនឹងមានប្រាក់ចំណេញជាប់ពន្ធគ្រប់គ្រាន់ ដើម្បីអនុញ្ញាតឱ្យប្រើប្រាស់ពន្ធពន្យារជាទ្រព្យសកម្មមានទាំងអស់ ឬផ្នែកខ្លះ។ ពន្ធពន្យារជាទ្រព្យសកម្មដែលមិនទាន់ទទួលស្គាល់ ត្រូវបានវាយតម្លៃនៅកាលបរិច្ឆេទរបាយការណ៍នីមួយៗ និងត្រូវបានគេទទួលស្គាល់ក្នុងទំហំ ដែលអាចនឹងទទួលបានថាមានប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតគ្រប់គ្រាន់ ដែលនឹងអនុញ្ញាតឱ្យពន្ធពន្យារទ្រព្យសកម្មអាចទទួលបានវិញ។

ពន្ធពន្យារជាទ្រព្យសកម្ម និងបំណុលពន្ធពន្យារ ត្រូវបានវាស់វែងតាមអត្រាពន្ធដែលរំពឹងថានឹងត្រូវបានអនុវត្តក្នុងឆ្នាំនោះនៅពេលដែលទ្រព្យសកម្មនោះបានលក់ ឬបំណុលនោះបានទូទាត់ដោយផ្អែកលើអត្រាពន្ធដែលបានអនុម័ត ឬត្រូវបានអនុម័តជាធរមាននៅកាលបរិច្ឆេទរបាយការណ៍។

ធនាគារអាចកាត់កងពន្ធពន្យារទ្រព្យសកម្ម ជាមួយបំណុលពន្ធពន្យារបាន នៅពេលដែលមានសិទ្ធិស្របច្បាប់ក្នុងការទូទាត់ពន្ធទ្រព្យសកម្ម និងបំណុលពន្ធបច្ចុប្បន្ន ហើយធនាគារមានបំណងទូទាត់តាមមូលដ្ឋានកាត់កង។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក

## 2. គោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

### 2.7 សង្ខេបនៃគោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

#### 2.7.18 ទ្រព្យអកម្មយថាភាព

ក្នុងករណីដែលមិនទំនងថាលំហូរចេញនៃផលប្រយោជន៍សេដ្ឋកិច្ចនឹងត្រូវការ ឬចំនួនទឹកប្រាក់ មិនអាចប៉ាន់ស្មានបានជាក់លាក់ នោះកាតព្វកិច្ចមិនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុទេ ហើយត្រូវលាតត្រដាងថាជាទ្រព្យអកម្មយថាភាព លើកលែងតែប្រូបាប៊ីលីតេ នៃលំហូរចេញនៃផលប្រយោជន៍សេដ្ឋកិច្ច គឺមិនមាន។ កាតព្វកិច្ចដែលអាចមានដែលអត្ថិភាពនៃកាតព្វកិច្ចនោះនឹងត្រូវបានបញ្ជាក់ដោយការកើតឡើង ឬការមិនកើតឡើងនៃព្រឹត្តិការណ៍នាពេលអនាគតមួយ ឬច្រើនក៏ត្រូវបានលាតត្រដាងថាជាទ្រព្យអកម្មយថាភាព លុះត្រាណាតែប្រូបាប៊ីលីតេនៃលំហូរចេញផលប្រយោជន៍សេដ្ឋកិច្ច គឺមិនមាន។

### 2.8 វិសោធនកម្មលើ CIFRSs ដែលបានចេញផ្សាយ និងបានអនុវត្តដោយក្រុមហ៊ុនរួម និងធនាគារ

ក្រុមហ៊ុនរួមបានអនុវត្តវិសោធនកម្មខាងក្រោមនេះជាលើកដំបូងសម្រាប់កាលបរិច្ឆេទរបាយការណ៍ប្រចាំឆ្នាំ ដោយចាប់ផ្តើមពីថ្ងៃ1 ខែមករា ឆ្នាំ 2024៖

(i) វិសោធនកម្មលើ CIAS 1, ទ្រព្យអកម្មរយៈពេលវែងជាមួយកិច្ចព្រមព្រៀង
(ii) វិសោធនកម្មលើ CIAS 7 និង CIFRS 7, ការរៀបចំលើហិរញ្ញប្បទានសម្រាប់អ្នកផ្គត់ផ្គង់
(iii) វិសោធនកម្មលើ CIFRS 16, បំណុលភតិសន្យាក្នុងការលក់ និងជួលត្រឡប់

វិសោធនកម្មដែលបានរាយបញ្ជីខាងលើពុំមានផលប៉ះពាល់គួរឱ្យកត់សម្គាល់ណាមួយទៅលើតម្លៃ ដែលបានទទួលស្គាល់ក្នុងឆ្នាំមុន ឆ្នាំបច្ចុប្បន្ន ឬឆ្នាំអនាគតនោះទេ។

### 2.9 ស្តង់ដា និងវិសោធនកម្មលើ CIFRSs ដែលបានចេញផ្សាយ ប៉ុន្តែមិនទាន់មានប្រសិទ្ធភាព

ស្តង់ដាថ្មី និងវិសោធនកម្មលើស្តង់ដាដែលបានចេញផ្សាយ ប៉ុន្តែមិនទាន់មានប្រសិទ្ធភាព ឬមិនបានអនុវត្តមុនពេលកំណត់ដោយក្រុមហ៊ុនរួម និងធនាគារ ដល់កាលបរិច្ឆេទនៃការចេញផ្សាយនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួម និងធនាគារ គឺបានលាតត្រដាងដូចខាងក្រោម៖

(i) ស្តង់ដា ដែលក្រុមហ៊ុនរួមមានបំណងអនុវត្តនៅពេលដែលមានប្រសិទ្ធភាព៖

- CIFRS 17 - កិច្ចសន្យាធានារ៉ាប់រង
  យោងតាមសេចក្តីជូនដំណឹងរបស់និយ័តករគណនេយ្យ និងសវនកម្ម ចុះថ្ងៃទី24 ខែមីនា ឆ្នាំ2024 ក្រុមហ៊ុនធានារ៉ាប់រងទទួលបានការអនុញ្ញាតឱ្យពន្យារពេលអនុវត្តស្តង់ដានេះ។ ក្រុមហ៊ុនធានារ៉ាប់រងដែលអាចអនុវត្តបានមុនកាលកំណត់ ត្រូវបានលើកទឹកចិត្ត។ ធនាគារទទួលលិខិតពីនិយ័តករគណនេយ្យ និងសវនកម្ម ចុះថ្ងៃទី15 ខែកុម្ភៈ ឆ្នាំ2024 ដែលបានអនុញ្ញាតឱ្យធនាគារពន្យារពេលអនុវត្ត CIFRS 17 រហូតដល់ថ្ងៃទី1 ខែមករា ឆ្នាំ2026។ នៅថ្ងៃទី23 ខែធ្នូ ឆ្នាំ2024 និយ័តករគណនេយ្យ និងសវនកម្មបានចេញសេចក្តីជូនដំណឹងដែលអនុញ្ញាតឱ្យក្រុមហ៊ុនធានារ៉ាប់រងបន្តពន្យារពេលអនុវត្ត CIFRS 17 រហូតដល់ថ្ងៃទី1 ខែមករា ឆ្នាំ2028។

(ii) ស្តង់ដា ដែលបានធ្វើវិសោធនកម្ម ដែលមិនរំពឹងទុកថាប៉ះពាល់ជាសារវន្តលើក្រុមហ៊ុនរួម៖

ប្រសិទ្ធភាពចាប់ផ្តើម ឬបន្ទាប់ពីថ្ងៃទី1 ខែមករា ឆ្នាំ2025

- វិសោធនកម្មលើ CIAS 21, ការខ្វះខាតលើលទ្ធភាពដោះដូរ

ប្រសិទ្ធភាពចាប់ផ្តើម ឬបន្ទាប់ពីថ្ងៃទី1 ខែមករា ឆ្នាំ2026

- វិសោធនកម្មលើ CIFRS 9 និង CIFRS 7, ចំណាត់ថ្នាក់ និងការវាស់វែងនៃឧបករណ៍ហិរញ្ញវត្ថុ
- ការកែលម្អប្រចាំឆ្នាំលើស្តង់ដាគណនេយ្យ CIFRS - លេខ 11

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក

## 2. គោលនយោបាយគណនេយ្យជាសារវន្ត (តពីទំព័រមុន)

2.9 ស្តង់ដា និងវិសោធនកម្មលើ CIFRSs ដែលបានចេញផ្សាយ ប៉ុន្តែមិនទាន់មានប្រសិទ្ធភាព (តពីទំព័រមុន)

ប្រសិទ្ធភាពចាប់ផ្តើមឬបន្ទាប់ពីថ្ងៃទី1 ខែមករា ឆ្នាំ2027

- CIFRS 18, ការបង្ហាញ និងការលាតត្រដាងក្នុងរបាយការណ៍ហិរញ្ញវត្ថុ
- CIFRS 19, បុត្រសម្ព័ន្ធដែលពុំមានការទទួលខុសត្រូវជាសាធារណៈ ៖ ការលាតត្រដាង

កាលបរិច្ឆេទប្រសិទ្ធភាពបានពន្យារជាអចិន្ត្រៃយ៍

- វិសោធនកម្មលើ CIFRS 10, របាយការណ៍ហិរញ្ញវត្ថុរួម និង CIAS 28, លក់ ឬ ការរួមចំណែកនៃទ្រព្យសកម្ម រវាងវិនិយោគិន និងក្រុមហ៊ុនសម្ព័ន្ធញាតិ ឬក្រុមហ៊ុនរួមទុនរបស់ខ្លួន

## 3. សាច់ប្រាក់ក្នុងដៃ

សាច់ប្រាក់ក្នុងដៃរួមមាន៖

| | *ក្រុមហ៊ុនរួម* | | | | *ធនាគារ* | | | |
|---|---|---|---|---|---|---|---|---|
| | *2024* | | *2023* | | *2024* | | *2023* | |
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5)* |
| ដុល្លារអាមេរិក | 53,568,889 | 215,614,778 | 54,946,375 | 224,455,942 | 53,568,080 | 215,611,522 | 54,945,909 | 224,454,038 |
| ខ្មែររៀល | 9,008,073 | 36,257,494 | 7,579,613 | 30,962,719 | 9,008,073 | 36,257,494 | 7,579,613 | 30,962,719 |
| រូបិយប័ណ្ណផ្សេង | 408,401 | 1,643,814 | 1,999 | 8,166 | 408,401 | 1,643,814 | 1,999 | 8,166 |
| | **62,985,363** | **253,516,086** | **62,527,987** | **255,426,827** | **62,984,554** | **253,512,830** | **62,527,521** | **255,424,923** |

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក

## 3. សាច់ប្រាក់ក្នុងដៃ (តពីទំព័រមុន)

សម្រាប់គោលបំណងនៃរបាយការណ៍លំហូរសាច់ប្រាក់ សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមាន៖

| | ក្រុមហ៊ុនរួម | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | 2024 | | 2023 | | 2024 | | 2023 | |
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5) |
| សាច់ប្រាក់ក្នុងដៃ | 62,985,363 | 253,516,086 | 62,527,987 | 255,426,827 | 62,984,554 | 253,512,830 | 62,527,521 | 255,424,923 |
| សមតុល្យជាមួយធនាគារជាតិនៃកម្ពុជា | 126,390,844 | 508,723,147 | 101,514,494 | 414,686,708 | 126,390,844 | 508,723,147 | 101,514,494 | 414,686,708 |
| សមតុល្យជាមួយធនាគារផ្សេងៗ និងគ្រឹះស្ថានហិរញ្ញវត្ថុ | 171,847,451 | 6 91,685,990 | 152,984,878 | 624,943,227 | 171,825,905 | 691,599,268 | 152,442,599 | 622,728,017 |
| | **361,223,658** | **1,453,925,223** | **317,027,359** | **1,295,056,762** | **361,201,303** | **1,453,835,245** | **316,484,614** | **1,292,839,648** |

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក

## 4. សមតុល្យជាមួយធនាគារជាតិនៃកម្ពុជា

សមតុល្យជាមួយធនាគារជាតិនៃកម្ពុជារួមមាន៖

| | ក្រុមហ៊ុនរួម | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | 2024 | | 2023 | | 2024 | | 2023 | |
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5) |
| គណនីចរន្តជាប្រាក់ដុល្លារអាមេរិក | 102,736,013 | 413,512,452 | 92,765,305 | 378,946,271 | 102,736,013 | 413,512,452 | 92,765,305 | 378,946,271 |
| គណនីចរន្តជាប្រាក់រៀល | 23,654,831 | 95,210,695 | 8,749,189 | 35,740,437 | 23,654,831 | 95,210,695 | 8,749,189 | 35,740,437 |
| ប្រាក់បញ្ញើទុនបម្រុង | 108,211,250 | 435,550,281 | 100,385,600 | 410,075,176 | 108,211,250 | 435,550,281 | 100,385,600 | 410,075,176 |
| ប្រាក់តម្កល់ធានាលើដើមទុន | 10,700,000 | 43,067,500 | 10,700,000 | 43,709,500 | 9,000,000 | 36,225,000 | 9,000,000 | 36,765,000 |
| មូលបត្រអាចជួញដូរបាន | 20,000,000 | 80,500,000 | 25,000,000 | 102,125,000 | 20,000,000 | 80,500,000 | 25,000,000 | 102,125,000 |
| | **265,302,094** | **1,067,840,928** | **237,600,094** | **970,596,384** | **263,602,094** | **1,060,998,428** | **235,900,094** | **963,651,884** |

### ប្រាក់បញ្ញើទុនបម្រុង

យោងតាមលិខិតរបស់ធនាគារជាតិនៃកម្ពុជា លេខ ធ7-023-1127 ស.ជ.ណ ចុះថ្ងៃទី23 ខែវិច្ឆិកា ឆ្នាំ2023 ប្រាក់បញ្ញើបម្រុងកាតព្វកិច្ចអប្បបរមាជាមួយធនាគារជាតិនៃកម្ពុជា ត្រូវកំណត់ឱ្យរក្សានៅអត្រា 7.00% នៃប្រាក់បញ្ញើពីអតិថិជនជារូបិយប័ណ្ណប្រាក់រៀល និងជារូបិយប័ណ្ណផ្សេងៗទៀតក្រៅពីរូបិយប័ណ្ណប្រាក់រៀលរហូតដល់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 (2023៖ រូបិយប័ណ្ណប្រាក់រៀល និងជារូបិយប័ណ្ណផ្សេងៗទៀតក្រៅពីរូបិយប័ណ្ណប្រាក់រៀលនៅអត្រា 7.00%)។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក

## 4. សមតុល្យជាមួយធនាគារជាតិនៃកម្ពុជា (តពីទំព័រមុន)

### ប្រាក់តម្កល់ធានាលើដើមទុន

#### ធនាគារ

យោងតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជា លេខ ធ7-01-136 ចុះថ្ងៃទី15 ខែតុលា ឆ្នាំ2001 គ្រប់ធនាគារតម្រូវឱ្យតម្កល់ប្រាក់ធានាចំនួន 10% នៃដើមទុនចុះបញ្ជីជាមួយធនាគារជាតិនៃកម្ពុជា។ ប្រាក់តម្កល់នេះ គឺមិនអាចប្រើប្រាស់ក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ធនាគារបានឡើយ ប៉ុន្តែធនាគារអាចដកយកវិញបាននៅពេលដែលធនាគារសម្រេចចិត្តឈប់ធ្វើអាជីវកម្មនៅក្នុងប្រទេសកម្ពុជា។

#### ក្រុមហ៊ុនធានារ៉ាប់រងកម្ពុឡុនប៉ាក ភីអិលស៊ី

ក្រោមអនុក្រឹត្យរបស់កម្ពុជា ស្តីពីធានារ៉ាប់រង ចុះថ្ងៃទី22 ខែតុលា ឆ្នាំ2001 និងសារាចរលេខ 009 របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី9 ខែធ្នូ ឆ្នាំ2002 ក្រុមហ៊ុនធានារ៉ាប់រងតម្រូវឱ្យរក្សា ប្រាក់តម្កល់តាមច្បាប់ ស្មើនឹង10% នៃដើមទុនចុះបញ្ជីជាមួយធនាគារជាតិនៃកម្ពុជា។

#### ក្រុមហ៊ុន មូលបត្រ កម្ពុ ម.ក

ប្រាក់តម្កល់តាមច្បាប់ ត្រូវបានរក្សាទុកជាមួយធនាគារជាតិនៃកម្ពុជា អនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ដូចដែលបានកំណត់ក្នុងមាត្រា 17 នៃប្រកាសលេខ 009 គ.ម.ក/09 ចុះថ្ងៃទី18 ខែវិច្ឆិកា ឆ្នាំ2009 ស្តីពីការផ្តល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារមូលបត្រដែលចេញផ្សាយដោយនិយ័តករមូលបត្រកម្ពុជា ("SERC")។

### មូលបត្រអាចជួញដូរបាន

ធនាគារបានដាក់មូលបត្រអាចជួញដូរបាន ("NCD") ក្នុងតម្លៃ 15,000,000 ដុល្លារអាមេរិក (2023៖ 15,000,000 ដុល្លារអាមេរិក) ជាមួយនឹងធនាគារជាតិនៃកម្ពុជា ជាទ្រព្យបញ្ចាំសម្រាប់ហ្វាស៊ីលីធីគណនីទូទាត់។ គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 ធនាគារមិនទាន់បានប្រើប្រាស់ឥណទានវិបារូបន៍លើហ្វាស៊ីលីធីគណនីទូទាត់នៅឡើយទេ។

NCD ផ្សេងទៀតដែលមានតម្លៃ 5,000,000 ដុល្លារអាមេរិក (2023៖ 5,000,000 ដុល្លារអាមេរិក) ជាមួយនឹងធនាគារជាតិនៃកម្ពុជា ត្រូវបានដាក់ជាទ្រព្យបញ្ចាំសម្រាប់ការចូលរួមក្នុងប្រព័ន្ធទូទាត់រាយរបស់ KOICA ("KOICA")។

ពុំមាន NCD ជាមួយនឹងធនាគារជាតិនៃកម្ពុជាសម្រាប់គោលបំណងក្នុងការរកចំណូលការប្រាក់នោះទេ គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 (2023៖ 5,000,000 ដុល្លារអាមេរិក)។

### អត្រាការប្រាក់

អត្រាការប្រាក់ប្រចាំឆ្នាំលើសមតុល្យនៅធនាគារជាតិនៃកម្ពុជាមានដូចខាងក្រោម៖

| | 2024 | 2023 |
|---|---|---|
| ប្រាក់តម្កល់ធានាលើដើមទុន | 1.31% | 1.19% - 1.33% |
| មូលបត្រអាចជួញដូរបាន | 1.03% - 1.38% | 0.83% - 3.48% |

គណនីចរន្តគឺតាមតម្រូវការ ហើយ NCD មានអាយុកាលកំណត់ចន្លោះពី 2 សប្តាហ៍ ទៅ1ឆ្នាំ។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក

## 5. សមតុល្យជាមួយធនាគារផ្សេងៗ និងគ្រឹះស្ថានហិរញ្ញវត្ថុ

សមតុល្យជាមួយធនាគារផ្សេងៗ និងគ្រឹះស្ថានហិរញ្ញវត្ថុរួមមាន៖

| | ក្រុមហ៊ុនរួម | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | 2024 | | 2023 | | 2024 | | 2023 | |
| | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5) | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5) |
| គណនីចរន្ត និងគណនីសន្សំជាមួយ៖ | | | | | | | | |
| ធនាគារក្នុងស្រុក | 21,546 | 86,723 | 547,362 | 2,235,974 | 5,067 | 20,395 | 5,083 | 20,764 |
| ធនាគារក្រៅស្រុក | 36,820,838 | 148,203,872 | 22,437,516 | 91,657,253 | 36,820,838 | 148,203,872 | 22,437,516 | 91,657,253 |
| ប្រាក់បញ្ញើ | 539,410,872 | 2,171,128,760 | 438,489,700 | 1,791,230,425 | 518,789,200 | 2,088,126,530 | 424,045,600 | 1,732,226,276 |
| | **576,253,256** | **2,319,419,355** | **461,474,578** | **1,885,123,652** | **555,615,105** | **2,236,350,797** | **446,488,199** | **1,823,904,293** |
| សំវិធានធនសម្រាប់ការខាតបង់ឥណទានរំពឹងទុក ("ECL") | (107,697) | (433,480) | (400,583) | (1,636,382) | (92,212) | (371,153) | (218,719) | (893,467) |
| | **576,145,559** | **2,318,985,875** | **461,073,995** | **1,883,487,270** | **555,522,893** | **2,235,979,644** | **446,269,480** | **1,823,010,826** |

គណនីចរន្ត និងគណនីសន្សំដែលមាននៅក្នុងធនាគារក្នុងស្រុក និងធនាគារក្រៅស្រុក ទទួលបានការប្រាក់ក្នុងអត្រាចាប់ពី 0.00% ទៅ 2.10% ក្នុងមួយឆ្នាំ (ឆ្នាំ2023៖ 0.08% ទៅ 3.50%)។

ប្រាក់បញ្ញើ រួមមានប្រាក់បញ្ញើមានកាលកំណត់ដែលទទួលបានការប្រាក់ចាប់ពី 4.20% ទៅ 6.50% ក្នុងមួយឆ្នាំ (ឆ្នាំ2023៖ 1.00% ទៅ 6.50%)។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក

## 5. សមតុល្យជាមួយធនាគារផ្សេងៗ និងគ្រឹះស្ថានហិរញ្ញវត្ថុ (តពីទំព័រមុន)

បម្រែបម្រួលសម្រាប់ ECL លើសមតុល្យជាមួយធនាគារផ្សេងៗ និងគ្រឹះស្ថានហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួម និងធនាគារមានដូចខាងក្រោម៖

| | *ក្រុមហ៊ុនរួម* | | | | *ធនាគារ* | | | |
|---|---|---|---|---|---|---|---|---|
| | *2024* | | *2023* | | *2024* | | *2023* | |
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5)* |
| សមតុល្យនាដើមការិយបរិច្ឆេទ (ការកត់ត្រាត្រឡប់) | 400,583 | 1,636,382 | 400,164 | 1,647,475 | 218,719 | 893,467 | 217,983 | 897,436 |
| សំវិធានធនក្នុងឆ្នាំ | (292,886) | (1,192,339) | 419 | 1,722 | (126,507) | (515,010) | 736 | 3,025 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (10,563) | - | (12,815) | - | (7,304) | - | (6,994) |
| សមតុល្យនាចុងការិយបរិច្ឆេទ | **107,697** | **433,480** | **400,583** | **1,636,382** | **92,212** | **371,153** | **218,719** | **893,467** |

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក

## 6. ឥណទាន និងបុរេប្រទាន

ឥណទាន និងបុរេប្រទានរបស់ សម្ព័ន្ធធនាគារ និងធនាគារមានដូចខាងក្រោម៖

| | 2024 | | 2023 | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5)* |
| ឥណទានមានការកំណត់ | 998,991,352 | 4,020,940,192 | 959,857,096 | 3,921,016,237 |
| ឥណទានវិបារូបន៍ | 313,618,460 | 1,262,314,302 | 278,976,428 | 1,139,618,708 |
| ឥណទានគេហដ្ឋាន | 160,200,357 | 644,806,437 | 150,673,210 | 615,500,063 |
| សក្ខីបត្រជំនឿទុកចិត្ត | 4,698,732 | 18,912,396 | 2,262,302 | 9,241,504 |
| ប័ណ្ណឥណទាន | 3,782,228 | 15,223,468 | 3,457,955 | 14,125,746 |
| ឥណទានយានយន្ត | 666,467 | 2,682,529 | 379,561 | 1,550,507 |
| | **1,481,957,596** | **5,964,879,324** | **1,395,606,552** | **5,701,052,765** |
| ការប្រាក់ដែលនឹងត្រូវទទួល | 12,101,005 | 48,706,545 | 7,980,767 | 32,601,433 |
| **ឥណទាន និងបុរេប្រទានសរុប-ដុល** | **1,494,058,601** | **6,013,585,869** | **1,403,587,319** | **5,733,654,198** |
| ដក៖ សំវិធានធនសម្រាប់ ECL | ( 13,597,417 ) | ( 54,729,603 ) | ( 14,035,849 ) | ( 57,336,443 ) |
| **ឥណទាន និងបុរេប្រទាន-សុទ្ធ** | **1,480,461,184** | **5,958,856,266** | **1,389,551,470** | **5,676,317,755** |

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក

## 6. ឥណទាន និងបុរេប្រទាន (តពីទំព័រមុន)

ការវិភាគបន្ថែមលើឥណទាន និងបុរេប្រទាន មានដូចខាងក្រោម៖

(i) បម្រែបម្រួលនៃសំវិធានធនសម្រាប់ ECL លើឥណទាន និងបុរេប្រទាន

| | *2024* | | | |
|---|---|---|---|---|
| | *ដំណាក់កាល 1* | *ដំណាក់កាល 2* | *ដំណាក់កាល 3* | *សរុប* |
| | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* |
| **សមតុល្យនាដើមការិយបរិច្ឆេទ** | **1,550,556** | **6,866,510** | **5,618,783** | **14,035,849** |
| *ការប្រែប្រួលដោយសារហានិភ័យ៖* | | | | |
| ផ្ទេរទៅដំណាក់កាល 1 | 361,112 | (329,963) | (31,149) | - |
| ផ្ទេរទៅដំណាក់កាល 2 | (108,295) | 2,208,396 | (2,100,101) | - |
| ផ្ទេរទៅដំណាក់កាល 3 | (27,081) | (639,863) | 666,944 | - |
| ការវាស់វែងឡើងវិញសុទ្ធដោយសារការប្រែប្រួលនៃហានិភ័យឥណទាន | (194,403) | (561,753) | 11,390,011 | 10,633,855 |
| ការផ្លាស់ប្តូរលើការបែងចែកជាផ្នែក | (352,205) | (944,198) | (627,703) | (1,924,106) |
| ទ្រព្យសកម្មហិរញ្ញវត្ថុថ្មី | 238,781 | 1,957,567 | 358,915 | 2,555,263 |
| ឥទ្ធិពលនៃការប្រមូល និងបម្រែបម្រួលផ្សេងទៀតនៅក្នុងសមតុល្យត្រូវទទួល | (285,565) | (2,264,227) | (946,936) | (3,496,728) |
| ចំនួនដែលបានលុបចោល | - | - | (8,229,873) | (8,229,873) |
| បម្រែបម្រួលរូបិយប័ណ្ណបរទេស | 2,951 | 11,806 | 8,400 | 23,157 |
| **សំវិធានធនសម្រាប់ ECL** | **1,185,851** | **6,304,275** | **6,107,291** | **13,597,417** |
| **សមមូលពាន់រៀល** *(កំណត់សម្គាល់លេខ 2.5)* | **4,773,050** | **25,374,707** | **24,581,846** | **54,729,603** |

* *ឥណទាន និងបុរេប្រទានថ្មីដែលបានបង្កើតនៅក្នុងឆ្នាំ គឺមិនមែនជាឥណទានមានអ៊ីមភែរមិននៅពេលដែលបង្កើតដំបូងនោះទេ ប៉ុន្តែហានិភ័យឥណទានបានចុះខ្សោយក្នុងអំឡុងពេលបន្ទាប់។*

** *ផលប៉ះពាល់លើការវាស់វែងនៃ ECL ដោយសារការផ្លាស់ប្តូរលើការបែងចែកជាផ្នែកក្នុងឆ្នាំ ដែលកើតឡើងពីការកែសម្រួលឡើងវិញលើសំពៀតឥណទាន ដើម្បីឆ្លុះបញ្ចាំងពីព័ត៌មានថ្មីបំផុត។*

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក

## 6. ឥណទាន និងបុរេប្រទាន (តពីទំព័រមុន)

(i) បម្រែបម្រួលនៃសំវិធានធនសម្រាប់ ECL លើឥណទាន និងបុរេប្រទាន (តពីទំព័រមុន)

| | 2023 | | | |
|---|---|---|---|---|
| | *ដំណាក់កាល 1* | *ដំណាក់កាល 2* | *ដំណាក់កាល 3* | *សរុប* |
| | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* |
| **សមតុល្យនាដើមការិយបរិច្ឆេទ** | **1,696,054** | **3,171,663** | **4,959,734** | **9,827,451** |
| *ការប្រែប្រួលដោយសារហានិភ័យ៖* | | | | |
| ផ្ទេរទៅដំណាក់កាល 1 | 346,216 | (287,801) | (58,415) | - |
| ផ្ទេរទៅដំណាក់កាល 2 | (75,392) | 610,514 | (535,122) | - |
| ផ្ទេរទៅដំណាក់កាល 3 | (2,825) | (838,490) | 841,315 | - |
| ការវាស់វែងឡើងវិញសុទ្ធដោយសារការប្រែប្រួលនៃហានីភ័យឥណទាន | (573,116) | 1,976,824 | 8,981,630 | 10,385,338 |
| ទ្រព្យសកម្មហិរញ្ញវត្ថុថ្មី* | 304,245 | 2,460,451 | 253,702 | 3,018,398 |
| ឥទ្ធិពលនៃការប្រមូលនិងបម្រែបម្រួលផ្សេងទៀតនៅក្នុងសមតុល្យត្រូវទទួល | (151,247) | (228,787) | (381) | (380,415) |
| ចំនួនដែលបានលុបចោល | - | - | (8,827,298) | (8,827,298) |
| បម្រែបម្រួលរូបិយប័ណ្ណបរទេស | 6,621 | 2,136 | 3,618 | 12,375 |
| **សំវិធានធនសម្រាប់ ECL** | **1,550,556** | **6,866,510** | **5,618,783** | **14,035,849** |
| **សមមូលពាន់រៀល** *(កំណត់សម្គាល់លេខ 2.5)* | **6,334,021** | **28,049,693** | **22,952,729** | **57,336,443** |

** ឥណទាន និងបុរេប្រទានថ្មីដែលបានបង្កើតនៅក្នុងឆ្នាំ គឺមិនមែនជាឥណទានមានអ៊ីមភែរមិន នៅពេលដែលបង្កើតដំបូងនោះទេ ប៉ុន្តែហានិភ័យឥណទានបានចុះខ្សោយក្នុងអំឡុងពេលបន្ទាប់។*

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក

## 6. ឥណទាន និងបុរេប្រទាន (តពីទំព័រមុន)

(ii) ការកំណត់ចំណាត់ថ្នាក់សំពៀតឥណទាន រួមបញ្ចូលទាំងការប្រាក់ត្រូវទទួលសុទ្ធ

| | 2024 | | 2023 | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5)* |
| ដំណាក់កាល 1 | 1,388,000,330 | 5,586,701,328 | 1,308,480,227 | 5,345,141,727 |
| ដំណាក់កាល 2 | 77,010,681 | 309,967,991 | 75,457,167 | 308,242,527 |
| ដំណាក់កាល 3 | 29,047,590 | 116,916,550 | 19,649,925 | 80,269,944 |
| **សរុប** | **1,494,058,601** | **6,013,585,869** | **1,403,587,319** | **5,733,654,198** |

យោងទៅ កំណត់សម្គាល់លេខ 27.2 (ច) ហានិភ័យឥណទាន ដើម្បីវិភាគលើគុណភាពឥណទាន។

(iii) ការវិភាគលើសំពៀតឥណទានតាមប្រភេទអាជីវកម្ម

យោងទៅកំណត់សម្គាល់លេខ 27.2 (ង) លើបណ្តុំហានិភ័យនៃសំពៀតឥណទានតាមប្រភេទអាជីវកម្ម។

(iv) ការវិភាគសំពៀតឥណទាន តាមអាយុកាលកំណត់

យោងទៅកំណត់សម្គាល់លេខ 30 លើទម្រង់អាយុកាលកំណត់។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក

## 6. ឥណទាន និងបុរេប្រទាន (តពីទំព័រមុន)

(v) វិភាគសំពៀតឥណទានតាមនិវាសនភាព ទំនាក់ទំនង ហានិភ័យ និងអត្រាការប្រាក់៖

| | 2024 | | 2023 | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5)* |
| និវាសនភាព | | | | |
| និវាសនជន | 1,494,058,601 | 6,013,585,869 | 1,403,587,319 | 5,733,654,198 |
| អនិវាសនជន | - | - | - | - |
| | **1,494,058,601** | **6,013,585,869** | **1,403,587,319** | **5,733,654,198** |
| ទំនាក់ទំនង | | | | |
| ភាគីពាក់ព័ន្ធ | 11,676,655 | 46,998,536 | 11,670,245 | 47,672,951 |
| ភាគីមិនពាក់ព័ន្ធ | 1,482,381,946 | 5,966,587,333 | 1,391,917,074 | 5,685,981,247 |
| | **1,494,058,601** | **6,013,585,869** | **1,403,587,319** | **5,733,654,198** |
| ហានិភ័យ | | | | |
| ធំ | 30,655,423 | 123,388,078 | 48,490,360 | 198,083,121 |
| មិនធំ | 1,463,403,178 | 5,890,197,791 | 1,355,096,959 | 5,535,571,077 |
| | **1,494,058,601** | **6,013,585,869** | **1,403,587,319** | **5,733,654,198** |
| អត្រាការប្រាក់ប្រចាំឆ្នាំ | | | | |
| ឥណទានវិបារូបន៍ | | 5.25% - 10.00% | | 5.25% - 8.50% |
| ឥណទានមានការកំណត់ | | 3.00% - 13.00% | | 3.00% - 12.00% |
| សក្ខីបត្រជំនឿទុកចិត្ត | | 6.50% - 7.00% | | 6.75% - 8.50% |
| ឥណទានគេហដ្ឋាន | | 6.50% - 10.00% | | 6.50% - 8.50% |
| ឥណទានយានយន្ត | | 8.00% - 10.00% | | 10.00% |

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក

## 6. ឥណទាន និងបុរេប្រទាន (តពីទំព័រមុន)

(vi) វិភាគសំពៀតឥណទានតាមអាយុកាលដែលនៅសល់បែងចែកដោយអតិថិជនជាធនាគារ និងអតិថិជនមិនមែនជាធនាគារ ៖

| | 2024 | | 2023 | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5)* |
| អតិថិជនជាធនាគារ | | | | |
| ក្នុងរយៈពេលមួយឆ្នាំ | 204,783 | 824,252 | 206,277 | 842,642 |
| មួយទៅប្រាំឆ្នាំ | 3,472,977 | 13,978,732 | 4,475,935 | 18,284,194 |
| ច្រើនជាងប្រាំឆ្នាំ | 2,919,927 | 11,752,706 | 1,983,955 | 8,104,456 |
| | **6,597,687** | **26,555,690** | **6,666,167** | **27,231,292** |
| អតិថិជនមិនមែនជាធនាគារ | | | | |
| ក្នុងរយៈពេលមួយឆ្នាំ | 366,242,523 | 1,474,126,155 | 295,756,348 | 1,208,164,682 |
| មួយទៅប្រាំឆ្នាំ | 127,318,929 | 512,458,689 | 165,257,174 | 675,075,556 |
| ច្រើនជាងប្រាំឆ្នាំ | 993,899,462 | 4,000,445,335 | 935,907,630 | 3,823,182,668 |
| | **1,487,460,914** | **5,987,030,179** | **1,396,921,152** | **5,706,422,906** |
| | **1,494,058,601** | **6,013,585,869** | **1,403,587,319** | **5,733,654,198** |

## 7. ការវិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ

ការវិនិយោគ លើបុត្រសម្ព័ន្ធតាមតម្លៃភាគហ៊ុនមានដូចខាងក្រោម៖

| | 2024 | | 2023 | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2.5)* |
| ក្រុមហ៊ុនធានារ៉ាប់រងកម្ពុ ឡុនប៉ាក ភីអិលស៊ី | 3,570,000 | 14,369,250 | 3,570,000 | 14,583,450 |
| ក្រុមហ៊ុន មូលបត្រ កម្ពុ ម.ក | 12,000,000 | 48,300,000 | 12,000,000 | 49,020,000 |
| | **15,570,000** | **62,669,250** | **15,570,000** | **63,603,450** |

